ISSN 1560-7615 / ISBN 978-99950-52-06-5

# ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី១០ លេខ ៤ | តុលា - ធ្នូ ឆ្នាំ២០០៦ | តម្លៃ ១.៥០០៛

## គួរឱ្យក្រុមប្រឹក្សាឃុំធ្វើជាអ្នកគ្រប់គ្រងព្រៃឈើ

**Iben Nathan, Tove Enggrob Boon អាន សុវត្ថា និង Kasper Hansen ពិភាក្សាពីតួនាទីដ៏សំខាន់ ដែលក្រុមប្រឹក្សាឃុំអាចអនុវត្តដើម្បីបំពេញតំរូវការជាបន្ទាន់ក្នុងការធានាជីវភាពប្រជាជនជនបទក្រីក្រ ជាអ្នកពឹងផ្អែកលើព្រៃឈើ ដោយអាចរក្សាធនធានដ៏មានតំលៃនេះឱ្យមានចីរភាពថែមទៀត ***

ប្រទេសកម្ពុជា មានកិច្ចការជាបន្ទាន់មួយ គឺធានាជីវភាពប្រជាជនក្រីក្រនៅជនបទ ដែលពឹងផ្អែកលើព្រៃឈើ ហើយរក្សាព្រៃដ៏មានតំលៃឱ្យមានចីរភាព ។ ដោយសាររបបគ្រប់គ្រងពីមុនៗ ខកខានមិនបានបំពេញតំរូវការទាំងនេះ ជំនាញការបរទេស និងអ្នកអនុវត្តកិច្ចការអភិវឌ្ឍន៍ បានផ្ដល់មតិជំរុញយ៉ាងខ្លាំងឱ្យប្រគល់ការងារ គ្រប់គ្រងព្រៃឈើទៅឱ្យអង្គភាពវិមជ្ឈការ ដូចជា សហគមន៍ព្រៃឈើ និងក្រុមប្រឹក្សាឃុំ ។ យោងតាមបទពិសោធន៍ខាងការគ្រប់គ្រងព្រៃឈើផ្អែកលើសហគមន៍ អត្ថបទនេះ បង្ហាញថា នៅប្រទេសកម្ពុជា ការគ្រប់គ្រងព្រៃឈើដោយក្រុមប្រឹក្សាឃុំ អាចដំណើរការទៅបានលុះត្រាតែសហគមន៍បានទទួលផលប្រយោជន៍សំខាន់ៗ ហើយមន្ត្រីរដ្ឋជាន់ខ្ពស់ និង/រឺ តួអង្គខាងក្រៅ ត្រូវតែផ្ដល់ការគាំទ្រ និងបំពេញតួនាទីយ៉ាងសកម្ម ។



*ក្រុមគ្រប់គ្រងព្រៃឈើផ្អែកលើសហគមន៍ យល់ដឹងពីសារៈសំខាន់នៃការថែរក្សាធនធានព្រៃឈើសំរាប់អ្នកជំនាន់ក្រោយ ។*

### សេចក្ដីផ្ដើម

ព្រៃឈើមានទំហំប្រហែល ៥៨% នៃផ្ទៃដីកម្ពុជាសរុប រឺប្រហែល ១០លានហិកតា ប៉ុន្តែតំបន់ព្រៃបានថយចុះ និងខូចរិចរិលក្នុងល្បឿនគួរឱ្យបារម្ភ (FAO 2005) ។ រឿងនេះធ្ងន់ធ្ងរណាស់ ពីព្រោះជនកម្ពុជាភាគច្រើន រស់នៅពឹងផ្អែកលើការប្រមូលផលិតផលព្រៃឈើ ។ គេត្រូវការឈើ និងបង្គោលឈើសំរាប់សាងសង់ផ្ទះ រកប្រាក់ចំណូល និងដោះស្រាយតំរូវការផ្សេងទៀត ។ អនុផលព្រៃឈើ ដូចជា អុស ជ័រឈើ និងសាច់សត្វព្រៃ បានចូលរួមចំណែកយ៉ាងច្រើនដល់ជីវភាពរស់នៅរបស់ប្រជាជននៅជនបទ ជាពិសេសនៅពេលពួកគេជួបនឹងវិបត្តិ (Heov *et al.* 2006) ។

របបគ្រប់គ្រងកាលពីមុនៗនៅកម្ពុជា មិនបានបញ្ឈប់ការខូចរិចរិល និងធានាឱ្យប្រជាជននៅជនបទទទួលបានប្រយោជន៍នោះទេ (IFSR 2004) ។ រឿងនេះធ្វើឱ្យគេយកចិត្តទុកដាក់កាន់តែច្រើនថា ការគ្រប់គ្រងព្រៃបែបវិមជ្ឈការ គឺជាវិធីសាស្ត្រមួយប្រសើរជាង ដោយយោងតាមបទពិសោធន៍អន្តរជាតិខាងការគ្រប់គ្រងព្រៃឈើផ្អែកលើសហគមន៍ (CBFM) ដូចជា នៅនេប៉ាល់ (Hobley 1996) និងឥណ្ឌា (Sundar 2001) ។ គេបានអះអាងថា CBFM គឺជាគំរូមានការទទួលស្គាល់ជាផ្លូវការតែមួយគត់នៃការគ្រប់គ្រងព្រៃបែបវិមជ្ឈការនៅកម្ពុជា ប៉ុន្តែនៅក្នុងទំរង់បច្ចុប្បន្ន CBFM មិនអាចចាត់ទុកថា មានលក្ខណៈវិមជ្ឈការពេញលេញបានទេ ពីព្រោះការ

* Iben Nathan (PhD) និង Tove Enggrob Boon (PhD) ជាអ្នកស្រាវជ្រាវជាន់ខ្ពស់នៃមជ្ឈមណ្ឌលព្រៃឈើ ទេសភាព និងផែនការនៃប្រទេសដាណឺម៉ាក (FLD) ។ អាន សុវត្ថា ជំនួយការស្រាវជ្រាវនៃ វបសអ កំពុងបន្តការសិក្សានៅ USA និង Kasper Hansen ជាទីប្រឹក្សាស្រាវជ្រាវ នៅ វបសអ ។ អត្ថបទនេះ ផ្អែកលើ កិច្ចសហការស្រាវជ្រាវរវាង វបសអ និង FLD ស្ដីពីការគ្រប់គ្រងព្រៃ បែបវិមជ្ឈការនៅកម្ពុជា ។

### មាតិកា

គួរឱ្យក្រុមប្រឹក្សាឃុំធ្វើជាអ្នកគ្រប់គ្រងព្រៃឈើ ........ ១
ការបង្កើតឧស្សាហៈនៃគណនេយ្យភាព : ករណីនៅកម្ពុជា ........ ៥
តើពាណិជ្ជកម្មសេរីជួយជំរុញការរីកចំរើនរឺទេ? ........ ៨
តាមដានសេដ្ឋកិច្ច — ស្ថានភាពក្រៅប្រទេស ........ ១១
— ស្ថានភាពក្នុងប្រទេស ........ ១៣
— សន្ទស្សន៍សេដ្ឋកិច្ច ........ ១៧
ព័ត៌មានថ្មីៗពី វបសអ ........ ២០

ត្រួតពិនិត្យមិនស្ថិតក្រោមការទទួលខុសត្រូវទាំងស្រុងរបស់ក្រុមសហគមន៍ព្រៃឈើទេ ហើយរដ្ឋបាលព្រៃឈើ (FA) នៅតែរក្សាសិទ្ធិអំណាចទាំងនេះ (Hobley and Boscolo 2004) ។

ក្នុងប៉ុន្មានឆ្នាំថ្មីៗ ការជជែកវែកញែកជាអន្តរជាតិ បានផ្តោតលើការដាក់បញ្ចូលការងារគ្រប់គ្រងធនធានធម្មជាតិទៅក្នុងរចនាសម្ព័ន្ធអាជ្ញាធរ មូលដ្ឋាន ។ ក្នុងនេះមានការយល់ឃើញដ៏សំខាន់មួយថា ប្រជាធិបតេយ្យ ភាវូបនីយកម្ម និងការគ្រប់គ្រងធនធានធម្មជាតិ អាចជួយពង្រឹងគ្នាទៅវិញទៅមកតាមរយៈការផ្ទេរអំណាច (e.g. Ribot 2004) ហើយការផ្ទេរអំណាចនេះ វាផ្តល់នូវមូលដ្ឋានគ្រឹះខាងស្ថាប័នដ៏រឹងមាំសំរាប់ការគ្រប់គ្រងធនធានធម្មជាតិផ្អែកលើសហគមន៍ ។ នៅពេលជាមួយគ្នា ក៏មានការយល់ដឹងជាទូទៅមួយថា ការផ្ទេរអំណាចមិនមែនសុទ្ធតែជាវិធីសាស្រ្ត អាចអនុវត្តបានជាក់ស្តែងរាល់ៗលើកនោះទេ (e.g. Larson 2003) ។

នៅកម្ពុជា និន្នាការនេះមានលើកឡើងក្នុងសំណើដែលមានការជជែកដេញដោលជាច្រើននៅក្នុងឯកសារត្រួតពិនិត្យព្រៃឈើឯករាជ្យ ក្នុងលក្ខណៈជាដៃគូខាងព្រៃឈើ ។ ភាពជាដៃគូខាងព្រៃឈើ ដែលគ្រោងនឹងធ្វើតាមទំរង់ជាផែនការព្រៃសហគមន៍ ត្រូវមានការអនុមតិពីរដ្ឋ ។ ក្រុមប្រឹក្សាឃុំមានភារកិច្ចអនុវត្តផែនការនេះ និងមានសិទ្ធិរក្សាទុកប្រើប្រាស់នូវសួយ និងកំរៃផ្សេងៗដែលប្រមូលបានពីធនធានធម្មជាតិ (IFSR 2004) ។ តួនាទីរបស់ក្រុមប្រឹក្សាឃុំសំខាន់ខ្លាំងណាស់ក្នុងកម្មវិធីទំហំ ៦០លានដុល្លាររបស់Danida-DFID សំរាប់លើកស្ទួយជីវភាពប្រជាជន ដែលនឹងដាក់អនុវត្តនៅ កម្ពុជាក្នុងឆ្នាំ២០០៦-១០ (Danida-DFID 2006) ។ រឿងនេះ ព្រមទាំង កំណែទំរង់រដ្ឋបាលបែបវិមជ្ឈការដែលបានផ្លាស់ប្តូរតួនាទី និងបង្កើនសារៈ សំខាន់នៃក្រុមប្រឹក្សាឃុំ (Rusten *et al.* 2004) បានបង្កើនភាពប្រាកដនិយមនៃកំណើនសិទ្ធិអំណាចក្រុមប្រឹក្សាឃុំទៅលើព្រៃឈើ នាថ្ងៃអនាគត ។

អត្ថបទនេះ មានគោលដៅវាយតំលៃពីតួនាទីសក្តានុពលនៃក្រុមប្រឹក្សាឃុំ ក្នុងឋានៈជាអ្នកគ្រប់គ្រងព្រៃឈើ ដោយពិនិត្យពីឧបសគ្គ និងឱកាសល្អចំបងៗ ដែលស្ថាប័ននេះនឹងជួបប្រទះ ប្រសិនបើពួកគេមានការទទួលខុសត្រូវច្រើនជាងមុនក្នុងការគ្រប់គ្រងព្រៃឈើ ។

ដោយសារក្រុមប្រឹក្សាឃុំ មានសិទ្ធិអំណាចតិចតួចពេកនាពេលបច្ចុប្បន្នក្នុងការគ្រប់គ្រងព្រៃឈើ និងមានតួនាទី ដែលបានគ្រោងឡើងសំរាប់ពេលអនាគតមិនសូវច្បាស់លាស់ ហេតុនេះគេមិនអាចវាយតំលៃបានទេ ពីតួនាទីជាក់លាក់ រឺបាន់ស្មានអ្វីមួយ ។ ដូច្នេះ អត្ថបទនេះនឹងលើកបង្ហាញពីបទពិសោធន៍ថ្មីៗនៃ CBFM និងការងារក្រុមប្រឹក្សាឃុំ ក្នុងឋានៈជាអ្នកគ្រប់គ្រងធនធានធម្មជាតិ តាមការសិក្សាឯកសារ និងតាមរបាយការណ៍របស់អ្នកឆ្លើយសំភាសន៍ក្នុងពេលចុះអង្កេតនៅតាមឃុំ[1] ។

## ឧបសគ្គ និងជំរើសសំរាប់ការគ្រប់គ្រងព្រៃឈើផ្អែកលើសហគមន៍

ឧបសគ្គ និងជំរើសសំរាប់ CBFM ដែលបានរកឃើញនៅពេលចុះអង្កេតតាមឃុំ វាកើតចេញពីកត្តា២ គឺ ១) គ្រឿងលើកទឹកចិត្ត និងគ្រឿងបង្អាក់ទឹកចិត្ត ដើម្បីឱ្យសហគមន៍គ្រប់គ្រងព្រៃឈើតាមរយៈក្រុមសហគមន៍ព្រៃឈើ និងក្រុមប្រឹក្សាឃុំ និង ២) ទំនាក់ទំនងរវាងក្រុមប្រឹក្សាឃុំ និងភាគីពាក់ព័ន្ធឯទៀតៗ ។

### *១. គ្រឿងលើកទឹកចិត្ត និងគ្រឿងបង្អាក់ទឹកចិត្តសំរាប់សហគមន៍ធ្វើការគ្រប់គ្រងព្រៃឈើ*

សហគមន៍ ជាទូទៅចាប់អារម្មណ៍ក្នុងការចូលរួមគ្រប់គ្រងព្រៃសហគមន៍ ដោយសារមានគ្រឿងលើកទឹកចិត្តមួយចំនួន ។ ទី១ ព្រៃឈើមានមុខងារជួយផ្គត់ផ្គង់ជីវភាព និងធ្វើជាសំណាញ់សុវត្ថិភាព ទោះបីវាជួយបានតិចតួចក្តី ដោយសារព្រៃសហគមន៍ភាគច្រើនមានគុណភាពទាប (សូមអាននៅខាងក្រោម) ។ ទី២ មានអ្នកឆ្លើយសំភាសន៍ CBFM ខ្លះដែរ ដែលសង្ឃឹមថានឹងទទួលបានផលប្រយោជន៍ទៅអនាគតជាឈើ និងសសរឈើ សំរាប់សាងសង់ផ្ទះសំបែង ។ ទី៣ ប្រហែលជាកត្តាសំខាន់ជាងគេ គឺសហគមន៍បានបញ្ជាក់ពីផលចំណេញនៃការបង្កើតទំនាក់ទំនងល្អជាមួយ NGO តាមរយៈ CBFM ដោយការរំពឹងថា NGO នឹងជួយគាំទ្រពួកគេក្នុងបញ្ហាផ្សេងទៀត ដូចជា ការផ្តួចផ្តើមបង្កើតសកម្មភាពសេដ្ឋកិច្ចបន្ថែមសំរាប់សហគមន៍ ។ ក្នុងករណីដោយឡែកមួយ សហគមន៍បានពន្យល់ថា ខាងកងទ័ព បានព្យាយាមបំពានយកព្រៃសហគមន៍ ។ ទំនាស់បានឈានដល់ការប្តឹងផ្តល់នៅតុលាការ ។ ដោយមានការជួយជ្រោមជ្រែងពី NGO សហគមន៍បានទទួលការគាំទ្រពីរដ្ឋបាលព្រៃឈើ ហើយបន្ទាប់មកក៏បានឈ្នះក្តី ។ ម្យ៉ាងទៀត ក្រុមអ្នកឆ្លើយសំភាសន៍ CBFM មួយចំនួនបានរាយការណ៍ថា ពួកគេបានចុះដើរល្បាតព្រៃសហគមន៍ហើយ ដោយសារពួកគាត់គិតឃើញពីសារៈសំខាន់ក្នុងការរក្សាធនធានព្រៃឈើសំរាប់អ្នកជំនាន់ក្រោយ ។ ដូចនេះ គេឃើញថាសហគមន៍ដែលឆ្លើយសំភាសន៍ គឺការយល់ដឹងខ្ពស់ពីបញ្ហាបរិស្ថាន ។

គ្រឿងបង្អាក់ទឹកចិត្តដ៏ចំបងមួយសំរាប់ CBFM នៅកម្ពុជាគឺ ព្រៃសហគមន៍មិនបានផ្តល់អត្ថប្រយោជន៍អ្វីច្រើនទេទៅឱ្យសហគមន៍ ។ ទី១ ក្រៅពីកំហិតដែលថា ព្រៃសហគមន៍អាចបង្កើតឡើងតែនៅក្នុងតំបន់ព្រៃផលិតកម្ម (RGC/CFO 2006) ក៏មានច្បាប់កំណត់ពីបរិមាណ រឺ គុណភាពព្រៃឈើ ដែលសហគមន៍អាចគ្រប់គ្រងបានផងដែរ ។ ប៉ុន្តែ ក្នុងការ អនុវត្តន៍ជាក់ស្តែង CBFM ភាគច្រើនបង្កើតឡើងតែនៅក្នុងព្រៃតូចៗ និងខូចរិចរិលរួចទៅហើយ (McKenney *et al.* 2004) ។ សមាជិកសហគមន៍ព្រៃឈើ ជាពិសេសអ្នកក្របំផុត បានប្រើប្រាស់សិទ្ធិរបស់ខ្លួន ដើម្បីប្រមូលអនុផលព្រៃឈើពីព្រៃសហគមន៍ ប៉ុន្តែពួកគេគិតថា ផលប្រយោជន៍នេះមិនសំខាន់ប៉ុន្មានទេ ។ សមាជិកសហគមន៍ព្រៃឈើមួយក្រុមបានឆ្លើយសំភាសន៍ថា ពួកគាត់ប្រមូលផលិតផលព្រៃឈើដែលគាត់ត្រូវការ មកពីព្រៃមានតំលៃខ្ពស់ដែលនៅជុំវិញព្រៃសហគមន៍ទៅវិញទេ ។

ទីពីរ អនុក្រិត្យស្តីពីព្រៃសហគមន៍ បានហាមឃាត់ការកាប់ឈើក្នុងរយៈពេល៥ឆ្នាំ ចំពោះក្រុមសហគមន៍ព្រៃឈើ (RGC 2003) ។ ការហាមឃាត់នេះ ត្រូវដាក់អនុវត្តចំពោះក្រុមនីមួយៗចាប់តាំងពីថ្ងៃចុះបញ្ជីជាផ្លូវការ ។ រឿងនេះ តំរូវឱ្យមានការអនុមតិជាផ្លូវការលើផែនការគ្រប់គ្រងព្រៃរបស់សហគមន៍ ដែលត្រូវស្របតាមគោលការណ៍ទូទៅមួយចំនួនរបស់រដ្ឋ ។ ដើម្បី ទទួលបានការអនុមតិពីក្រសួង គេអាចត្រូវចំណាយពេលអស់ច្រើនណាស់ ។ មន្ត្រីឆ្លើយសំភាសន៍មានការបារម្ភថា ពេលត្រូវរង់ចាំដ៏យូរ និងការហាមឃាត់កាប់ឈើរយៈ ៥ឆ្នាំ នឹងបង្អាក់ទឹកចិត្តក្រុមសហគមន៍ព្រៃឈើ ពីព្រោះវារារាំងពួកគាត់មិនឱ្យទទួលបានផលប្រយោជន៍ពីការប្រឹងប្រែងគ្រប់គ្រង ។

ទីបី លំហូរផលប្រយោជន៍នៅថ្ងៃអនាគតក៏មិនទាន់ច្បាស់លាស់ដែរ ដោយសារច្បាប់ស្តីពីសិទ្ធិកាន់កាប់ និងការបែងចែកផលប្រយោជន៍ មានភាពមិនច្បាស់លាស់ ។ ដរាបណាក្រុមសហគមន៍ព្រៃឈើនៅតែមិនទាន់បានចុះ

បញ្ជីជាផ្លូវការ ពួកគេនៅតែមិនអាចទទួលបានដីព្រៃ ដែលជាកម្មសិទ្ធិរបស់រដ្ឋទេ ។ បច្ចុប្បន្ន សហគមន៍ព្រៃឈើប្រហែល ៥០% មានឯកសារស្របច្បាប់ប៉ុន្តែបទប្បញ្ញត្តិនៅតែមិនទាន់ច្បាស់លាស់ស្តីពីការបែងចែកផលប្រយោជន៍ រវាងសហគមន៍ និងរដ្ឋាភិបាល (Vatanak and Leakhena 2005) ។

នៅមូលដ្ឋាន គេយល់ថា បញ្ហាចោទធំមួយ គឺប្រជាជនមិនអាចឆ្លៀតពេលដើរល្បាតតំបន់ព្រៃសហគមន៍ ។ ឧទាហរណ៍ មានគណៈកម្មាធិការមួយនៃ CBFM បានប្រគល់ការងារដើរល្បាតឱ្យទៅ ១៥គ្រួសារក្រីក្រ ប៉ុន្តែពួកគេមានពេលវេលាតិចតួចសំរាប់ធ្វើការងារនេះ ពីព្រោះជាការងារគ្មានប្រាក់បៀវត្សរ៍ ។ ក្នុងករណីដែលមិនសូវមានការផ្តល់ផលប្រយោជន៍ច្រើន សហគមន៍ព្រៃឈើហាក់ដូចបានបង្កើនបន្ទុកការងារចំពោះអ្នកក្រីក្រ ជាជាងជួយសំរាលដល់ជីវភាពរស់នៅរបស់ពួកគេ ។

ចំពោះក្រុមប្រឹក្សាឃុំ ព្រៃសហគមន៍មានលក្ខណៈបង្អាក់ទឹកចិត្តទៅវិញ ហើយពួកគេកំផ្តល់អាទិភាពដល់ការគ្រប់គ្រងធនធានធម្មជាតិណាស់នៅក្នុងផែនការអភិវឌ្ឍន៍ ពីព្រោះផលប្រយោជន៍បានពីគំរោងគ្រប់គ្រងធនធានធម្មជាតិ វាមិនលេចធ្លោដូចខាងគំរោងហេដ្ឋារចនាសម្ព័ន្ធទេ ។ សមាជិកក្រុមប្រឹក្សាឃុំ តែងចង់បានលទ្ធផលដែលម្ចាស់ឆ្នោតអាចមើលឃើញយ៉ាងច្បាស់ ។

## ***២. កំហិត និងជំរើសនៅក្នុងទំនាក់ទំនងរវាងក្រុមប្រឹក្សាឃុំ និងភាគីឯទៀត***

តាមមតិរបស់ក្រុមប្រឹក្សាឃុំ តួអង្គសំខាន់ៗក្នុងការគ្រប់គ្រងព្រៃឈើ រួមមានប្រជាជនក្នុងសហគមន៍ អ្នកខាងក្រៅដែលអាចប្រើប្រាស់ព្រៃឈើ ស្ថាប័នរដ្ឋជាន់ខ្ពស់ អង្គការផ្តល់ជំនួយ និង NGOs (សូមអាន Hobley 2004) ។

### ***២.១. ការដោះស្រាយជាមួយតួអង្គមានអំណាច និងមិនសូវមានអំណាចទាំងខាងក្នុង និងខាងក្រៅ***

ទោះបីព្រៃឈើត្រូវបានគ្រប់គ្រងដោយក្រុម CBFM រឺក្រុមប្រឹក្សាឃុំក្តី ត្រូវមានសេចក្តីថែងច្បាស់លាស់ពីសិទ្ធិអំណាចរបស់អាជ្ញាធរថ្នាក់ខេត្ត និងថ្នាក់ជាតិ ព្រមទាំង "ច្បាប់មានកំលាំងអាជ្ញា" ដើម្បីគាំទ្រដល់ការគ្រប់គ្រង និងការដាក់អនុវត្តន៍ច្បាប់នៅមូលដ្ឋាន កាត់បន្ថយសកម្មភាពខុសច្បាប់ និងផ្តល់សិទ្ធិស្របច្បាប់ដល់អ្នកនៅជនបទ (សូមអាន Marona *et al.* 2005) ។

ក្រុម CBFM ជាច្រើន ជួបបញ្ហាធ្ងន់ធ្ងរជាមួយអ្នកខាងក្រៅមានអំណាចខ្លាំង និងអ្នកខាងក្នុងខ្លះៗដែរ ។ តាមធម្មតាក្រុម CBFM មិនអាចធ្វើអ្វីបានច្រើនទេ បើសិនខាងកងទ័ព រឺអ្នកខាងក្រៅផ្សេងទៀត បំពានចូលទៅក្នុងព្រៃសហគមន៍ ហើយទាមទារយកដីនោះ រឺបើសិនមានទំនាស់ស្តីពីព្រំដែនព្រៃសហគមន៍ ដែលមិនអាចដោះស្រាយបានតាមរយៈការចរចា ។ រឿងនេះមានចោទឡើងដូចគ្នាចំពោះបញ្ហាឯទៀត ដូចជាការទន្ទ្រានយកដី និងការកាប់ឈើខុសច្បាប់ ទោះបីជាជនល្មើសជាអ្នកខាងក្រៅ រឺអ្នកខាងក្នុងសហគមន៍ក្តី ។ ក្រុម CBFM គ្មានសិទ្ធិអំណាចចាប់ខ្លួនជនល្មើស រឺចាត់វិធានការអ្វីផ្សេងដើម្បីតទល់នឹងអ្នកទាំងនោះទេ (សូមអាន Vatanak and Leakhena 2005) ។

បើប្រៀបធៀបនឹងក្រុម CBFM ក្រុមប្រឹក្សាឃុំមានលក្ខណៈអំណោយផលជាងក្នុងការងារដោះស្រាយទំនាស់ ពីព្រោះពួកគេអាចសហការជាមួយប៉ូលីសដើម្បីចាប់ខ្លួនជនល្មើសបាន ។ ពួកគេមានសិទ្ធិអំណាចធ្វើការសំរុះសំរួលទំនាស់រវាងប្រជាជនក្នុងឃុំ ហើយពួកគេមានស្ថានភាពរឹងប៉ឹងល្អ ពីព្រោះវាជាការងារជាប្រពៃណីរបស់ពួកគេ ។ ប៉ុន្តែក្រុមប្រឹក្សាឃុំនៅខ្សោយជាង បើធៀបនឹងអ្នកខាងក្រៅ ដូចជាខាងកងទ័ពជាដើម ហើយមិនអាចតទល់ជាមួយពួកនេះ ដោយគ្មានការគាំទ្រពីតួអង្គខ្លាំងៗឯទៀតឡើយ ។ ម្យ៉ាងទៀត ក្រុមប្រឹក្សាឃុំ ក៏មិនអាចដោះស្រាយទំនាស់ទាក់ទិននឹងភូមិឯទៀត ដូចជាទំនាស់ព្រំដែនជាដើម ពីព្រោះពួកគេមិនអាចតទល់នឹងអ្នក ឋានៈខ្ពស់នៅក្នុងមូលដ្ឋាន និងមិនសូវដឹងច្បាស់ពីច្បាប់ ។

បទពិសោធន៍ពីប្រទេសផ្សេងៗបង្ហាញថា មានទិដ្ឋភាពជាច្រើនទៀតនៃទំនាក់ទំនងរវាងក្រុមប្រឹក្សាឃុំ និងប្រជាជនមូលដ្ឋាន ដែលមានសារៈសំខាន់ណាស់ ។ អ្នកស្រាវជ្រាវខ្លះ បានអះអាងថា សហគមន៍មូលដ្ឋានច្រើនសំបូរ ទៅដោយទំនាស់ផលប្រយោជន៍ផ្ទៃក្នុង ហើយងាយធ្លាក់ក្រោមការក្តោបក្តាប់របស់ពួកអ្នកឋានៈខ្ពស់នៅមូលដ្ឋាន (e.g. Agrawal and Gibson 1999) ។ អ្នកស្រាវជ្រាវជាច្រើនទៀតអះអាងថា សូម្បីតែអាជ្ញាធរមូលដ្ឋាន ដែលមានគណនេយ្យភាពចំពោះថ្នាក់ក្រោម និងជាតំណាងល្អឥតខ្ចោះ ក៏នៅតែអាចមើលរំលងប្រយោជន៍ប្រជាជនភាគតិចដែរ (Wunder 2001) ។ បើសិនមានចំណេញ អ្នកធ្វើសេចក្តីសំរេចចិត្តជាសមូហភាព តែងព្យាយាមធ្វើអាជីវកម្មលើធនធានធម្មជាតិជាជាងអភិរក្សវា ជាពិសេសបើសិនពួកគេមិនត្រូវទទួលរ៉ាប់រងបន្ទុកចំណាយជាប្រយោលនៃការខូចចិរចិលធនធានធម្មជាតិទេនោះ ។ រឿងបែបនេះនឹងកើតឡើង ឧទាហរណ៍បើសិនសហគមន៍ទាំងមូល បានទទួលផលប្រយោជន៍ច្រើនពីការធ្វើអាជីវកម្មហួសកំរិត រឺនៅពេលមានតំរូវការបច្ចុប្បន្នជាបន្ទាន់ ហើយផលវិបាក និងបន្ទុកចំណាយនៃការធ្វើអាជីវកម្មវាផុសឡើងនៅពេលក្រោយ (Ribort 2004, Larson 2003) ។

### ***២.២. ការដោះស្រាយជាមួយស្ថាប័នរដ្ឋថ្នាក់ខ្ពស់ អ្នកផ្តល់ជំនួយ និង NGOs***

នៅកម្ពុជា បញ្ហាមួយនៃការអនុវត្តន៍វិមជ្ឈការ និងគោលដៅនានារបស់វាឱ្យបានសំរេចគឺ មន្ត្រីរាជការ និងអ្នកនយោបាយថ្នាក់មូលដ្ឋាន មិនសូវមានសមត្ថភាពអនុវត្តការងារដ៏ចាំបាច់នានាទេ (Turner 2002) ។ ក្រុមប្រឹក្សាឃុំទើបបានដំណើរការថ្មីៗ ពីព្រោះការបោះឆ្នោតឃុំលើកទី១ធ្វើឡើងនៅឆ្នាំ ២០០២ ។ ក្នុងនេះ អ្នកធ្លាប់ធ្វើជាមេភូមិ មិនអាចឈរឈ្មោះបោះឆ្នោតបានទេ ដូច្នេះសមាជិកក្រុមប្រឹក្សាឃុំភាគច្រើន ពុំសូវមានបទពិសោធន៍ ។ ម្យ៉ាងទៀតក្រុមប្រឹក្សាឃុំខ្វះខាតខាងហិរញ្ញវត្ថុ (Rusten *et al.* 2004) ហើយសិទ្ធិអំណាចលើព្រៃឈើ និងធនធានធម្មជាតិដទៃទៀត គឺថ្នាក់ខេត្តជាអ្នកក្តោបក្តាប់ជាក់ស្តែង (Oberndorf 2004) ។ ជាលទ្ធផល ក្រុមប្រឹក្សាឃុំមិនបានចាត់ទុកការគ្រប់គ្រងព្រៃឈើថាជាការងារចំបងមួយរបស់ខ្លួនទេ ។

ចំពោះទំនាក់ទំនងរវាងក្រុមប្រឹក្សាឃុំ និងខេត្ត ក្របខ័ណ្ឌច្បាប់បច្ចុប្បន្នសំរាប់អាជ្ញាធរមូលដ្ឋាន មិនបានផ្តល់ឯករាជ្យភាពច្រើនទៅឱ្យក្រុមប្រឹក្សាឃុំទេ ។ ថ្នាក់ខេត្ត មានសិទ្ធិអំណាចចំបងលើព្រៃឈើ និងធនធានធម្មជាតិដទៃទៀត (Oberndorf 2004) ។ យោងតាមទ្រឹស្តី រឿងនេះជាបញ្ហាចោទមួយ ពីព្រោះការគ្រប់គ្រងព្រៃឈើមានប្រសិទ្ធភាព និងសមធម៌ ទាមទារការផ្ទេរសិទ្ធិអំណាចច្រើនទៅឱ្យឃុំ (e.g. Ribot 2004) ។ បើចង់ឱ្យក្រុមប្រឹក្សាឃុំចូលពាក់ព័ន្ធកាន់តែច្រើនក្នុងការគ្រប់គ្រងព្រៃឈើ គេត្រូវដោះស្រាយស្ថានភាពបច្ចុប្បន្នដែលពួកគេខ្វះស្វ័យភាព ។

ពាក់ព័ន្ធនឹងទំនាក់ទំនងរវាង FA និងក្រុម CBFM រឺក្រុមប្រឹក្សាឃុំ FA បានទទួលស្គាល់ថា គេមានផលចំណេញច្រើនយ៉ាងដើម្បីផ្ទេរការទទួលខុសត្រូវគ្រប់គ្រងព្រៃទៅឱ្យក្រុម CBFM ជាពិសេសសំរាប់ព្រៃដែលពុំមានតំលៃ ។ វិធីនេះជំរុញឱ្យក្រុមសហគមន៍ព្រៃឈើ ធ្វើការយាមល្បាត

ដីព្រៃរិចរិលរបស់រដ្ឋ ដើម្បីធានាការដុះឡើងវិញរបស់ដើមឈើ ដោយមិនបានទទួលប្រាក់បៀវត្សរ៍ រឺផលប្រយោជន៍អ្វីធំដុំឡើយ ។ ពួកគេជួយសំរាលការងាររបស់ FA ដែលកំពុងខ្វះខាតបុគ្គលិក ដោយ FA មិនបាច់ចំណាយប្រាក់ រឺបាត់បង់បុព្វសិទ្ធិអ្វីទេ ។ លើសពីនេះ ក្រុម CBFM និងក្រុមប្រឹក្សាឃុំ គឺជាវេទិកាផ្ដល់ការងាយស្រួលឱ្យ FA ធ្វើការប្រាស្រ័យទាក់ទងជាមួយអ្នកភូមិ ដូចជា ដើម្បីផ្សព្វផ្សាយព័ត៌មានអំពីវិធាននិងបទប្បញ្ញត្តិរបស់ FA បង្កើនការយល់ដឹងពីបរិស្ថាន និងយន្ដការគ្រប់គ្រងបរិស្ថានជាដើម ។ម្យ៉ាងវិញទៀត បុគ្គលិក FA ដែលឆ្លើយសំភាសន៍ ហាក់ដូចមិនសូវចង់ផ្ទេរសិទ្ធិអំណាចទៅឱ្យអាជ្ញាធរមូលដ្ឋានទេ ហើយចំនុចនេះជាឧបសគ្គធ្ងន់ធ្ងរមួយក្នុងការគ្រប់គ្រងព្រៃតាមបែបវិមជ្ឈការឱ្យបានជោគជ័យ ។ ដូច្នេះ គេត្រូវពង្រឹងសិទ្ធិអំណាចក្រុមប្រឹក្សាឃុំក្នុងការពាក់ព័ន្ធជាមួយស្ថាប័នរដ្ឋជាន់ខ្ពស់ ប៉ុន្ដែក៏ត្រូវជួយឱ្យក្រុមប្រឹក្សាឃុំ មានសមត្ថភាពអនុវត្តសិទ្ធិអំណាចនេះដែរ ។

អង្គការផ្ដល់ជំនួយ និង NGOs មានតួនាទីសំខាន់ដោយផ្ទាល់ និងដោយប្រយោលនៅក្នុង CBFM នៅកម្ពុជា ។ CBFM ពិបាកនឹងកើតមានឡើងដោយគ្មានការចូលរួមពី NGO រឺទីភ្នាក់ងារផ្ដល់ជំនួយជាតិ និងអន្ដរជាតិណាស់ ។ កម្មវិធីសិលា គាំទ្រដោយអ្នកផ្ដល់ជំនួយ បានផ្ដល់ការគាំទ្រខាងរដ្ឋបាលតាមរយៈ ក្រុមសំរបសំរួលស្រុកនិងខេត្តដែលដាក់បញ្ចូលអាទិភាពនានានៃការគ្រប់គ្រងធនធានធម្មជាតិនិងបរិស្ថាន និងបញ្ហាបារម្ភផ្សេងទៀតទៅក្នុងគ្រប់វិស័យរបស់ឃុំ ព្រមទាំងជួយសំរបសំរួលដល់សិក្ខាសាលាថ្នាក់ខេត្តជាទៀងទាត់ ។ នៅក្នុងសិក្ខាសាលានេះ តំណាងមកពី ក្រុមប្រឹក្សាឃុំ ក្រុម CBFM ប៉ូលិសទាហ៊ាន និងភាគីពាក់ព័ន្ធឯទៀត ជួបពិភាក្សាគ្នាលើបញ្ហាជាច្រើន ។ NGO ដែលពាក់ព័ន្ធនឹងសកម្មភាព CBFM បានផ្ដល់ការគាំទ្រជាញឹកញាប់ដល់ឃុំតាមមធ្យោបាយផ្សេងៗ ដូចជាតាមរយៈការជួយគាំទ្រដល់ក្រុម CBFM ដែលមានទំនាស់ជាមួយអ្នកខាងក្រៅដ៏មានអំណាច ។ រឿងដែលល្អគឺ NGO មានវត្តមានជាញឹកញាប់ និងមានបំណងជួយគាំទ្រ ។ រឿងមិនល្អ គឺប្រសិនបើអង្គភាពវិមជ្ឈការមានការពឹងផ្អែកខ្លាំងពេកទៅលើជំនួយគាំទ្ររបស់ NGO និងអ្នកផ្ដល់ជំនួយ វិធីសាស្ត្រនេះ នឹងមិនអាចមានចីរភាពទេ ។

អ្នកឆ្លើយសំភាសន៍មួយចំនួនបានលើកឡើងថា ផែនការគ្រប់គ្រងដែលមានចែងនៅក្នុងគោលការណ៍ណែនាំថ្មីស្ដីពីសហគមន៍ព្រៃឈើ វាមានលក្ខណៈបច្ចេកទេសស្មុគស្មាញពេកសំរាប់ក្រុម CBFM និងក្រុមប្រឹក្សាឃុំ ហើយអាចរាំងស្ទះការអនុវត្តន៍ CBFM និងកាត់បន្ថយការផ្ដល់សិទ្ធិអំណាចទៅឱ្យក្រុម CBFM និងក្រុមប្រឹក្សាឃុំ ។ ចំនុចគ្រោះថ្នាក់គឺ ពួកគេកាន់តែពឹងផ្អែកខ្លាំងឡើងទៅលើជំនួយគាំទ្ររបស់ NGO និងយោបល់បច្ចេកទេសពី FA សំរាប់ការធ្វើផែនការគ្រប់គ្រប់ព្រៃឈើ និងការដាំព្រៃយ៉ាងសកម្ម ។ នៅពេលជាមួយគ្នា FA ក៏ខ្វះសមត្ថភាព (បុគ្គលិក និងជំនាញ) ដើម្បីផ្ដល់ជំនួយបច្ចេកទេសដល់ក្រុម CBFM ដែរ ។

## គោលគំនិតឱ្យក្រុមប្រឹក្សាឃុំធ្វើជាអ្នកគ្រប់គ្រងព្រៃឈើ៖ កិច្ចពិភាក្សា និងសេចក្ដីសន្និដ្ឋាន

តើក្រុមប្រឹក្សាឃុំនៅកម្ពុជាអាចទទួលខុសត្រូវច្រើនជាងមុនរឺទេ លើការគ្រប់គ្រងព្រៃឈើ? បទពិសោធន៍ពីក្រុមសហគមន៍ព្រៃឈើបង្ហាញថា ការគ្រប់គ្រងដោយសហគមន៍អាចទទួលបានជោគជ័យ លុះត្រាតែវាមានផ្ដល់ផលប្រយោជន៍ច្រើន និងជាក់ស្ដែងដល់ថ្នាក់មូលដ្ឋាន ទោះបីអ្នកទទួលខុសត្រូវធ្វើការគ្រប់គ្រងជាក្រុម CBFM រឺក្រុមប្រឹក្សាឃុំក្ដី ។ រឿងនេះតំរូវឱ្យ (១) ផ្ទេរមិនត្រឹមតែព្រៃរិចរិលនោះទេ ប៉ុន្ដែថែមទាំងព្រៃមានតំលៃផងដែរឱ្យទៅសហគមន៍ និង (២) ដាក់អនុវត្តបែបបទកំណត់ឱ្យសហគមន៍ទទួលបានជាផ្លូវការនូវផលប្រយោជន៍សំខាន់ៗ និងជាក់ស្ដែងពីវិធីសាស្ត្រគ្រប់គ្រងព្រៃមានចីរភាព ដូចជា តាមរយៈការធានាសិទ្ធិឱ្យសហគមន៍អាចប្រមូល និងលក់ឈើនិងផលិតផលព្រៃឈើមានតំលៃផ្សេងៗទៀត ដោយបង្កើនតំលៃបន្ថែមនៅមូលដ្ឋាន និងកែលំអម៉ាឃីតទីផលិតផលព្រៃឈើវីក៏ផ្ដល់កំរៃឱ្យប្រជាជនមូលដ្ឋាន សំរាប់ការជួយការពារព្រៃដែលពួកគេមិនអាចទាញយកផលប្រយោជន៍បាន ។ ចំនុចដ៏ចាំបាច់មួយគឺ ក្រុមប្រឹក្សាឃុំត្រូវមានលទ្ធភាពដោះស្រាយជាមួយអ្នកមានអំណាច (និងអ្នកមិនសូវមានអំណាច) ទាំងមកពីខាងក្រៅ និងពីខាងក្នុង ។ នេះជារឿងសំខាន់ ប៉ុន្ដែក៏មានលក្ខណៈរសើបខាងនយោបាយដែរ ពីព្រោះវាតំរូវឱ្យមានការបែងចែកឡើងវិញនូវសិទ្ធិអំណាច និងធនធានទៅឱ្យក្រុមប្រឹក្សាឃុំ ។ ជំនួយគាំទ្រដ៏ច្រើនទៅដល់ក្រុមប្រឹក្សាឃុំ ដូចជា គំរោងរបស់អ្នកផ្ដល់ជំនួយជាដើម អាចជួយឱ្យពួកគេបង្កើនសមត្ថភាពដោះស្រាយបញ្ហាផ្សេងៗ ប៉ុន្ដែគេមិនសូវសង្ឃឹមថា វាអាចកែប្រែស្ថានភាពបាននោះទេ ប្រសិនបើក្នុងពេលជាមួយគ្នាគេមិនបានយកចិត្តទុកដាក់ខ្លាំងដល់ការគ្រប់គ្រងនៅថ្នាក់ជាតិ និងទំនាក់ទំនងការងាររវាងថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ ។

ម្យ៉ាងទៀត មុនពេលលុបបំបាត់តួនាទី FA ទាំងស្រុងក្នុងការគ្រប់គ្រងព្រៃបែបវិមជ្ឈការ គេគួរពិចារណាថា អង្គភាពគ្រប់គ្រងព្រៃដែលនៅទន់ខ្សោយ ដូចជា ក្រុម CBFM និងក្រុមប្រឹក្សាឃុំ នៅតែត្រូវការជំនួយបច្ចេកទេសពីប្រព័ន្ធ FA ។ ពួកគេក៏ត្រូវការជំនួយគាំទ្រក្នុងការដោះស្រាយបញ្ហាផងដែរ ដូចជាការទាមទារខុសច្បាប់របស់អ្នកបំពានមកពីខាងក្រៅ និងទំនាស់រវាងឃុំ ។ ដូច្នេះចំនុចសំខាន់គឺ មិនត្រូវរំលង FA ទាំងស្រុងទេក្នុងការគ្រប់គ្រងព្រៃបែបវិមជ្ឈការ ពីព្រោះវាអាចចោទបញ្ហាធ្ងន់ធ្ងរដល់ក្រុមប្រឹក្សាឃុំ ។

ការរៀបរាប់ខាងលើអំពីឧបសគ្គ និងឱកាសល្អនៃការគ្រប់គ្រងព្រៃបែបវិមជ្ឈការនៅកម្ពុជា នៅមិនទាន់គ្រប់ជ្រុងជ្រោយទេ ពីព្រោះវាផ្អែកជាសំខាន់លើកិច្ចសំភាសន៍ជាមួយមនុស្សមួយចំនួនតូច និងប្រើពេលវេលាមានកំណត់ ។ ទិដ្ឋភាពខ្លះទៀត ជាពិសេសគឺទំហំនៃការក្ដោបក្ដាប់របស់អ្នកមានឋានៈខ្ពស់ និងរចនាសម្ព័ន្ធអំណាចនៅមូលដ្ឋាន និងថ្នាក់ជាតិ នឹងត្រូវលើកមកពិនិត្យនៅក្នុងការស្រាវជ្រាវបន្ថែមទៀតស្ដីពីការគ្រប់គ្រងព្រៃបែបវិមជ្ឈការ ។

គេអាចសន្និដ្ឋានថា យុទ្ធសាស្ត្រគ្រប់គ្រងព្រៃបែបវិមជ្ឈការហាក់មានលក្ខណៈល្អប្រសើរ និងមានជំរើសច្រើនសំរាប់ឱ្យប្រព័ន្ធគ្រប់គ្រងព្រៃបែបវិមជ្ឈការអនុវត្តបានងាយជាងប្រព័ន្ធគ្រប់គ្រងមុន ដើម្បីឱ្យការគ្រប់គ្រងព្រៃមានចីរភាព និងផ្ដល់ប្រយោជន៍ដល់ប្រជាជននៅជនបទ ។ ស្របពេលជាមួយគ្នា គេគួរយកចិត្តទុកដាក់ច្រើនថែមទៀត លើតួនាទីរដ្ឋាភិបាលក្នុងការបង្កើតបរិយាកាសនយោបាយ និងក្របខ័ណ្ឌច្បាប់ ដែលអំណោយផលដល់អង្គភាពគ្រប់គ្រងព្រៃបែបវិមជ្ឈការ ។ គេក៏គួរបង្កើនការយកចិត្តទុកដាក់លើការកែលំអទំនាក់ទំនងការងាររវាងថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ ផងដែរ ។ ទិដ្ឋភាពទាំងនេះ អាចសំខាន់ប៉ុនគ្នា រឺច្រើនជាង ការកែលំអធនធានមនុស្ស

*តទៅទំព័រទី ១០*

# ការបង្កើតទស្សនៈនៃគណនេយ្យភាព៖ ករណីនៅកម្ពុជា

លោក ហ៊ីង វុទ្ធី ពិភាក្សាពីទស្សនៈនៃគណនេយ្យភាពក្នុងវិស័យសាធារណៈ ដោយយោងតាមគំរូនៃប្រទេសលោកខាងលិច និងក្នុងបរិបទនៃការអនុវត្តន៍អភិបាលកិច្ចនៅកម្ពុជា ។*

## កិច្ចប្រឹងប្រែងធ្វើកំណែទំរង់របស់រដ្ឋាភិបាល និងចំណងទាក់ទងជាមួយគណនេយ្យភាព

គណនេយ្យភាពក្នុងវិស័យសាធារណៈ បានក្លាយជាក្តីបារម្ភយ៉ាងធំរបស់រដ្ឋាភិបាលកម្ពុជា និងសហគមន៍អ្នកផ្តល់ជំនួយក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ដោយគេឃើញមានលើកឡើងកាន់តែញឹកញាប់នៅក្នុងរបាយការណ៍របស់រដ្ឋាភិបាលសុន្ទរកថាផ្លូវការ និងរបៀបវារៈរបស់អ្នកផ្តល់ជំនួយទាក់ទិននឹងអភិបាលកិច្ចល្អ ការកាត់បន្ថយភាពក្រីក្រ វិមជ្ឈការ និងការអភិវឌ្ឍន៍បែបប្រជាធិបតេយ្យ ។ ជាទ្រឹស្តី គណនេយ្យភាពត្រូវមានជាចាំបាច់ ដើម្បីអាចផ្តល់សេវាមានចីរភាព និងកាត់បន្ថយភាពក្រីក្រ ហើយត្រូវដាក់បង្កប់នៅក្នុងគោលនយោបាយ និងការអនុវត្តន៍ ។ ការបង្កើត និងអនុវត្តន៍គោលនយោបាយស្តីពីការផ្តល់សេវា ជាដំណើរការនយោបាយ និងការរៀបចំផ្នែកបច្ចេកទេស ។ ហេតុនេះ ការសំរេចបានគណនេយ្យភាព និង-ជោគជ័យនៃការផ្តល់សេវាអំណោយផលដល់អ្នកក្រ តំរូវឱ្យមានការយល់ដឹងពីបច្ចេកទេស និង ដំណើរការនយោបាយជាក់ស្តែង ។ ប៉ុន្តែកង្វះការយល់ដឹងពីបរិបទនៃ គណនេយ្យភាព នាំឱ្យមានភាពមិនស៊ីសង្វាក់គ្នា និងភាពជាម្ចាស់មិនច្បាស់លាស់របស់រដ្ឋាភិបាលក្នុងការបង្កើត និងអនុវត្តន៍គោលនយោបាយស្តីពីការផ្តល់សេវាអំណោយផលដល់អ្នកក្រ ។ នៅគ្រប់លំដាប់ថ្នាក់ក្នុងជួររដ្ឋាភិបាល គេរកឃើញភាពស៊ីគ្នាមួយ គឺមន្ត្រីភាគច្រើន តែងបកស្រាយពាក្យគណនេយ្យភាពទៅតាមបរិបទការងាររបស់ខ្លួន ដោយមានយោងតិចតួច រឺគ្មានសោះទៅដល់អត្ថន័យស្តង់ដារមានឯកសារបញ្ជាក់របស់ពាក្យនេះ (មានឯកសារជិតបោះផ្សាយមួយរបស់ វិបសអ) ។ តំរូវការកសាងយន្តការគណនេយ្យភាពអំណោយផលដល់អ្នកក្រ វាកាន់តែស្រួចស្រាវឡើងក្នុងបរិបទអភិបាលកិច្ចដូចនៅកម្ពុជា ដែលអត្ថបទនេះនឹងពិពណ៌នាថា ជារបបមេកើយ-កូនចៅសម័យថ្មី ហើយដែល Brinkerhoff and Goldsmith (2002: 40) បានកំនត់និយមន័យថា ជា "ប្រព័ន្ធចំរុះនៃការគ្រប់គ្រងរបស់រដ្ឋាភិបាល ដែល-មាន ស្រទាប់លើសមហេតុផលល្អ-និងស្របច្បាប់ នៅគ្របពីលើចំណងទាក់ទង ស្នេកស្នេះតាមបែបបុគ្គល ដែល-ជាចរិតលក្ខណៈនៃការគ្រប់គ្រងរបៀបមេកើយ-កូនចៅ" ។

ដើម្បីស្វែងយល់ពីគណនេយ្យភាព ត្រូវធ្វើការវិភាគថ្លឹងថ្លែងផ្តោតលើ (ក) ទំនាក់ទំនងរវាងតួអង្គនីមួយៗ និង (ខ) រចនាសម្ព័ន្ធ និងប្រព័ន្ធ ដែលជួយជំរុញ និងរារាំងដល់តួអង្គ និងគណនេយ្យភាពរបស់ពួកគេ ។ គណនេយ្យភាពផ្តោតលើស្ថាប័ន សំដៅដល់គណនេយ្យភាពរបស់អ្នកណាចំពោះអ្នកណា និងសំរាប់អ្វី ដែលជារឿយៗ នាំឱ្យមានទំនាក់ទំនងតគ្នារវាងបុគ្គលឋានៈទាប និងបុគ្គលឋានៈខ្ពស់ ។ ប៉ុន្តែអត្ថបទនេះបានវែកញែកថា គណនេយ្យភាពវាស្មុគស្មាញ ជាងរឿងតួអង្គពីរនាក់ដែលចាប់គ្នាឱ្យទទួលខុសត្រូវទៅវិញទៅមកនោះទៀត ។ គណនេយ្យភាពក៏បានកំណត់ឡើងដោយផ្អែកលើបែបបទ ដែលប្រព័ន្ធអភិបាលកិច្ចធំទូលាយ (រួមមានសកម្មភាពនយោបាយ និងបច្ចេកទេស) វាជះឥទ្ធិពលទៅលើឥរិយាបថ និងការយល់ឃើញរបស់តួអង្គទាំងនេះ ។ ឧទាហរណ៍ ការយល់ឃើញថា បញ្ហារដ្ឋបាលអាចដោះស្រាយបានសក្តិសិទ្ធិជាង តាមរយៈទំនាក់ទំនងបុគ្គលច្រើនតែក្លាយជាការអនុវត្តន៍ជាក់ស្តែង និងបង្កើតការមិនទុកចិត្តគ្នានៅក្នុងមុខងារការិយាល័យជាផ្លូវការ ។ សំរាប់កម្ពុជាដែលជាប្រទេសមានប្រពៃណីនៃទំនាក់ទំនងមេកើយ-កូនចៅ ការយល់ដឹងពី បែបបទដែលការចរចាក្រៅផ្លូវការ និងបណ្តាញខាងនយោបាយ វាជះឥទ្ធិពលដល់ទំនាក់ទំនង និងរចនាសម្ព័ន្ធអភិបាលកិច្ចផ្លូវការ គឺសំខាន់ខ្លាំងណាស់សំរាប់អ្នកធ្វើកំណែទំរង់គោលនយោបាយ និងអ្នកអនុវត្ត ។ តើវត្តមានប្រព័ន្ធមេកើយ-កូនចៅ សម័យថ្មី វាធ្វើឱ្យរលាយចូលគ្នាបែបណានូវរបៀបរបបអភិបាលកិច្ចផ្លូវការ និងក្រៅផ្លូវការ ដើម្បីជះឥទ្ធិពលដល់គណនេយ្យភាព? អត្ថបទនេះ ផ្តោតលើលក្ខណៈក្រៅផ្លូវការខាងលើ ដោយស្វែងយល់ពីវប្បធម៌យូរលង់នៅកម្ពុជានៃបណ្តាញមេកើយ-កូនចៅ ព្រមទាំងធ្វើការស្រាយបង្ហាញថា តើក្នុងពេលថ្មីៗបណ្តាញនេះបានប្រទាក់ក្រឡាយ៉ាងដូចម្តេចជាមួយនឹងប្រព័ន្ធការិយាធិបតេយ្យសមហេតុផល ។

យោងតាមវិធីសាស្ត្រខាងលើ អត្ថបទនេះមានគោលដៅពីរ គឺ (១) បង្កើនការយល់ដឹងពីគណនេយ្យភាព និង (២) ជួយអ្នករដ្ឋបាលសាធារណៈកម្ពុជា ឱ្យបង្កើនសមត្ថភាពផ្ទាល់ ដើម្បីកំណត់ពីតួនាទីរបស់ខ្លួនចំពោះទំនាក់ទំនងគណនេយ្យភាពនៅក្នុងប្រព័ន្ធរដ្ឋាភិបាល និងដើម្បីយល់ដឹងពីរបៀប របបដែលនយោបាយ និងស្ថាប័នផ្លូវការ ធ្វើអន្តរកម្មចុះឡើង ដើម្បីជះឥទ្ធិពលទៅលើគណៈនេយ្យភាពក្នុងវិស័យសាធារណៈ ។

## ការកំណត់ទស្សនៈរបស់កម្ពុជាស្តីពីគណនេយ្យភាព

ទោះជាគេយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើគណនេយ្យភាពក្តី ប៉ុន្តែនៅមានបញ្ហាប្រឈមជាច្រើនដែលរារាំងមិនឱ្យប្រព័ន្ធ និងទំនាក់ទំនងគណនេយ្យភាពសមហេតុផល កើតមានឡើងបាននៅកម្ពុជា ។ ទី១ មន្ត្រីរដ្ឋាភិបាលថ្នាក់ខ្ពស់ជាទូទៅមាន ចំណេះដឹងជាក់ស្តែងទូលំទូលាយស្តីពីបញ្ហាប្រឈមនានាក្នុងការគ្រប់គ្រងវិស័យសាធារណៈ ប៉ុន្តែពួកគេខ្វះខាតក្របខ័ណ្ឌគោលគំនិតដ៏រឹងប៉ឹង ដើម្បីធ្វើវិភាគជាលក្ខណៈប្រព័ន្ធ និងធ្វើការកែលំអ ។ ទី២ មន្ត្រីស៊ីវិល និងអ្នកនយោបាយជារឿយៗ នៅយល់ដឹងមិនទាន់ច្បាស់ពីភាពខុសគ្នារវាងគណនេយ្យភាពស្ថាប័ន និងគណនេយ្យភាពបុគ្គល ជាពិសេសនៅក្នុងស្ថាប័នរដ្ឋថ្នាក់ទាប ដែលអាចនាំឱ្យចុះខ្សោយដល់កិច្ចសន្ទនាជាសាធារណៈ ការ-ផ្លាស់ប្តូរមតិពីគោលការណ៍អភិបាលកិច្ចជាមួយប្រជាពលរដ្ឋ និង-

---

* ឯកសារនេះ ផ្អែកលើលទ្ធផលការងារក្នុងគំរោងសិក្សាពីគណនេយ្យភាពរបស់ វិបសអ ដែលបានដំណើរការតាំងពីពាក់កណ្តាលឆ្នាំ២០០៥ ។ សំរាប់ការពិភាក្សាលំអិតលើបញ្ហាលើកឡើងក្នុងអត្ថបទនេះ សូមរង់ចាំអាន *ការសិក្សាវិភាគឯកសារស្តីពីគណនេយ្យភាព និងរបបមេកើយ-កូនចៅសម័យថ្មី: ទស្សនៈ និងករណីសិក្សានៅកម្ពុជា* ។ លោក ហ៊ីង វុទ្ធី ជាអ្នកស្រាវជ្រាវនៅ វិបសអ ។

ការអនុវត្តន៍គោល នយោបាយ ។

ពាក្យ "accountablility រឺ គណនេយ្យភាព" ប្រើប្រាស់មិនបានរលូនល្អទេ ក្នុងភាសាអង់គ្លេស ហើយនៅពេលបកប្រែជាភាសាខ្មែរ ក៏កាន់តែមានន័យមិនច្បាស់ថែមទៀត ពីព្រោះគ្មានពាក្យសំរាប់បកប្រែឱ្យចំៗ ។ គណនេយ្យភាព គឺជាពាក្យបង្កើតថ្មី[១] តាមការបកប្រែត្រង់ៗនូវមេពាក្យក្នុងភាសាអង់គ្លេស គឺ account = គណនេយ្យ និង ability = ភាព រឺ សភាព ។ និយាយរួម ពាក្យ គណនេយ្យភាព តែងនាំឱ្យគេគិតដល់សភាពនៃគណនេយ្យ ហើយមន្ត្រីរាជការកម្ពុជា តែងផ្សារភ្ជាប់ពាក្យនេះទៅនឹង គណនេយ្យហិរញ្ញវត្ថុ ។ ជាទូទៅគេមិនបាននឹកដល់គោលគំនិតនៃគណនេយ្យភាពខាងស្ថាប័ន និងគណនេយ្យភាពបុគ្គលទេ ហើយមន្ត្រីរាជការក្រុមផ្សេងគ្នា មានការបកស្រាយន័យខុសៗគ្នា ។ ទាំងមន្ត្រីរដ្ឋថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានបកស្រាយន័យពាក្យនេះ ដោយសង្កត់ធ្ងន់លើខ្លឹមសារខាងហិរញ្ញវត្ថុ ដែលរួមមាន "តំលាភាព ការត្រួតពិនិត្យ និងការប្រតិបត្តិតាម" និងដែលអាចជាលទ្ធផលនៃការបកប្រែត្រង់ៗក្នុងន័យ "សភាពនៃគណនេយ្យ" ។ ការបកស្រាយបែបនេះ ក៏អាចមកពីអន្តរកម្មជាមួយប្រព័ន្ធគ្រប់គ្រងផ្អែកតាមអ្នកផ្តល់ជំនួយ ដូចជា កម្មវិធីសិលា ជាដើមដែរ ។

## លក្ខណៈពិសេសខាងបច្ចេកទេសនៃគណនេយ្យភាព

លក្ខណៈបច្ចេកទេសនានានៃគណនេយ្យភាព ផ្អែកលើការរៀបចំខាងស្ថាប័ន រឺខាងការិយាធិបតេយ្យសមហេតុផល-ស្របច្បាប់ដែលលេចធ្លោ អាចទាយទុកមុន និងកំណត់ច្បាស់ជាផ្លូវការដោយវិធាននិងបទប្បញ្ញត្តិច្បាប់ (ឧ. គោលការណ៍ណែនាំខាងសុខភាពសាធារណៈ ដើម្បីកែលំអសុខភាពមាតា និងទារក លក្ខណៈវិនិច្ឆ័យសំរាប់ជ្រើសរើស និងតំលើងឋានៈបុគ្គលិក) ហើយវាទទួលឥទ្ធិពលយ៉ាងខ្លាំងក្លាពីក្របខណ្ឌអភិបាលកិច្ចសេរី និងបែបបទអនុវត្តន៍ គាំទ្រដោយពួកបស្ចិមប្រទេស ហើយស្រេជាងខ្ពស់ដោយស្ថាប័នផ្តល់ជំនួយអន្តរជាតិ ។ ក្នុងអត្ថបទនេះ ក្របខណ្ឌផ្សេងៗគឺមានតាំងពីរដ្ឋបាល សាធារណៈបែបប្រពៃណីដែលបានវិវត្តខាងទ្រឹស្តី ការគ្រប់គ្រងសាធារណៈ បែបថ្មី និងសេដ្ឋកិច្ចស្ថាប័នសម័យថ្មី រហូតដល់វិធីសាស្ត្រផ្តោតលើការអភិវឌ្ឍន៍និងផ្អែកលើអ្នកផ្តល់ជំនួយ ដែលមានដូចជា រដ្ឋមានសមត្ថភាពល្អ វិមជ្ឈការ គណនេយ្យភាពខាងនយោបាយនិងសង្គមកិច្ច គណនេយ្យភាពត្រីកោណ និងគណនេយ្យភាពខ្សែបណ្តោយសំរាប់ការចែករំលែកលទ្ធផល ជាដើម[២] ។

ក្របខណ្ឌនីមួយៗជះឥទ្ធិពលជាក់លាក់ទៅលើបែបបទអនុវត្តអភិបាលកិច្ចរបស់កម្ពុជា និងចូលរួមចំណែកកំណត់គណនេយ្យភាពនៅក្នុងរបៀបរបបអភិបាលកិច្ច ។ ឧទាហរណ៍ ប្រព័ន្ធរដ្ឋបាលសាធារណៈជាប្រពៃណី (TPA) បាននាំមកនូវគោលគំនិតនៃការិយាធិបតេយ្យសមហេតុផល-ស្របច្បាប់ ដែលក្នុងនេះអ្នករដ្ឋបាលអាចធ្វើការដាច់ដោយឡែកពីអ្នកនយោបាយ (Weber 1965) ។ បើគិតពីគណនេយ្យភាព TPA បានណែនាំពីគោលគំនិតនៃ "ការទទួលខុសត្រូវចំពោះមុខ" និង "ការដាក់អនុវត្តន៍" (Schedler 1999) ។ រីឯក្របខណ្ឌគ្រប់គ្រងសាធារណៈបែបថ្មី (NPM) ផ្តោតលើគោលគំនិត "ទុកឱ្យអ្នកគ្រប់គ្រងធ្វើការគ្រប់គ្រង" (Drucker 1954, 1964) តាមរយៈការធ្វើវិមជ្ឈការសិទ្ធិអំណាចសំរេចអារកាត់ ដើម្បីឱ្យអ្នកគ្រប់គ្រងអាចជ្រើសរើសធាតុចូលផ្សេងៗ (ទោះជាមានកំហិតខាងថវិកាខ្លះៗ) និងវិធីអនុវត្តការងារដើម្បីអាចសំរេចគោលដៅបាន (Clark និង Newman 1993) ។ ក្របខណ្ឌគ្រប់គ្រងសាធារណៈបែបថ្មី (NPM) បកស្រាយន័យ គណនេយ្យភាព តាមរយៈទំនាក់ទំនងម្ចាស់-ភ្នាក់ងារ ហើយកំណត់ថា គណនេយ្យភាពអាចសំរេចបានតាមរយៈសិទ្ធិសំរេចពេញលេញក្នុងការគ្រប់គ្រង ។ គណនេយ្យភាព ក៏ទទួលឥទ្ធិពលផងដែរពីក្របខណ្ឌសេដ្ឋកិច្ចបែបស្ថាប័នថ្មី (NIE) ។ ដោយឈរលើការសន្មតជាមូលដ្ឋានរបស់ពួកនេអូក្លាស៊ិកស្តីពីភាពកំរនៃធនធាន និងតំរូវការប្រកួតប្រជែង NIE បាន ដាក់បញ្ចូលគ្នានូវសារៈសំខាន់នៃព័ត៌មាន គំនិតផ្សេងៗ និងចំណាយប្រតិបត្តិ ការជាប់ពាក់ព័ន្ធ ហើយតភ្ជាប់វាទៅនឹងចំណាយផលិតកម្ម និងប្រសិទ្ធភាព ជាទូទៅនៃទីផ្សារដែលជួយជំរុញកំណើន (North 1990) ។ ចំនុចស្នូលនៃ NIE គឺនិយមន័យពិសេសនៃស្ថាប័នដែលបានបូកបញ្ចូលទាំងវិធានធម្មតាៗ និងបទប្បញ្ញត្តិផ្សេងៗ (ជាពិសេស ព័ត៌មាន) ដែលតួអង្គផ្តល់ឱ្យគ្នានៅក្នុងប្រតិបត្តិការដោះដូរខាងសេដ្ឋកិច្ចនិងទីផ្សារ រឺប្រតិបត្តិការដទៃទៀត (North 1990; World Bank 2002) ។ ស្ថាប័នមានប្រសិទ្ធភាពល្អ ជួយកាត់បន្ថយចំណាយប្រតិបត្តិការ និងជំរុញកំណើន ។ គណនេយ្យភាពបែប NIE គឺផ្អែកលើស្ថាប័ន ទីផ្សារ ព័ត៌មាន កិច្ចសន្យា និងជំរើសនានា ។

ចាប់តាំងពីពាក់កណ្តាលទសវត្សរ៍១៩៩០ ទីភ្នាក់ងារអភិវឌ្ឍន៍ទ្វេភាគី និងពហុភាគី បានណែនាំពីវិធីសាស្ត្រជាច្រើន សំរាប់កែលំអការអភិវឌ្ឍន៍នៅក្នុងប្រទេសក្រីក្រ ។ ឧទាហរណ៍ វិមជ្ឈការដែលអនុវត្តនៅក្រោមគោលការណ៍ "រំលែកអំណាច (subsidiarity)" បានផ្តល់ហេតុផលថា មុខងារព្រមទាំងសិទ្ធិអំណាចនិងធនធានផ្សេងៗសំរាប់អនុវត្តតួនាទីនេះ គួរផ្តល់ទៅឱ្យអាជ្ញាធរមូលដ្ឋានថ្នាក់ទាបបំផុតដែលអាចអនុវត្តវាបាន (Breton *et al.* 1998) ។ ក្របខ័ណ្ឌវិមជ្ឈការ ព្យាយាមសំរេចឱ្យបាននូវគណនេយ្យភាពតាមរយៈ "ការពាំនាំរដ្ឋបាល (អ្នកផ្តល់សេវា) ឱ្យខិតទៅជិតប្រជាពលរដ្ឋ (អ្នកទទួលសេវា)" ដែលធ្វើឱ្យប្រជាពលរដ្ឋអាចទាមទារគណនេយ្យភាពទាំងពីអ្នករដ្ឋបាល និងពីអ្នកដឹកនាំជាប់ឆ្នោតនៅក្នុងមូលដ្ឋានយ៉ាងសកម្ម (Manor 1999: 67) ។ ក្របខ័ណ្ឌថ្មីៗនៃ "គណនេយ្យភាពត្រីកោណ" (WB 2004) សំគាល់ឃើញតួអង្គបីប្រភេទសំខាន់ៗគឺ អ្នកកសាងគោលនយោបាយ អ្នកផ្តល់សេវាជួរមុខ និងប្រជាពលរដ្ឋ ។ វិធីសាស្ត្រគណនេយ្យភាពត្រីកោណ បង្កើនការយកចិត្តទុកដាក់លើភាពស្មាតស្មុំនៃរចនាសម្ព័ន្ធ និងលទ្ធផលនៃសកម្មភាពបុគ្គល ដើម្បីកែលំអគណនេយ្យភាពខាងស្ថាប័ន ។ ម្យ៉ាងទៀត វាមិនគ្រាន់តែពិនិត្យលើគណនេយ្យភាពតាមរយៈព្រឹត្តិការណ៍កន្លងហើយ (ext post perspective) នោះទេ ប៉ុន្តែវាថែមទាំងមើលទៅមុខ មុនព្រឹត្តិការណ៍ (ext ante) ទៀតផង ។ ដូច្នេះ គណនេយ្យភាព ត្រូវមានលក្ខណៈពាក់ព័ន្ធល្អទាំងនៅមុនពេល ក្នុងពេល និងក្រោយពេលព្រឹត្តិការណ៍កើតឡើង ។ យោងតាមក្របខ័ណ្ឌនេះ លទ្ធផលដែលមានគណនេយ្យភាព ត្រូវផុសចេញពី (ក) ការធ្វើប្រតិភូកម្ម (ការចាត់តាំងច្បាស់លាស់) (ខ) ហិរញ្ញវត្ថុ (ផ្តល់ថវិកាគ្រប់គ្រាន់នៅគ្រប់កំរិត) (គ) លទ្ធផលការងារ (នៃមន្ត្រីរាជការក្រសួង និងអ្នកផ្តល់សេវាឯទៀត) (ឃ) ព័ត៌មានស្តីពីលទ្ធផល និង (ង) លក្ខណៈអាចដាក់អនុវត្តបាន (WB 2004:47) ។

## កត្តាគ្រោងផ្លូវការប៉ះពាល់ដល់គណនេយ្យភាព

### មូលដ្ឋានគ្រឹះមេកើយ-កូនចៅ

កម្ពុជា គឺជាសង្គមមានទំនាក់ទំនងបែបមេកើយ-កូនចៅ ជាប្រពៃណី ។ នេះជាវប្បធម៌មួយផ្អែកលើឋានានុក្រមសង្គម ដែលកកើតឡើងនៅជុំវិញ

"មិត្តភាពជាស្នូល ដោយក្នុងនេះបុគ្គលមានឋានៈសេដ្ឋកិច្ច-សង្គមកិច្ចខ្ពស់ (មេកើយ) បានប្រើប្រាស់ឥទ្ធិពលនិងធនធានរបស់ខ្លួន ដើម្បីផ្តល់កិច្ចការពារ និង/រឺ ផលប្រយោជន៍ ដល់អ្នកមានឋានៈទាបជាង (កូនចៅ) ហើយជាការតបស្នង កូនចៅនឹងផ្តល់ជំនួយគាំទ្រជាទូទៅ រួមទាំងសេវាផ្ទាល់ខ្លួនផងទៅដល់មេកើយ" (Scott 1977:92) ។ ចរិតលក្ខណៈនៃទំនាក់ទំនងមេកើយ-កូនចៅ មានជាអាទិ៍ (ក) ឋានានុក្រមរឹងមាំ និងបដិការមិនស្មើភាព ដោយមានកូនចៅនៅហែហមជុំវិញមេកើយ (ខ) មេកើយបានប្រមូលបង្គរទុកទ្រព្យសម្បត្តិតាមរយៈការត្រួតត្រាលើធនធានសំខាន់ៗ (គ) ទំនាក់ទំនងផ្អែកលើមនោសញ្ចេតនា ដូចជាសាច់ញាតិ និងក្រុមគ្រួសារ (ឃ) ការស្វែងរកដំណោះស្រាយដោយផ្អែកលើទំនាក់ទំនងផ្ទាល់ខ្លួនជាមួយមេកើយ និង (ង) សីលធម៌ជាប្រពៃណី និងវប្បធម៌ បានក្លាយជាកត្តាជះឥទ្ធិពលទៅលើចរិតនៃទំនាក់ទំនងមេកើយ-កូនចៅ (Weber 1965, 1978; Scott 1977; Eisenstadt and Roniger 1984; Neher 1981; Hanks 1975) ។

របបមេកើយ-កូនចៅនៅកម្ពុជា បានបង្ហាញនូវលក្ខណៈជាច្រើនដូចបានរៀបរាប់ខាងលើ ។ ឋានានុក្រមរឹងមាំ និងបដិការមិនស្មើភាពនៅកម្ពុជាអាចផុសចេញពីការប្រើប្រាស់ "ខ្សែ" និង "ខ្នង" ។ ខ្សែ សំដៅដល់កូនចៅមួយខ្សែដែលពឹងផ្អែកលើកិច្ចការពារ និងការគាំទ្រពី ខ្នង ដែលមានន័យត្រង់ថា "ខ្នងរបស់មនុស្ស" និង ន័យធៀបថា "មេកើយ" ។ ការណែនាំក្នុងសង្គម ជាប្រពៃណីជំរុញឱ្យប្រជាជនកម្ពុជាស្វែងរក ខ្សែ រឺ ខ្នង ដែលមានលក្ខណៈ ស្របគ្នានឹងការសង្កេតថា ទំនាក់ទំនងមេកើយ-កូនចៅត្រូវបានជំរុញឡើង ដោយសារការបរាជ័យរបស់រដ្ឋ និងបណ្តាញគ្រួសារក្នុងការផ្តល់កិច្ចការពារ ដល់បុគ្គល (Scott 1977) ។ ការណែនាំជាប្រពៃណីនិងតាមវប្បធម៌នៅ កម្ពុជាដែលពង្រឹងភក្តីភាពរវាងមេកើយ-កូនចៅ រួមមានការកសាងកុងសង់ស៊ុស និងការជៀសវាង-ការតទល់ដោយផ្ទាល់ជាមួយអ្នកមានអំណាច រឺ អ្នកឋានៈខ្ពស់ ។ ចំនុចគួរ-ចាប់អារម្មណ៍ គឺអ្នកភូមិជនបទមិនបានចាត់ទុករបប អនុគ្រោះនិយមនេះថាអយុត្តិធម៌ រឺមិនស្មើភាពនោះទេ (Ledgerwood and Vijghen 2002) ។ តួអង្គក្នុងក្បាលម៉ាស៊ីនរដ្ឋ ជាពិសេសមន្ត្រីរាជការ ត្រូវប្រឈមមុខនឹងគណនេយ្យភាពច្រើនបែបយ៉ាង ទាំងចំពោះគ្រួសារ និងអង្គការចាត់តាំងរបស់រដ្ឋ ។

## រដ្ឋប្រកាន់របបមេកើយ-កូនចៅសម័យថ្មី

ស្ថាប័នផ្លូវការត្រូវបានបង្កើតឡើងដើម្បីបំរើសាធារណៈជន និងគោរពតាមបែបបទគណនេយ្យភាពជាផ្លូវការ ប៉ុន្តែស្ថាប័នក្រៅផ្លូវការ (មនោគមវិជ្ជាបំរើនយោបាយ សីលធម៌និងបទដ្ឋានវប្បធម៌ បណ្តាញមេកើយ-កូនចៅជាប្រពៃណី) ប្រហែលអាចលំអៀងទៅរកផលប្រយោជន៍ឯកជន និងមានគណនេយ្យភាពមិនសូវច្បាស់លាស់ ។ ប្រព័ន្ធអភិបាលកិច្ចមេកើយ-កូនចៅសម័យថ្មី ជាប្រព័ន្ធចំរុះដែលក្នុងនោះវិធាននិងរបៀបរបបបែបមេកើយ-កូនចៅ វាស្ថិតនៅជាប់ពីក្រោមស្ថាប័នសមហេតុផល-ស្របច្បាប់នានា (Brinkerhoff and Goldsmith 2002) ។ ចរិតលក្ខណៈនៃរបបមេកើយ-កូនចៅសម័យថ្មី (ដែលជារបបមេកើយ-កូនចៅជាប្រពៃណីបានកែតំរូវ) រួមមាន (ក) ការដោះស្រាយបញ្ហាតាមវិធីពិសេសផ្ទាល់ខ្លួន (ខ) ការប្រមូលផ្តុំធនធានក្នុងដៃអ្នកឋានៈខ្ពស់មួយចំនួនតូច (គ) ការបែងចែក-មិនច្បាស់លាស់រវាងដែនសាធារណៈ និងដែនឯកជន (ឃ) វត្តមានវិបត្តិហិរ-ញ្ញវត្ថុរ៉ាំរ៉ៃ (Bratton and van de Walle 1994; van de Walle 2001) ។

ប្រព័ន្ធអភិបាលកិច្ចបច្ចុប្បន្នរបស់កម្ពុជា គឺមានបរិយាកាសនយោបាយនិងស្ថាប័នតាមបែបមេកើយ-កូនចៅសម័យថ្មី (Rusten *et al.* 2004) ដោយក្នុងនេះ បណ្តាញឧបត្ថម្ភគាំទ្រក្រៅផ្លូវការ បានជ្រៀតចូលទៅក្នុងស្ថាប័នផ្លូវការ ហើយធ្វើឱ្យទំនាក់ទំនងគណនេយ្យភាពវាស្មុគស្មាញជាខ្លាំង ។ ចរិតលក្ខណៈមួយនៃរបបមេកើយ-កូនចៅសម័យថ្មីនៅកម្ពុជា គឺការប្រើប្រាស់ជាប្រក្រតីនូវស្ថាប័នផ្លូវការសំរាប់ទាញយកផលប្រយោជន៍ ។ Huges (2003:61) បានលើកថា "រដ្ឋបានប្រើប្រាស់ហេតុផលនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច ដើម្បីបើកច្រកធនធាន ដែលបន្ទាប់មកក៏អាចយកវាមកប្រើប្រាស់សំរាប់ជំរុញលក្ខណៈពេញច្បាប់នៃរបបគ្រប់គ្រង តាម-រយៈការផ្តល់អំណោយ និងតួនាទីដល់កូនចៅ ហើយពួកកូនចៅក៏បង្កើតសិទ្ធិអំណាច និងឱកាសសំរាប់កេងយកចំណេញ" ។ ដំណោះស្រាយផ្ទាល់ខ្លួនចំពោះបញ្ហាសាធារណៈ អាចមើលឃើញច្បាស់នៅពេលអ្នកភូមិជនបទក្រីក្របានអំពាវនាវដោយផ្ទាល់ដល់មន្ត្រីជាន់ខ្ពស់ឱ្យជួយដោះស្រាយបញ្ហារំលោភយកដីធ្លី ជាជាងដាក់បណ្តឹងតវ៉ាតាមរយៈស្ថាប័នការិយាធិបតេយ្យផ្លូវការរបស់រដ្ឋ ។ របបមេកើយ-កូនចៅសម័យថ្មី បានពង្រីកទៅដល់ថ្នាក់មូលដ្ឋាន ហើយនៅទីនោះមន្ត្រីការិយាល័យទទួលរងឥទ្ធិពលអវិជ្ជមាន ពីព្រោះបដិការមិនស្មើភាពនៅក្នុងទំនាក់ទំនង វាធ្វើឱ្យមានធនធានតិចតួចណាស់ (បានតែមួយរស់) ដែលធ្លាក់ទៅដល់ពួកគេ ។ ជារឿយៗធនធានដែលបែងចែកឱ្យនោះ វាបានត្រឹមតែ ជួយដោះស្រាយតំរូវការចាំបាច់របស់កូនចៅប៉ុណ្ណោះ ដើម្បីឱ្យកូនចៅនៅរក្សា ភក្តីភាព និងមានជីវភាពមួយដ៏សាមញ្ញបំផុត ។

កិច្ចពិភាក្សាខាងលើ ដែលផ្តោតលើទិដ្ឋភាពបច្ចេកទេសនិងក្រៅផ្លូវការនៃគណនេយ្យភាព បានលាតត្រដាងពីបរិយាកាសដ៏ស្មុគស្មាញ ដែលមន្ត្រីរាជការ និងអ្នកធ្វើកំណែទំរង់ ត្រូវបំពេញមុខងារខ្លួន ។ ដើម្បីជួយដល់មន្ត្រីរាជការ និងអ្នកធ្វើកំណែទំរង់ ក្នុងការវាយតំលៃលើប្រព័ន្ធអភិបាលកិច្ចដ៏ស្មុគស្មាញ អត្ថបទនេះដាក់ស្នើឡើងនូវនិយមន័យថ្មីមួយនៃគណនេយ្យភាព ដែលផ្សារភ្ជាប់ល្អទៅនឹងបរិបទកម្ពុជា ក៏ដូចជាការសន្មតផ្សេងៗខាងផ្នែកទ្រឹស្តី ។

## សេចក្តីសន្និដ្ឋាន

### ការកំណត់ឡើងវិញនូវនិយមន័យគណនេយ្យភាពក្នុងវិស័យសាធារណៈសំរាប់ប្រទេសកម្ពុជា

ដើម្បីពង្រឹងគណនេយ្យភាពក្នុងវិស័យសាធារណៈនៅកម្ពុជា ភ្នាក់ងាររដ្ឋបាលសាធារណៈ និងអ្នកធ្វើកំណែទំរង់ ចាំបាច់ត្រូវយល់ដឹងពីលក្ខណៈចាំបាច់ផ្សេងៗនៃគណនេយ្យភាព យោងតាមក្រឹត្យក្រមបច្ចេកទេស និងយោង-តាមកត្តាសង្គមកិច្ចនិងកត្តានយោបាយជាក់ស្តែង ដែលជះឥទ្ធិពលជាលក្ខណៈក្រៅ ផ្លូវការទៅលើវា ។ ការយកចិត្តទុក-ដាក់មិនស្មើគ្នាចំពោះកត្តាទាំងពីរ ច្រើននាំឱ្យមានគណនេយ្យភាព "តែមួយជ្រុង" និង-មានឱកាសតិចតួចដើម្បីនឹងផ្តល់សេវាសំខាន់ៗដោយមានចីរភាព ។ និ-យមន័យថ្មីតាមបរិបទនៃ គណនេយ្យភាព ដូចមាននៅខាងក្រោម ត្រូវបានរៀបចំឡើងដើម្បីឱ្យមាន តុល្យភាពស្របតាមតំរូវការ :

- គណនេយ្យភាព គឺជាសីលធម៌ផ្ទាល់ខ្លួន សីលធម៌ខាងរដ្ឋបាល និង

*តទៅទំព័រទី ១៩*

# តើពាណិជ្ជកម្មសេរីជួយជំរុញការរីកចំរើនដែរទេ?

*បណ្ឌិត សុខ ស៊ីណា ព្យាយាមទាក់ទាញការយកចិត្តទុកដាក់ចំពោះមតិថា ពាណិជ្ជកម្មសេរីមិនមែនជាឱសថទិព្វ សំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចនោះទេ ដោយបានរំលែកពីទ្រឹស្តីជាច្រើនដើម្បីធ្វើការបញ្ជាក់អះអាង ។ នៅពេលកម្ពុជាឈានជើងចូលទៅក្នុងពិភពនៃសាកលភាវូបនីយកម្ម ពាណិជ្ជកម្មសេរីកំពុងដំណើរការទៅមុខជានិច្ច ហើយសមាជិកទាំងអស់នៃអង្គការពាណិជ្ជកម្មពិភពលោក (World Trade Organisation: WTO) ត្រូវតែប្រកួតប្រជែងគ្នា ។ ផលចំណេញ និងការខាតបង់ អាចកើតមានឡើងក្នុងពេលជាមួយគ្នា រីឯលទ្ធផលវាអាស្រ័យជាសំខាន់ទៅតាមស្ថានភាពប្រកួតប្រជែងរបស់ប្រទេសនីមួយៗ ។**

សាកលភាវូបនីយកម្ម[1] និងការបារម្ភពីភាពក្រីក្រនិងវិសមភាព បានក្លាយជាបញ្ហាមានការពិភាក្សាច្រើនបំផុតនៅក្នុងមជ្ឈដ្ឋានអ្នកសិក្សា និងប្រព័ន្ធផ្សព្វផ្សាយ ។ មានការយល់ឃើញផ្សេងៗគ្នាច្រើនណាស់ ពីផលប៉ះពាល់នៃសាកលភាវូបនីយកម្ម ។ អ្នកប្រឆាំងនឹងសាកលភាវូបនីយកម្មលើកឡើងថា សាកលភាវូបនីយកម្មធ្វើឱ្យអ្នកមានកាន់តែមាន ហើយអ្នកក្រកាន់តែក្រ ចំណែកឯពួកអ្នកគាំទ្រអះអាងថា សាកលភាវូបនីយកម្ម ជួយជំរុញការរីកចំរើន ។ សូម្បីក្នុងចំណោមអ្នកសេដ្ឋកិច្ច ក៏មានការខ្វែងមតិគ្នាជាខ្លាំងអំពីផលប៉ះពាល់នៃពាណិជ្ជកម្មសេរីចំពោះសេដ្ឋកិច្ចប្រទេសមួយ ។ បើសិនគ្មានការយល់ឃើញស្របគ្នាពីផលចំណេញនៃពាណិជ្ជកម្មសេរីទេ ហេតុអ្វីបានជាប្រទេសនានានៅទូទាំងពិភពលោក រួមទាំងប្រទេសក្រីក្រផង បានសំរេចចិត្តចូលក្នុង WTO? ដូចប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើនទៀតដែរ នៅពេលចូលក្នុង WTO នៅឆ្នាំ២០០៤ កម្ពុជាសង្ឃឹមថា WTO នឹងផ្តល់ផលចំណេញដល់វិស័យនាំចេញ ជាពិសេសផលិតកម្មសំលៀកបំពាក់ ។ ដើម្បីសំរេចគោលដៅនេះ ថ្លៃថាមពល ថ្លៃដឹកជញ្ជូន និងការិយាធិបតេយ្យ ត្រូវតែកាត់បន្ថយ ហើយការកសាងសមត្ថភាពរបស់កម្មករត្រូវតែជំរុញឡើង ។

អត្ថបទសង្ខេបនេះ ពិនិត្យមើលពីវិធីដែលកម្ពុជាអាចទាញផលចំណេញពីភាពជាសមាជិក WTO ។ ផ្នែកទី១ ពិភាក្សាពីទ្រឹស្តីក្លាស៊ិកនៃពាណិជ្ជកម្មអន្តរជាតិ ហើយផ្នែកទី២ បង្ហាញពីការអះអាងជំទាស់មួយចំនួន ការវិភាគពីស្ថានភាពនៅកម្ពុជា និងអនុសាសន៍គោលនយោបាយមួយចំនួន ។

## ទ្រឹស្តីក្លាស៊ិកនៃពាណិជ្ជកម្មអន្តរជាតិ

យោងតាមទ្រឹស្តីនេះ ពាណិជ្ជកម្មគឺជាប្រភពនៃការរីកចំរើន ។ ឧត្តមភាពដាច់ខាត និងឧត្តមភាពប្រៀបធៀប គឺជាយន្តការសំខាន់ពីរដែលអាចបង្កឱ្យមានពាណិជ្ជកម្មអន្តរជាតិ ។ សូមពិនិត្យមើលពីវិធីដែលយន្តការទាំងពីរនេះអាចទាញយកផលចំណេញពីពាណិជ្ជកម្ម ។

***កង្វះខាតទំនិញ នាំឱ្យមានពាណិជ្ជកម្ម:*** ជាទូទៅ ពាណិជ្ជកម្មរវាងប្រទេសនានា កើតឡើងនៅពេលមានប្រទេសណាមួយខ្វះខាតទំនិញ ។ ពាណិជ្ជកម្មនាំមកនូវផលចំណេញ ដោយវាជួយបំពេញការខ្វះខាតទំនិញប្រើប្រាស់ និងទំនិញវិនិយោគនៅក្នុងប្រទេសនាំចូល ។ សំរាប់ប្រទេសកំពុងអភិវឌ្ឍន៍ដែលពុំមានសមត្ថភាពផលិតគ្រឿងចក្រឧស្សាហកម្មសំរាប់កែច្នៃផលិតផលកសិកម្ម ការនាំចូលគ្រឿងបរិក្ខារទាំងនេះមានសារៈសំខាន់ខ្លាំងណាស់ ព្រោះវាជួយឱ្យគេអាចបង្កើតផលិតផលថ្មីៗបាន ។ នៅពេលជាមួយគ្នា ប្រទេសនាំចេញក៏អាចកាត់បន្ថយអតិរេកផលិតផលរបស់ខ្លួន ។ ផលចំណេញពីការនាំចេញ អាចយកទៅប្រើប្រាស់សំរាប់គោលដៅផ្សេងទៀតបាន ហើយរឿងនេះក៏ជួយឱ្យប្រទេសនាំចេញអាចបង្កើតផលិតផលថ្មីៗទៀតដែរ ។

***ថ្លៃដើមផលិតកម្មខុសគ្នា ក៏នាំឱ្យមានពាណិជ្ជកម្មដែរ:*** ទំនិញអាចមាននៅគ្រប់ប្រទេសដែលចូលរួមធ្វើពាណិជ្ជកម្ម ប៉ុន្តែថ្លៃដើមផលិតកម្ម វាខុសគ្នា ។ តាមរយៈពាណិជ្ជកម្ម សុខមាលភាពនៅប្រទេសទាំងនោះអាចកើនឡើងតាមរយៈការកាត់បន្ថយថ្លៃដើមផលិតកម្ម ។ ប្រទេសដែលមានថ្លៃដើមផលិតកម្មខ្ពស់ អាចជំនួសផលិតផលក្នុងស្រុកដោយទំនិញនាំចូល ដែលផលិតឡើងអស់ថ្លៃដើមទាបជាង ។ ដូច្នេះពាណិជ្ជកម្មជួយឱ្យប្រទេសមួយអាចកសាងជំនាញឯកទេសនៅក្នុងវិធីសាស្ត្រផលិតរបស់ខ្លួន ។ ការរីកចំរើនក្នុងវិធីសាស្ត្រផលិត មិនត្រឹមតែកាត់បន្ថយថ្លៃដើមផលិតកម្មប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កើតឱ្យមានផលិតផលថ្មីៗទៀតផង ។

## ការអះអាងជំទាស់

ទ្រឹស្តីក្លាស៊ិកនៃពាណិជ្ជកម្មអន្តរជាតិ មានគេរិះគន់ជាយូរមកហើយ ។ លោក Friedrich List ជាសេដ្ឋវិទូដើមកំណើតអាឡឺម៉ង់ និងជាមនុស្សម្នាក់ក្នុងចំណោមស្ថាបនិកដ៏សំខាន់ៗបំផុតនៃទ្រឹស្តីពន្ធគយ បានរិះគន់យ៉ាងខ្លាំងចំពោះការអះអាងរបស់លោក Adam Smith ដែលបានអំពាវនាវឱ្យបង្កើតពាណិជ្ជកម្មសេរីនេះឡើង ។ យោងតាម List ពាណិជ្ជកម្មអាចនាំឱ្យមានការបែងចែកស្មើគ្នានូវភាពចំរុងចំរើន គឺលុះត្រាតែបណ្តាប្រទេសចូលរួមធ្វើពាណិជ្ជកម្មមានកំរិតអភិវឌ្ឍន៍ស្មើគ្នា បើពុំនោះទេ វានឹងនាំឱ្យមានអ្នកឈ្នះ និង អ្នកចាញ់ ។ ជាទូទៅ អ្នកឈ្នះគឺជាប្រទេសអ្នកមាន ពីព្រោះវិធីផលិតរបស់គេមានការអភិវឌ្ឍន៍ខ្ពស់ជាង ហើយអ្នកចាញ់គឺជាប្រទេសក្រីក្រ ។ ដូច្នេះ ពាណិជ្ជកម្មសេរី មិនមែនជាឱសថទិព្វសំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចនោះទេ ។

អ្នកគាំទ្រទ្រឹស្តីនៃការពឹងផ្អែក (ឧ. Paul Baran 1975) បានជជែកវែកញែកថា ប្រទេសកំពុងអភិវឌ្ឍន៍ គួរតែផ្តាច់ចំណងទាក់ទងជាមួយប្រទេសអភិវឌ្ឍន៍តែម្តង ។ យោងតាមទ្រឹស្តីនេះ ការធ្វើសមាហរណកម្មកាន់តែខ្លាំងទៅក្នុងទីផ្សារពិភពលោក អាចមានផលប៉ះពាល់មិនល្អដល់ការ អភិវឌ្ឍន៍ ហើយមូលហេតុចំបង គឺការដោះដូរមិនស្មើភាពរវាងប្រទេស អភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍ ។ ការវែកញែកនេះទទួលបានការគាំទ្រ ពី Dieter Senghaas (Hein ឆ្នាំ១៩៩៦) ។ យោងតាម Senghaas ប្រទេស កកើតថ្មី ត្រូវការគោលការណ៍ការពារមួយចំនួនដើម្បីជួយឧស្សាហកម្មក្មេងខ្ចី របស់គេឱ្យមានជីវិតរស់ ។ Senghaas បានជជែកវែកញែកថា អឺរ៉ុបខាងលិច មានការអភិវឌ្ឍន៍សេដ្ឋកិច្ច គឺដោយសារគោលការណ៍ការពារផលិតផល ក្នុងស្រុកជាជាងដោយសារពាណិជ្ជកម្មសេរី ។

យុទ្ធសាស្ត្រអភិវឌ្ឍន៍នៃបណ្តាប្រទេសឧស្សាហកម្មថ្មី (NICs) បានបង្ហាញផ្លូវដើរប្រហាក់ប្រហែលគ្នា ។ ឧទាហរណ៍ ការជំរុញការនាំចេញ និងការ

---

* អត្ថបទនេះផ្អែកលើទ្រឹស្តីបែបក្លាស៊ិកនៃពាណិជ្ជកម្មអន្តរជាតិ មតិអះអាងជំទាស់ និងការវិភាគពីស្ថានភាពនៅកម្ពុជា ។ បណ្ឌិត សុខ ស៊ីណា ជាអ្នកស្រាវជ្រាវនៅ វិបសអ ។

ផលិតទំនិញជំនួសការនាំចូល គឺជាយុទ្ធសាស្ត្រផ្សំគ្នា ដែលជួយឱ្យកូរ៉េខាងត្បូង និងតៃវ៉ាន់ ក្លាយជាប្រទេសមានជោគជ័យខ្លាំងជាងគេខាងសេដ្ឋកិច្ចនៅសតវត្សរ៍ទី២០ ហើយជោគជ័យនេះកំពុងបន្តរហូតមកដល់បច្ចុប្បន្ន ។ យុទ្ធសាស្ត្រមួយនៃគោលការណ៍ការពារផលិតផលក្នុងស្រុក គឺគេអនុញ្ញាតឱ្យមានវិនិយោគទុនបរទេសផ្ទាល់ លុះត្រ-តាណាវាមិនគំរាមកំហែងដល់វត្តមានឧស្សាហកម្មក្មេងខ្ចីក្នុងស្រុក ។ កិច្ចការពារនេះត្រូវអនុវត្តរហូតដល់ពេលឧស្សាហកម្មក្មេងខ្ចីធំពេញរូបរាង អាចប្រកួតប្រជែងបាន ហើយបន្ទាប់មក គេដកវាចេញជាបណ្ដើរៗ ដើម្បីទុកឱ្យផលិតផលក្នុងស្រុកប្រឹងប្រកួត ប្រជែងជាមួយផលិតផលបរទេស ។

យុទ្ធសាស្ត្រការពារផលិតផលក្នុងស្រុក ពឹងផ្អែកលើអន្តរាគមន៍ដ៏ខ្លាំងក្លារបស់រដ្ឋនៅក្នុងសេដ្ឋកិច្ច ដែលផ្ទុយពីទ្រឹស្តីក្លាសិកនៃពាណិជ្ជកម្មអន្តរជាតិ និងផ្ទុយពីមតិទូទៅរបស់អ្នកធ្វើនយោបាយរូបិយវត្ថុដែលលើកថា អន្តរាគមន៍ខ្លាំងៗរបស់រដ្ឋ ហុចផលមិនល្អទេដល់កំណើនសេដ្ឋកិច្ច ។ ប៉ុន្តែ ពួកអ្នកគាំទ្រទ្រឹស្តីពន្ធគយបានជជែកវែកញែកថា គោលការណ៍ការពារផលិតផលក្នុងស្រុកនេះ គ្មានបង្កគ្រោះថ្នាក់អ្វីទេ ប៉ុន្តែគឺកង្វះចំណុចផ្តោតនៃគោលការណ៍ការពារ និងការយឺតយ៉ាវក្នុងការកំណត់ពីផលប៉ះពាល់អវិជ្ជមាននៃគោលការណ៍ការពារទៅវិញទេ ដែលបង្កគ្រោះថ្នាក់នោះ ។

## ស្ថានភាពកម្ពុជា

វិធីសាស្ត្របែបទ្រឹស្តីដូចពិភាក្សានៅខាងលើ ជួយផ្តល់គំនិតយ៉ាងច្បាស់ថា ពាណិជ្ជកម្មសេរីមិនមែនសុទ្ធតែធានាបាននូវការរីកចំរើននោះទេ ។ ស្ថិតក្នុងចំណោមប្រទេសក្រីក្របំផុតក្នុងពិភពលោក កម្ពុជាបានចូលជាសមាជិក WTO នៅខែកញ្ញា ឆ្នាំ២០០៤ ហើយការណ៍នេះបង្ហាញពីកិច្ចខិតខំរបស់រដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រតាមរយៈពាណិជ្ជកម្ម ដែលចាត់ទុកជាគំនិតផ្តួចផ្តើមដ៏សំខាន់មួយ ដើម្បីបង្កើនការងារនៅគ្រប់វិស័យ ។ ទោះបីពាណិជ្ជកម្មបានកើនឡើងយ៉ាងខ្លាំងតាំងពីពេលបង្កើតរដ្ឋាភិបាលចំរុះនៅឆ្នាំ១៩៩៣ មកក្តី ក៏ពាណិជ្ជកម្មក្រៅប្រទេស បានពឹងផ្អែកយ៉ាងខ្លាំងតែទៅលើវិស័យមួយ គឺឧស្សាហកម្មកាត់ដេរ ។ ឧទាហរណ៍ ការនាំចេញផលិតផលសំលៀកបំពាក់ មានរហូតដល់ ៧០% នៃការនាំចេញសរុបនៅឆ្នាំ ១៩៩៨-២០០២[២] ដោយកើនពី ២០លានដុល្លារនៅឆ្នាំ១៩៩៥ ដល់ជិត ២ពាន់លានដុល្លារ នៅឆ្នាំ២០០៤ ។

កំណើនក្នុងឧស្សាហកម្មកាត់ដេរ ផុសចេញពីកត្តា ៣ជាសំខាន់: (១) ច្បាប់វិនិយោគទុនផ្ទាល់ (២) ផលចំណេញបានពីលក្ខខណ្ឌពាណិជ្ជកម្មអនុគ្រោះបំផុត (MFN) និងប្រព័ន្ធអនុគ្រោះទូទៅ (GSP) ដែលផ្តល់ឱ្យដោយសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប និង (៣) កំលាំងពលកម្មថោក ។ ឧស្សាហកម្មនាំចេញរបស់កម្ពុជា បានស្ទុះឡើងនៅចំពេលគេធ្វើឱ្យមានសេរីភាវូបនីយកម្មលើពាណិជ្ជកម្មសំលៀកបំពាក់ ដែលត្រូវបានគ្រប់គ្រងដោយកិច្ចព្រមព្រៀងវិស័យកាត់ដេរ និងវាយនភ័ណ្ឌ ។ នៅក្នុងព្រមព្រៀងនេះ ពាណិជ្ជកម្មផលិតផលសំលៀកបំពាក់ វាអាស្រ័យទៅតាមកិច្ចព្រមព្រៀងទ្វេភាគី ។ កូតា និងពន្ធនាំចូល គឺកំណត់ដោយប្រទេសនាំចូល ។ កិច្ចព្រមព្រៀងវិស័យកាត់ដេរនិងវាយនភ័ណ្ឌ បានបញ្ចប់នៅចុងឆ្នាំ២០០៤ ហើយតាំងពីនោះមក ពុំមានកូតាសំរាប់ពាណិជ្ជកម្មផលិតផលសំលៀកបំពាក់ចំពោះសមាជិក WTO ទៀតទេ ។ ការនាំចេញនិងនាំចូលផលិតផលសំលៀកបំពាក់ ពុំមានការរិតបន្តឹងទៀតទេ ហើយវាស្ថិតក្រោមអត្រាពន្ធគយធម្មតា ។ ដើម្បីឱ្យឧស្សាហកម្មកាត់ដេរមានដំណើរការ កម្ពុជាត្រូវការសមាជិកភាពក្នុង WTO ។ នេះជាការវែកញែកសមហេតុផលមួយ ។ ប៉ុន្តែពាណិជ្ជកម្មសេរីមានន័យថា ផលិតផលក្នុងស្រុក ត្រូវប្រកួតប្រជែងជាមួយផលិតផលបរទេស ទាំងនៅលើទីផ្សារពិភពលោក និងទីផ្សារក្នុងស្រុក ។

ផលចំណេញពិត និងការខាតបង់ពិតនៃពាណិជ្ជកម្មសេរី ស៊ឹងតែមិនអាចគណនាកើតទេ ។ ប៉ុន្តែ គេអាចវិភាគផលប៉ះពាល់នៃពាណិជ្ជកម្មសេរីបានតាមរយៈផលប៉ះពាល់លើអ្នកប្រើប្រាស់ និងផលប៉ះពាល់លើអ្នកផលិត ។ ផលប៉ះពាល់អាចមានលក្ខណៈខុសៗគ្នា ។ បើសិនផលិតផលក្នុងស្រុកមានថ្លៃខ្ពស់ជាងផលិតផលនាំចូល តំរូវការផលិតផលនាំចូលនឹងកើនឡើង ។ ផលប៉ះពាល់លើអ្នកប្រើប្រាស់ គឺវិជ្ជមានក្នុងករណីនេះ ពីព្រោះពួកគេបានទំនិញប្រើប្រាស់ច្រើនជាងមុនក្នុងតំលៃដូចគ្នា ។ ប៉ុន្តែផលប៉ះពាល់លើអ្នកផលិត គឺអវិជ្ជមាន ពីព្រោះតំរូវការផលិតផលក្នុងស្រុកធ្លាក់ចុះ ។ ផលប៉ះពាល់វិជ្ជមានលើអ្នកប្រើប្រាស់ អាចទទួលបានដោយមានការខាតបង់ក្នុងវិស័យផលិតកម្ម ។ ដូច្នេះ កំណើនការនាំចូលអាចបណ្តាលឱ្យធ្លាក់ចុះ ចំនួនការងារធ្វើ ។ បើគិតទាំងផលប៉ះពាល់លើអ្នកផលិតផង សមាហរណកម្ម សេដ្ឋកិច្ចកម្ពុជាទៅក្នុង WTO មិនសូវភ្លឺថ្លាប៉ុន្មានទេនៅក្នុងរយៈពេលខ្លី ប៉ុន្តែ វាអាចមានលក្ខណៈវិជ្ជមាននៅក្នុងរយៈពេលវែង ។ គេត្រូវទទួលស្គាល់ថា លទ្ធផលទៅអនាគតវាជាប់ទាក់ទងនឹងស្ថានភាពជាក់ស្តែងនាពេលបច្ចុប្បន្ន ច្រើនណាស់ ពីព្រោះអនាគតកាល គឺជារឿងបន្តពីបច្ចុប្បន្នកាល ។

ឧស្សាហកម្មកាត់ដេររបស់កម្ពុជា នៅក្មេងខ្ចីណាស់ ។ នៅចុងឆ្នាំ២០០៤ ផលិតផលសំលៀកបំពាក់ជាង ៩០% បាននាំចេញទៅសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុបនៅក្រោមលក្ខខណ្ឌអនុគ្រោះ MFN រឺ GSP ។ ដោយសារលក្ខខណ្ឌអនុគ្រោះបានចប់អស់ ឧស្សាហកម្មកាត់ដេរត្រូវពឹងផ្អែកយ៉ាងខ្លាំងលើសមត្ថភាពប្រកួតប្រជែងរបស់ខ្លួន ។ មានកត្តាសំខាន់ៗ ៣ យ៉ាងតិចដែលកំណត់ពីលក្ខណៈប្រកួតប្រជែងរបស់សហគ្រាស ពោលគឺ ថ្លៃ គុណភាព និងជំនាញគ្រប់គ្រង ។ ទាក់ទិននឹងគុណភាពផលិតផល និងជំនាញគ្រប់គ្រងការប្រកួតប្រជែងលើទីផ្សារពិភពលោក មិនចោទបញ្ហាខ្លាំងទេ ពីព្រោះរោងចក្រកាត់ដេរប្រហែល ៨០%[៣] ជាកម្មសិទ្ធិរបស់វិនិយោគិនបរទេស ដែលភាគច្រើនមានបទពិសោធន៍ជាយូរមកហើយក្នុងមុខជំនួញនេះ ។ បញ្ហាសំខាន់សព្វថ្ងៃគឺ ថ្លៃដើមផលិតកម្ម ។ ដោយហេតុថា ចិនក៏ជាសមាជិក WTO និងស្ថិតក្នុងចំណោមប្រទេសនាំមុខគេខាងនាំចេញសំលៀកបំពាក់ ដូច្នេះកម្ពុជាត្រូវប្រឈមមុខនឹងការប្រកួតប្រជែងខ្លាំងក្លាពីប្រទេសចិន ។ ថ្លៃដើមសំលៀកបំពាក់នៅកម្ពុជា ខ្ពស់ជាងនៅចិនប្រហែល ១៥%-២០% (IMF ឆ្នាំ២០០៣ ទំព័រ ៤៨) ។ ដូច្នេះ កម្ពុជាត្រូវតែបន្ទាបថ្លៃដើមផលិតកម្មរបស់ខ្លួន ឱ្យនៅត្រឹមកំរិតអាចប្រកួតប្រជែងបាន ។ ប៉ុន្តែក្នុងករណីខ្លះ គេមិនអាចបញ្ចុះថ្លៃដើមផលិតកម្មបានទេ ។ មួយចំណែកធំនៃធាតុចូលផលិតកម្មជាទំនិញនាំចូល ។ បន្ទុកចំណាយលើទំនិញទាំងនេះ មិនអាចកាត់បន្ថយនៅក្នុងស្រុកបានទេ ពីព្រោះវាអាស្រ័យលើកំរិតថ្លៃនៅទីផ្សារពិភពលោក ។ ប្រាក់បៀវត្សរ៍ប្រចាំខែអប្បបរមា ៤៥ដុល្លារ របស់កម្មកររោងចក្រកាត់ដេរ វាស្ថិតនៅខាងក្រោមកំរិតចិញ្ចឹមជីវិតគ្រាន់តែមួយរស់ (៨០ដុល្លារ) ។ ប្រាក់បៀវត្សរ៍មិនអាចកាត់បន្ថយបានទេ បើសិនចង់កាត់បន្ថយថ្លៃដើមផលិតកម្ម ។ ប៉ុន្តែមានលទ្ធភាពមួយ ដើម្បីកាត់បន្ថយថ្លៃធាតុចូលក្នុងស្រុក ។

ថ្លៃអគ្គិសនី ការដឹកជញ្ជូន និងការិយាធិបតេយ្យ ត្រូវតែកាត់បន្ថយ ។ ថ្លៃអគ្គិសនីនៅកម្ពុជា គឺ ០,១២-០,១៦ដុល្លារ/គីឡូវ៉ាត់ រឺ៤ដង ខ្ពស់ជាងនៅ

ថៃ និងវៀតណាម[៤] ។ ការដឹកជញ្ជូនកុងតឺន័រមួយទៅកាន់កំពង់ផែ ត្រូវចំណាយប្រហែល ៥០០ដុល្លារ រឺ ៤,១ដង ខ្ពស់ជាងនៅវៀតណាម[៥] ។ ចំណាយចំបងមួយទៀត ដែលឧស្សាហកម្មកាត់ដេរត្រូវប្រឈម គឺការិយាធិបតេយ្យ ។ លោក វ៉ាន់ ស៊ូ អ៊ាង[៥] ប្រធានសមាគមរោងចក្រកាត់ដេរនៅកម្ពុជា បានលើកពីផលប៉ះពាល់នៃចំណាយនេះដូចតទៅ: "ខ្ញុំសូមនិយាយម្ដងទៀត ហើយខ្ញុំហត់នឿយនឹងនិយាយដដែលៗថា ការស៊ីសំណូកការិយាធិបតេយ្យ និងអំពើពុករលួយ កំពុងរាំងស្ទះដល់ឧស្សាហកម្មកាត់ដេរ" (ឃែមបូឌាដេលី ច្បាប់ចេញថ្ងៃទី១៣ កុម្ភៈ ២០០៤ ទំព័រ១) ។

## សរុបសេចក្ដី

អង្គការ WTO នេះផ្ទាល់មិនចោទបញ្ហាអ្វីដល់កម្ពុជាទេ ប៉ុន្តែវាបង្កើតបញ្ហាប្រឈមថា តើកម្ពុជាត្រូវធ្វើយ៉ាងណាដើម្បីអាចទទួលបានផលចំណេញពីសមាជិកភាពរបស់ខ្លួន ។ រឿងនេះ តំរូវឱ្យមានការប្ដេជ្ញាចិត្តកាត់បន្ថយថ្លៃដើមផលិតកម្ម ដែលអាចធ្វើបានតាមរយៈការបង្កើនផលិតភាពនៃកំលាំងពលកម្ម និងការកាត់បន្ថយចំណាយលើការិយាធិបតេយ្យ ។ ផលិតភាពនៃកំលាំងពលកម្ម អាចបង្កើនបានតាមរយៈការប្រើប្រាស់មូលធន និងការពង្រឹងកំរិតជំនាញ ។ សមត្ថភាពដើម្បីដាក់ប្រើបច្ចេកវិទ្យាថ្មី វាអាស្រ័យទៅលើកំរិតអប់រំរបស់កម្មករ ។ ការប្រើមូលធនកាន់តែច្រើន វាជួយបង្កើនផលិតភាពកំលាំងពលកម្មក្នុងមួយរយៈដំបូង ប៉ុន្តែអាចបង្កភាពអត់ការងារធ្វើ ពីព្រោះទ្រព្យមូលធន (ម៉ាស៊ីន) អាចចូលមកជំនួសកំលាំងពលកម្ម ។ ដូច្នេះ ដើម្បីបង្កើនផលិតភាព អាទិភាពទី១ គឺកាត់បន្ថយចំណាយលើថាមពល ការដឹកជញ្ជូន និងការិយាធិបតេយ្យ ព្រមទាំងជំរុញការកសាងសមត្ថភាពកម្មករ ។ ដើម្បីសំរេចគោលដៅនេះ ត្រូវមានអន្តរាគមន៍យ៉ាងខ្លាំងក្លាពីរដ្ឋ ប៉ុន្តែវាប្រហែលត្រូវទទួលបរាជ័យ បើសិនកំណែទំរង់រដ្ឋបាលសាធារណៈគ្មានការរីកចំរើនទេនោះ ។ ដូច្នេះកម្ពុជានឹងទទួលផលចំណេញបានច្រើនប៉ុណ្ណាពីសមាជិកភាពក្នុង WTO វាស្ថិតក្រោមការគ្រប់គ្រងរបស់កម្ពុជាខ្លួនឯងជាពិសេសគឺការគ្រប់គ្រងរបស់រដ្ឋាភិបាល ។

## កំណត់សំគាល់

១. ពាក្យ "សាកលភាវូបនីយកម្ម" អាចយល់បានថាជាសមាហរណកម្មនៃប្រព័ន្ធសេដ្ឋកិច្ច នយោបាយ វប្បធម៌ និងបរិស្ថាន ។ ពាណិជ្ជកម្មសេរីគឺជាទំរង់ពិសេសមួយនៃសមាហរណកម្មសេដ្ឋកិច្ច ។
២. មធ្យមភាគនៃការនាំចេញសំលៀកបំពាក់ ធៀបនឹងការនាំចេញសរុបនៅកំឡុងឆ្នាំ ១៩៩៨-២០០២ ។
៣. យោងតាមទិន្នន័យ ផ្ដល់ដោយគណៈកម្មាធិការវិនិយោគកម្ពុជានៅឆ្នាំ ១៩៩៩- ២០០២ ។

---

តពីទំព័រ ៤ **គួរឱ្យក្រុមប្រឹក្សាឃុំធ្វើ...**

សមត្ថភាពខាងហិរញ្ញវត្ថុនិងបច្ចេកទេសរបស់អាជ្ញាធរមូលដ្ឋានទៅទៀត ។

## កំណត់សំគាល់

១. ការចុះសិក្សាដល់កន្លែងបានធ្វើឡើងនៅ ៤ឃុំ ក្នុង ២ខេត្តគឺ ពោធិសាត់ និងសៀមរាប នៅខែឧសភា ២០០៦ និងរួមមានបទសំភាសន៍ជាមួយសមាជិកគណៈកម្មការរបស់សហគមន៍ព្រៃឈើ ក្រុមប្រឹក្សាឃុំ មន្ត្រីរដ្ឋាភិបាល បុគ្គលិក FAO SEILA និង Danida នៅថ្នាក់ខេត្ត និងថ្នាក់ជាតិ ព្រមទាំងតំណាងអង្គការ CONCERN និង CFR ។ ការចុះសិក្សានេះគឺជាជំហានទី១ ក្នុងគំរោងសហការស្រាវជ្រាវរវាង វិបសអ និងមជ្ឈមណ្ឌលដាណឺមាកសំរាប់ព្រៃឈើ ទេសភាព និងផែនការ ។
២. ការគ្រប់គ្រងតំបន់ការពាររបស់សហគមន៍ បានអនុវត្តនៅក្នុងឧទ្យានជាតិ និងជាការទទួលខុសត្រូវរបស់ក្រសួងបរិស្ថាន (Oberndorf 2005) ។

## ឯកសារយោង

Agrawal, A. and C. C. Gibson (1999), “Enchantment and disenchantment: the role of community in natural resource conservation”. *World Development,* 27, pp. 629–649

Danida/DFID (2006), Natural Resource Management and Livelihoods Programme Cambodia (2006-2010). Programme Document 7 April (Cambodia: Danish Ministry of Foreign Affairs and Department for International Development).

FAO 2005. Global Forest Resources Assessment 2005, Cambodia, (Rome: Food and Agriculture Organization)

Heov K.S., B. Khlok, K. Hansen & C. Sloth (2006), “The value of forest resources to rural livelihoods in Cambodia”. CDRI Policy Brief, March, issue 2

Hobley, M. (2004), Players in the sector: civil society, private sector and donor agencies. Chapter 12 (the forest sector in Cambodia, Part II. Current context. (Cambodia: Independent forest sector review team report commissioned by the Joint Coordinating Committee, Forest Administration).

Hobley, M. (ed.) (1996), “Participatory forestry: the process of change in India and Nepal”. Rural development forestry study guide 3 (London: Rural Development Forestry Network, Overseas Development Institute)

Hobley, M. & M. Boscolo (2004), Policy formulation and implementation. Policy goals, regulatory control, fiscal incentives and public participation (Cambodia: Independent forest sector review team report commissioned by the Joint Coordinating Committee, Forest Administration).

IFSR (2004), The forest sector in Cambodia, Part I. Policy choices, issues and options. (Cambodia: Independent forest sector review team report commissioned by the Joint Coordinating Committee, Forest Administration).

Larson, A.M. (2003), “Decentralisation and forest Management in Latin America: Towards a Working Model”, *Public Administration and Development,* 23, pp. 211–226

Marona, S., H. Kalyan & R. Kinakin (2005), “Lessons learned from CBRNM in Cambodia: drawing upon examples from case studies”, Rotha, K.S., T. Carson, K. Riebe, S. Cox & E.V. Kaschke (eds.), *The Development of Community Based Natural Resource Management (CBNRM) in Cambodia. Selected Papers on Concepts and Experiences,* CBNRM Learning Initiative, CBRNM Learning Institute and WWF, Cambodia.

McKenney, B., Y. Chea, P. Tola & T. Evans (2004), *Focusing on Cambodia's High Value Forests: Livelihoods and Management* (Phnom Penh: CDRI and Wildlife Conservation Society)

Oberndorf, R. (2005), “Overview of the policy and legal framework related to CBNRM”, in Rotha, K.S., T. Carson, K. Riebe, S. Cox & E.V. Kaschke (eds.), *The development of community based natural resource management (CBNRM) in Cambodia. Selected papers on concepts and experiences,* CBNRM Learning Initiative, CBRNM Learning Institute and WWF, Cambodia.

Oberndorf, R. (2004), *Law harmonisation in relation to the decentralisation process in Cambodia.* Working Paper No. 31 (Phnom Penh: Cambodia Development Resource Institute)

RGC (2003), *Sub-decree on community forestry*. (Phnom Penh: Royal Government of Cambodia).

RGC/CFO (2006). “National community forestry programme (NCFP) strategic paper”. Draft strategic paper elaborated by the

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្រៅប្រទេស

## កំណើនសេដ្ឋកិច្ចពិភពលោក

ក្នុងកំឡុងពេលត្រីមាសទី២ ២០០៦ ផសស ពិតរបស់ US កើនបាន ២,៦% ធៀបនឹងមួយឆ្នាំមុន និងធ្លាក់ចុះពីកំណើន ៥,៦% នៅត្រីមាសទី១ ២០០៦ ។ ការធ្លាក់ចុះកំណើន ផសស នៅត្រីមាសទី២ បណ្ដាលជាសំខាន់មកពីរការធ្លាក់ចុះចំណាយប្រើប្រាស់លើទំនិញជាប់លាប់ វិនិយោគលើគ្រឿងបរិក្ខារនិងសូហ្វវែរ និងការចំណាយរបស់រដ្ឋាភិបាលសហព័ន្ធ ។

ផសស ពិតនៅតំបន់អឺរ៉ូ នៅត្រីមាសទី២ ២០០៦ កើនបាន ២,៤% ធៀបនឹងពេលដូចគ្នាឆ្នាំមុន និងកើនបាន ០,៩% ធៀបនឹងត្រីមាសមុន ។ ផសស ពិតរបស់ជប៉ុន កើនបាន ២,២% ធៀបនឹងមួយឆ្នាំមុន និងកើនបាន ០,២% ធៀបនឹងត្រីមាសមុន ។

កំណើនសេដ្ឋកិច្ចនៅចិន បានបំបែកឯកទត្តកម្មកំណើនខ្ពស់បំផុតនៅត្រីមាសទី ២ ។ អត្រាកំណើនប្រចាំឆ្នាំ នៅត្រីមាសទី២ ២០០៦ គឺ ១១,៣% ធៀបនឹងកំណើន ១០,៩% នៅត្រីមាសមុន ។ វិស័យឧស្សាហកម្ម បន្តមានកំណើនក្នុងអត្រាខ្ពស់ជាងវិស័យសេវាកម្ម និងវិស័យកសិកម្ម ខណៈដែលវិនិយោគនៅតែមានកំណើនធំជាងគេ ។ ផសស ពិត នៅកូរ៉េខាងត្បូងនៅត្រីមាសទី២ កើនបាន ៥,៣% ធៀបនឹងមួយឆ្នាំមុន ធៀបនឹងកំណើន ៦,១% នៅត្រីមាសមុន ។ ផសស ពិត នៅតៃវ៉ាន់ និងហុងកុង នៅត្រីមាសទី ២ ២០០៦ កើនបាន ៤,៦% និង ៥,២% ធៀបនឹងពេលដូចគ្នាឆ្នាំមុន ។

សេដ្ឋកិច្ចម៉ាឡេស៊ី នៅត្រីមាសទី២ ២០០៦ កើនបាន ៥,៩% ធៀបនឹងកំណើន ៥,៥% នៅត្រីមាសមុន ។ នៅផ្នែកខាងផលិតកម្ម ធៀបនឹងមួយឆ្នាំមុន វិស័យឧស្សាហកម្មផលិត និងវិស័យសេវាកម្ម មានអត្រាកំណើនយ៉ាងខ្ពស់ដល់ទៅ ៨,៤% និង ៦,០% ។ នៅខាងផ្នែកចំណាយទុនអចល័តដុល និងចំណាយប្រើប្រាស់ឯកជន កើនបាន ៧,៦% និង ៧,៣% ធៀបនឹងមួយឆ្នាំមុន ។ សេដ្ឋកិច្ចសិង្ហបុរី នៅត្រីមាសទី២ ២០០៦ កើនបាន ៨,០% ធៀបនឹងពេលដូចគ្នា ឆ្នាំ២០០៥ ។ ឧស្សាហកម្មផលិត កើនបាន ១២,២% រីឯសេវាកម្ម កើនបាន ៦,៩% ។ ផសស ពិត នៅថៃ នៅត្រីមាសទី២ កើនបាន ៤,៩% ធៀបនឹងពេលដូចគ្នាឆ្នាំ២០០៥ ។ កំណើនវិស័យកសិកម្មនៅត្រីមាសទី២ គឺ ៥,៤% ធៀបនឹងកំណើន ៦,៣% នៅត្រីមាសទី១ ។ វិស័យមិនមែនកសិកម្ម កើនបាន ៤,៨% ធៀបនឹងមួយឆ្នាំមុន ប៉ុន្តែទាបជាងកំណើន ៦,១% នៅត្រីមាសមុន ។

## អតិផរណាក្នុងពិភពលោក និងអត្រាប្តូរប្រាក់នៅទីផ្សារអន្តរជាតិ

ថ្លៃថាមពល គឺជាកត្តាមួយក្នុងចំណោមកត្តាសំខាន់ជាច្រើន ដែលធ្វើឱ្យមានការវិវត្តន៍ថ្លៃទំនិញប្រើប្រាស់ក្នុងសេដ្ឋកិច្ចធំបងៗលើពិភពលោក នៅកំឡុងត្រីមាសទី២ ។ ថ្លៃទំនិញប្រើប្រាស់នៅ US កើន ៤,០% ក្នុងរយៈមួយឆ្នាំរហូតដល់ត្រីមាសទី២ ដែលសំខាន់បណ្ដាលមកពីការឡើងថ្លៃថាមពល ។ នៅតំបន់អឺរ៉ូ អតិផរណាមានកំរិត ២,៣% គឺខ្ពស់ជាងកំរិតអតិផរណាអតិបរមាកំណត់ដោយធនាគារកណ្ដាលអឺរ៉ុប (២%) ។ រឿងនេះ ឆ្លុះបង្ហាញពីកំណើនថ្លៃថាមពល និងកំណើនថ្លៃម្ហូបអាហារមិនទាន់កែច្នៃ ។ បំរែបំរួលពីមួយឆ្នាំទៅមួយឆ្នាំនៃថ្លៃទំនិញប្រើប្រាស់នៅជប៉ុន មានកំណើន ០,៧% ដោយសារតែថាមពល ឡើងថ្លៃ ។ នៅចិន កូរ៉េខាងត្បូង និងសិង្ហបុរី អតិផរណាមានកំរិត ១,៤% ១,២% និង ២,៣% នៅត្រីមាសទី២ ។

នៅទីផ្សារប្ដូរប្រាក់បរទេស ដុល្លារUS បន្តធ្លាក់ថ្លៃទល់នឹងរូបិយវត្ថុធំបងៗ ។ ទល់នឹងប្រាក់យ៉េនជប៉ុន ដុល្លារប្ដូរបាន ១១៤,៥យ៉េន/ដុល្លារUS ហើយទល់នឹងអឺរ៉ូ វាប្ដូរបាន ០,៨០អឺរ៉ូ/ដុល្លារUS ដោយធ្លាក់ថ្លៃពី ១១៦,៩យ៉េន/ដុល្លារUS និង ០,៨៣អឺរ៉ូ/ដុល្លារUS នៅត្រីមាសទី១ ។ ទល់នឹងវ៉ុនកូរ៉េខាងត្បូង និងយ៉ុនចិន វាប្ដូរបាន ៩៤៩វ៉ុន/ដុល្លារUS និង ៨,០១យ៉ុន/ដុល្លារUS ដោយធ្លាក់ថ្លៃពី ៩៧៦វ៉ុន/ដុល្លារUS និង ៨,០៥យ៉ុន/ដុល្លារUS នៅត្រីមាសមុន ។ ដុល្លារបានធ្លាក់ថ្លៃ ដោយសារការវាយស្មានថា ធនាគារកណ្ដាលអឺរ៉ុប នឹងបង្កើនអត្រាការប្រាក់ឱ្យខ្ពស់ជាង ធនាគារកណ្ដាលអាមេរិក និងបន្ទាប់ពីមានការស្នើសុំរបស់អាមេរិកឱ្យតំឡើងថ្លៃរូបិយវត្ថុអាស៊ីសំខាន់ៗ ។

## ថ្លៃផលិតផលនៅលើទីផ្សារពិភពលោក

នៅត្រីមាសទី២ ២០០៦ ថ្លៃអង្ករ ពោត ប្រេងឆា សាំង និងប្រេងឆៅកើនឡើង ប៉ុន្តែថ្លៃសណ្ដែកសៀង បែរជាធ្លាក់ចុះ ។ ថ្លៃអង្ករ Thai 100% លេខ ២ នៅទីផ្សារបាងកក គឺ ២៨៣,៨៦ដុល្លារ/តោន ធៀបនឹង ២៧៥,១២ដុល្លារ/តោន នៅត្រីមាសទី១ ។ ប្រេងឆាលក់ថ្លៃ ៣៩៧,៨៧ដុល្លារ/តោន ធៀបនឹង ៣៩៥,៧៥ដុល្លារ/តោន នៅត្រីមាសទី១ រីឯពោតលក់ថ្លៃ ៩៩,៩៥ដុល្លារ/តោន ធៀបនឹង ៩៥,៣៧ដុល្លារ/តោន នៅត្រីមាសទី១ ។ ថ្លៃសណ្ដែកសៀងនៅត្រីមាសទី២ ធ្លាក់ចុះអស់ ១,៩%

**តារាង១. កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០១-២០០៦ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)**

| | 2001 | 2002 | 2003 | 2004 | 2005 | | | 2006 | | 2005 |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q2 | Q3 | Q4 | Q1 | Q2 | |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | 6.7 | 4.8 | 7 | 7.7 | - | - | - | - | - | 13.4 |
| ឥណ្ឌូនេស៊ី | 3.8 | 3.8 | 4.9 | 5.1 | 5.5 | 5.3 | 4.9 | 4.6 | 5.2 | 5.6 |
| ម៉ាឡេស៊ី | 0.5 | 5.6 | 5.4 | 7 | 4.4 | 5.3 | 5.2 | 5.5 | 5.9 | 5.2 |
| សិង្ហបុរី | -2.3 | 2.6 | 1.4 | 8.5 | 5.4 | 7 | 7.7 | 10.7 | 8.0 | 5.7 |
| ថៃ | 1.9 | 6.1 | 6.9 | 6 | 4.6 | 5.3 | 4.7 | 6.0 | 4.9 | 4.5 |
| វៀតណាម | 6.0 | 6.7 | 7 | 7.5 | - | - | - | - | - | 8.4 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | 7.5 | 8.1 | 9.9 | 9.5 | 9.5 | 9.4 | 9.9 | 10.9 | 11.3 | 9.6 |
| ហុងកុង | 0.5 | 5.0 | 3.2 | 8.3 | 7.3 | 8.2 | 7.6 | 8.2 | 5.2 | 6.5 |
| កូរ៉េខាងត្បូង | 3.0 | 6.1 | 3 | 4.7 | 3.3 | 4.4 | 5.2 | 6.1 | 5.3 | 4.7 |
| តៃវ៉ាន់ | -2.2 | 4.2 | 3.1 | 5.7 | - | - | 6.0 | 4.9 | 4.6 | - |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ូ-១២ | 1.4 | 0.7 | 0.5 | 1.8 | 1.2 | 1.5 | 1.8 | 2.0 | 2.4 | 1.5 |
| ជប៉ុន | 0.4 | 0.4 | 2.6 | 3.4 | 1.4 | 2.9 | 4.5 | 3.0 | 2.2 | 2.5 |
| សហរដ្ឋអាមេរិក | 1.2 | 2.4 | 3.1 | 4.4 | 3.3 | 4.1 | 1.1 | 5.6 | 2.6 | 3.0 |

*Sources: Economist, countries' national statistics offices and central banks and ADB's Asia Regional Information Centre*

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្រៅប្រទេស

មកត្រឹម ២០៧,០២ដុល្លារ/តោន ។ ថ្លៃប្រេងឆៅ និងសាំង កើនឡើង យ៉ាងខ្លាំងដល់ ១២% និង ៣៦% ធៀបនឹងត្រីមាសមុន ។ ប្រេងឆៅលក់ថ្លៃ ៦៥,០៣ដុល្លារ/ធុង ហើយសាំងលក់ថ្លៃ ៥៥,៨៩សេន/លីត្រ ។

*រៀបរៀងដោយ ហ៊ីង វុត្ថា និង ភឹម រុនស៊ីណារិទ្ធិ*

**តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០១-២០០៦ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)**

| | 2001 | 2002 | 2003 | 2004 | 2005 | | | 2006 | | 2005 |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q2 | Q3 | Q4 | Q1 | Q2 | |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | -0.6 | 3.2 | 1.2 | 4.0 | 6.4 | 4.6 | 6.6 | 5.9 | 4.5 | 5.8 |
| ឥណ្ឌូនេស៊ី | 11.5 | 13.2 | 8.3 | 8.3 | 10.8 | 12 | 17.3 | - | 23.4 | 10.5 |
| ម៉ាឡេស៊ី | 1.4 | 1.8 | 1.1 | 1.6 | 3.0 | 3.4 | 3.4 | 3.9 | 4.1 | 3.1 |
| សិង្ហបុរី | 1.0 | -0.4 | 0.5 | 1.7 | 0.1 | 0.5 | 1.1 | 1.1 | 1.2 | 0.5 |
| ថៃ | 1.7 | 0.6 | 1.8 | 2.7 | 3.7 | 5.6 | 6.0 | 5.7 | 6.0 | 4.5 |
| វៀតណាម | -0.4 | 3.8 | 3.2 | 8.3 | 8.0 | 7.5 | - | - | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | 0.9 | -0.7 | 1.2 | 3.9 | 1.7 | 1.3 | 1.4 | 1.2 | 1.4 | 1.8 |
| ហុងកុង | -1.3 | -3.0 | -2.6 | -0.4 | 0.8 | 1.4 | 1.8 | 2.0 | 2.1 | 1.1 |
| កូរ៉េខាងត្បូង | 4.4 | 2.7 | 3.5 | 3.5 | 3.0 | 2.4 | 2.5 | 2.4 | 2.3 | 2.8 |
| តៃវ៉ាន់ | -0.01 | -0.2 | -0.3 | 1.6 | 2.1 | - | 2.4 | - | 1.5 | - |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ូ-១២ | 2.6 | 2.2 | 2.1 | 2.2 | 2.1 | 2.3 | 2.4 | 2.3 | 2.3 | 2.2 |
| ជប៉ុន | -0.6 | -0.9 | -0.3 | Nil | -0.1 | -0.3 | -0.5 | 0.4 | 0.7 | -0.3 |
| សហរដ្ឋអាមេរិក | 2.8 | 1.6 | 2.3 | 2.7 | 2.9 | 3.8 | 3.7 | 3.7 | 4.0 | 3.4 |

*Sources: International Monetary Fund, Economist and National Institute of Statistics*

**តារាង៣. អត្រាប្ដូរប្រាក់ធៀបនឹងដុល្លារនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០១-២០០៦ (មធ្យមភាគតាមការិយបរិច្ឆេទ)**

| | 2001 | 2002 | 2003 | 2004 | | 2005 | | 2006 | | 2005 |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q2 | Q3 | Q4 | Q1 | Q2 | |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា (រៀល) | 3,916.3 | 3,912.1 | 3,973 | 4,016.3 | 4,054.3 | 4,134.3 | 4,154.3 | 4,081.3 | 4,095.3 | 4,092.5 |
| ឥណ្ឌូនេស៊ី (រូពីយ៉ា) | 10,261 | 9,311 | 8,577 | 8,938 | 9,550 | 9,994 | 9,999 | 9,175 | 9,115 | 9,705 |
| ម៉ាឡេស៊ី (រីងហ្គិត) | 3.80 | 3.80 | 3.80 | 3.80 | 3.80 | 3.77 | 3.78 | 3.73 | 3.65 | 3.79 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.79 | 1.79 | 1.74 | 1.69 | 1.66 | 1.68 | 1.69 | 1.63 | 1.59 | 1.66 |
| ថៃ (បាត) | 44.4 | 42.9 | 41.5 | 40.2 | 40.1 | 41.3 | 41.02 | 39.3 | 38.1 | 40.2 |
| វៀតណាម (ដុង) | 14,725 | 15,280 | 15,510 | - | 15,842 | 15,878 | 15,907 | 15,921 | - | 15,859 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន (យ៉ន់) | 8.28 | 8.28 | 8.28 | 8.28 | 8.28 | 8.14 | 8.08 | 8.05 | 8.01 | 8.19 |
| ហុងកុង (ដុល្លារហុងកុង) | 7.80 | 7.80 | 7.78 | 7.79 | 7.79 | 7.77 | 7.75 | 7.76 | 7.76 | 7.78 |
| កូរ៉េខាងត្បូង (វ៉ុន) | 1,291 | 1,251 | 1,192 | 1,145 | 1,008 | 1,029 | 1,036 | 976 | 949 | 1,024 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 33.8 | 34.5 | 34.4 | 33.6 | 31.4 | 32.3 | 33.4 | 32.3 | 32.2 | 32.1 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 1.12 | 1.06 | 0.89 | 0.80 | 0.79 | 0.81 | 0.84 | 0.83 | 0.80 | 0.80 |
| ជប៉ុន (យ៉េន) | 121.5 | 125.4 | 115.9 | 108.2 | 107.4 | 111.2 | 117.2 | 116.9 | 114.5 | 110.2 |

*Sources: International Monetary Fund, Economist and National Bank of Cambodia*

**តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០០១-២០០៦ (មធ្យមភាគតាមការិយបរិច្ឆេទ)**

| | 2001 | 2002 | 2003 | 2004 | | 2005 | | 2006 | | 2005 |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q2 | Q3 | Q4 | Q1 | Q2 | |
| ពោត (US No. 2) - US ($/តោន) | 81.18 | 89.98 | 95.42 | 110.65 | 87.53 | 90.61 | 90.64 | 95.37 | 99.95 | 89.19 |
| ប្រេងឆា- អឺរ៉ុបពាយព្យ ($/តោន) | 259.13 | 353.91 | 402.03 | 427.47 | 382.48 | 376.41 | 391.52 | 395.75 | 397.87 | 381.32 |
| កៅស៊ូ - ម៉ាឡេស៊ី ($/តោន) | 602.0 | 768.3 | 1050 | 1252.2 | - | - | - | - | - | - |
| អង្ករ (Thai 100%B) - បាងកក ($/តោន) | 160.81 | 178.59 | 182.22 | 221.67 | 268.20 | 255.77 | 259.40 | 275.12 | 283.86 | 262.88 |
| សណ្ដែកសៀង (US No. 1) - US ($/តោន) | 163.89 | 182.58 | 218.86 | 262.03 | 263.66 | 214.37 | 210.42 | 210.96 | 207.02 | 224.25 |
| ប្រេងឆៅ-ឌូបៃ ($/ធុង) | 22.8 | 23.9 | 26.8 | 33.5 | 47.7 | 57.27 | 52.99 | 57.89 | 65.03 | 50.14 |
| សាំង - US Gulf coast (សេន/លីត្រ) | 19.5 | 19.1 | 23 | 30.9 | 39.7 | 52.37 | 42.29 | 41.18 | 55.89 | 42.19 |

*Sources: Food and Agriculture Organisation and US Energy Information Administration.*
*Note: All prices have been converted from US$/ton to US$/tonne. 1 ton = 0.907 tonne.*

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

នៅឆ្នាំ២០០៥ កម្ពុជាធ្លាប់មានកំណើន ផសស យ៉ាងខ្ពស់ គឺកំណើនពិត ១៣,៤% ។ ទោះបីជាសេដ្ឋកិច្ចមានកំណើនខ្ពស់ក្ដី ទំនាក់ទំនងរវាងកំណើន ហេដ្ឋារចនាសម្ព័ន្ធ និងការវិនិយោគ ទៅនឹងការកាត់បន្ថយភាពក្រីក្រ មានកំរិតតិចតួចប៉ុណ្ណោះ ។ នៅត្រីមាសទី២ ២០០៦ វិនិយោគឯកជននៅកម្ពុជា និងសកម្មភាពសាងសង់ កើនឡើង រីឯចំនួនភ្ញៀវបរទេស បែរជាធ្លាក់ចុះ ហើយនៅពេលជាមួយគ្នានោះ ពាណិជ្ជកម្មមានឱនភាពកាន់តែខ្លាំង ។

វិនិយោគក្នុងវិស័យឯកជន បានផ្ដល់ការងារមួយចំនួនធំដល់ប្រជាជនកម្ពុជាអស់ជាច្រើនឆ្នាំមកហើយ ពិសេសក្នុងវិស័យឧស្សាហកម្ម (កាត់ដេរ) និងសេវាកម្ម (សណ្ឋាគារ) ។ ទាំងវិស័យឧស្សាហកម្ម និង សេវាកម្ម មានការរីកលូតលាស់ខ្លាំងតែនៅទីក្រុងភ្នំពេញ និងខេត្តសៀមរាបប៉ុណ្ណោះ ។ តំបន់ជនបទ និងទីក្រុងនៅកម្ពុជា ពឹងផ្អែកលើគ្នាទៅវិញទៅមក ដោយប្រជាជនជនបទធ្វើចំណាកស្រុកទៅទីក្រុងដើម្បីស្វែងរកការងារធ្វើ ប៉ុន្តែសេដ្ឋកិច្ចទីក្រុង ក៏ពឹងផ្អែកវិញដែរ លើតំបន់ជនបទសំរាប់កំលាំង ពលកម្ម និងផលិតផលកសិកម្ម ជាពិសេសម្ហូបអាហារ ។ នៅត្រីមាសទី២ ២០០៦ គំរោងវិនិយោគឯកជនបានអនុម័ត កើនដល់ ២៣៣៧,០លានដុល្លារ រឺច្រើន-ជាង នៅត្រីមាសមុន ១០ដង ។ កំណើនយ៉ាងខ្លាំងនេះ បណ្ដាលមកពីគំរោងអនុម័តក្នុងវិស័យសេវាកម្ម ដែលកើនដល់ ២០៤៣,២លានដុល្លារ រឺស្មើនឹង ៣៤ដង នៃតួលេខនៅត្រីមាសមុន ។ វិស័យសេវាកម្ម រីកលូត-លាស់ដោយសារវិស័យទេសចរណ៍ និងសកម្មភាពសាងសង់ក្នុងវិស័យនេះ ។ កំណើនគំរោងអនុម័តក្នុង វិស័យសេវាកម្ម នាំមុខគេដោយការអនុមតិគំរោងសាងសង់ គឺ ២០១៧,០លានដុល្លារ ។ នៅត្រីមាសទី២ គំរោងអនុម័តក្នុងវិស័យកសិកម្ម កើនបាន ៧១% ធៀបនឹងត្រីមាសមុន ដល់ ២១៦,៩លានដុល្លារ និងគំរោង អនុម័តក្នុងវិស័យឧស្សាហកម្ម កើនបាន ៩២% ដល់ ៧៦,៩លានដុល្លារ ទោះបីជាគំរោងអនុម័តក្នុងវិស័យកាត់ដេរ ធ្លាក់ចុះអស់ ៦៩% មកត្រឹម ៩,៦លានដុល្លារ ក៏ដោយ ។

បន្ទាប់ពីធ្លាក់ចុះអស់ជាច្រើនត្រីមាស ការអនុមតិគំរោង-សាងសង់នៅភ្នំពេញ បានកើនឡើងវិញ នៅត្រីមាសទី២ ដោយមានកំណើន ២២% ធៀបនឹងត្រីមាសមុន ដល់ ៨២,២លានដុល្លារ ។ ការអនុម-តិសំណង់ផ្ទះល្វែង កើនបាន ៣០% ដល់ ៥១,៨លានដុល្លារ និងការអនុម-តិសំណង់ផ្សេងទៀត កើនបាន ៤២% ដល់ ២៤,៧លានដុល្លារ ។ ការអនុម-តិសំណង់ភូមិគ្រឹះ និងផ្ទះ នៅត្រីមាសទី២ ធ្លាក់ចុះអស់ ៤៤% ធៀបនឹងត្រី-មាសមុន ។ តាំងពី ឆ្នាំ២០០០ ការអនុមតិគំរោង-សាងសង់មានកំរិតខ្ពស់បំផុតនៅត្រីមាសទី២ ២០០៤ ។ នៅភ្នំពេញដែលជា-ទីក្រុងសំខាន់របស់កម្ពុជា គេឃើញមានសំណង់ថ្មីៗជាច្រើន ហើ-យសំណង់ចាស់ៗ ក៏មានការជួសជុលឡើងវិញផងដែរ ។ កំណើនប្រជាជនៅភ្នំពេញ បានធ្វើឱ្យទីក្រុងនេះរីកទំហំ ហើយគេឃើញមានអគារថ្មីៗនៅបរិវេណជាយក្រុង ។ កំណើនចំនួនភ្ញៀវមកទស្សនាកម្ពុជា ក៏ជាកត្តាបង្កើនសកម្មភាពសាងសង់ដែរ ដូចជា អគារទំនើបៗជាច្រើនត្រូវបានសាងសង់ (ឧ. តៀមស្រា និងភោជនីយដ្ឋាន នៅតាមបណ្ដោយ-មាត់ទន្លេ) ។ នៅតំបន់ផ្សេងទៀតក្រៅពីភ្នំពេញ ក៏ត្រូវមានសំណង់ថ្មីៗដែរ ពីព្រោះវាជួយបែងចែកផលចំណេញនៃការរីកចំរើនទៅគ្រប់ទីកន្លែងក្នុងផ្ទៃប្រទេស និងជួយកាត់បន្ថយចំនួនប្រជាជនរស់នៅភ្នំពេញ ។ កំណើនការអនុមតិគំរោងសាងសង់ភាគច្រើន បណ្ដាលមកពីកំណើនសេ-ដ្ឋកិច្ចដ៏ខ្ពស់នាពេលថ្មីៗ ។ កំណើននេះ ក៏ផ្ដល់ការងារនិងចំណូលកាន់តែច្រើនថែមទៀតដល់ប្រជាជន ជាពិសេសអ្នករស់នៅជនបទ ដែលមកភ្នំពេញធ្វើការជាកម្មករគ្មានជំនាញ ។ ដូច្នេះ កំណើនសកម្មភាពសាងសង់ គឺជាទិដ្ឋភាពសំខាន់នៃការអភិវឌ្ឍន៍សេដ្ឋកិច្ច ។ យោងតាមទិន្នន័យផ្ដល់ពីវិទ្យាស្ថានជាតិស្ថិតិ ចំនួនកម្មករសំណង់ និងកម្មកររោងចក្រនៅឆ្នាំ២០០៥ កើនលើសចំនួនកម្មករនៅឆ្នាំ២០០៤ ក្នុងអត្រាន ២០% (ដល់ ២៣៤.០០០នាក់) និង ៩,៥% (ដល់ ៧៨៩.០០០នាក់) ។

នៅត្រីមាសទី២ ភ្ញៀវមកសំរាកលំហែ បានថយចុះអស់ ២៧% មកត្រឹម ២៩២.៦៨២នាក់ ទោះបីនេះជាកំណើន ២១% ធៀបនឹងត្រីមាសដូចគ្នា ២០០៥ ក្ដី ។ ភ្ញៀវបរទេសសរុប បានថយចុះអស់ ២២% ធៀបនឹងត្រីមាសមុន មកត្រឹម ៣៥៨.០០០នាក់ ។ ភ្ញៀវមកតាមផ្លូវគោក និងផ្លូវទឹក ថយចុះអស់ ១៦% មកត្រឹម ១៥៣.៦០០នាក់ ហើយភ្ញៀវមកផ្លូវអាកាស ថយចុះអស់ ២៦% មកត្រឹម ២០៤.៤០០នាក់ ។ ក្នុងចំណោមភ្ញៀវមកតាមផ្លូវអាកាស ព្រលានយន្តហោះអន្តរជាតិភ្នំពេញ ទទួលបានភ្ញៀវ ៤៦% (៩៤.០២៤នាក់) រីឯព្រលានយន្តហោះសៀមរាប ទទួលបានភ្ញៀវ ៥៤% (១១០.៣៧៦នាក់) ។ ក្នុងចំណោមភ្ញៀវបរទេសសរុបមកកម្ពុជានៅត្រីមាសទី២ ភ្ញៀវមកសំរាកលំហែ មាន ៨២% ភ្ញៀវជាអ្នកជំនួញ ៧,៤% (២៦.៦៩២នាក់) ហើយចំនួននៅសល់ ជាភ្ញៀវមកក្នុងគោលបំណងផ្សេងទៀត ។ ជាទូទៅ ភ្ញៀវមកសំរាកលំហែ ថយចុះនៅត្រីមាសទី២ ហើយរំពឹងថា កើនឡើងបន្តិចវិញនៅត្រីមាសបន្ទាប់ ។ រដូវភ្ញៀវទេសចរច្រើនបំផុតនៅកម្ពុជា គឺនៅត្រីមាសទី១ (ខែមករា ដល់ ខែមីនា) ពីព្រោះអាកាសធាតុនៅអឌ្ឍគោលខាងជើង ជំរុញឱ្យអ្នកទេសចរមកកំសាន្តនៅតំបន់មានអាកាសធាតុក្ដៅ ។

ជញ្ជីងពាណិជ្ជកម្មក្រៅប្រទេសរបស់កម្ពុជា ជាទូទៅមានឱនភាព ។ នៅត្រីមាសទី២ ឱនភាពនេះ កើនឡើង ៤០% ដល់ ១២២,៤លានដុល្លារ ធៀបនឹងត្រីមាសមុន ។ ការនាំចេញមាន ៨៤% នៃការនាំចូល ធៀបនឹង ៨៧% នៅត្រីមាសមុន ។ ថ្វីបើការនាំចេញកើនឡើងនៅត្រីមាសទី២ តែវានៅមិនគ្រប់គ្រាន់ ដើម្បីទូទាត់ជាមួយការនាំចូល ។ ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០០៥ ឱនភាពពាណិជ្ជកម្មក្រៅប្រទេស ធ្លាក់ចុះអស់ ១៩% ។ នៅត្រីមាសទី២ ២០០៦ ការនាំចេញសរុបមាន ៦៥២,៥លានដុល្លារ រឺមានកំណើន ៨,២% ធៀបនឹងត្រីមាសមុន និងកំណើន ២៧% ធៀបនឹងត្រីមាសដូចគ្នា ២០០៥ ។ សំលៀកបំពាក់ដែលជាផលិតផលនាំចេញចំបង កើនបាន ១១% ដល់ ៦៣២,៤លានដុល្លារ ហើយក្នុងនោះ ការនាំចេញទៅ US កើនបាន ៨,៩% ដល់ ៤៣៨,៦លានដុល្លារ និងទៅតំបន់អឺរ៉ូ កើនបាន ២៩% ដល់ ១៤២,២លានដុល្លារ ។ ការនាំចេញផលិតផលកសិកម្ម ធ្លាក់ចុះអស់ ៤២% មកត្រឹម ២០,២លានដុល្លារ ក្នុងនោះការនាំចេញត្រី និងផលិតផលផ្សេងទៀត ធ្លាក់ចុះអស់ ៤៧% មកត្រឹម ១,០លានដុល្លារ និង ៦៩% មកត្រឹម ៧,០លានដុល្លារ ។ ការនាំចេញកៅស៊ូ និងឈើ កើនបាន ២៦% ដល់ ៩,៨លានដុល្លារ និង ៩,៥% ដល់ ២,៣លានដុល្លារ ។ កំណើនការនាំចេញសំលៀកបំពាក់ ជាមូលហេតុចំបងនាំឱ្យមានកំណើនការនាំចេញរបស់កម្ពុជា ។ កំណើនការនាំចេញសំលៀកបំពាក់ គឺជាលទ្ធផលនៃការវិនិយោគបន្ថែមក្នុងវិស័យឧស្សាហកម្មកាត់ដេរនៅកម្ពុជានៅប៉ុន្មានឆ្នាំកន្លងមកនេះ ។

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

ការនាំចូលសរុបនៅត្រីមាសទី២ ឡើងដល់ ៧៧៤,៩លានដុល្លារ វីកើន ១២% ធៀបនឹងត្រីមាសមុន និងកើន ១៦% ធៀបនឹងត្រីមាសដូចគ្នា ឆ្នាំ២០០៥ ។ ក្នុងចំណោមផលិតផលនាំចូលសំខាន់ៗ សាំងកើនបាន ១៤% ធៀបនឹងត្រីមាសមុន ដល់ ១២,៤លានដុល្លារ រីឯម៉ាស៊ូត បែរជាធ្លាក់ចុះ ០,៩% មកត្រឹម ៣២,២លានដុល្លារ ។ សំភារៈសំណង់ កើន ៥,៦% ដល់ ៣៩,១លានដុល្លារ ហើយការនាំចូលផ្សេងទៀត កើន ១៣% ដល់ ៦៩១,២លានដុល្លារ ។ កំណើនការនាំចូលសំភារៈសំណង់ បណ្តាលមកពីកំណើនសកម្មភាពសាងសង់នៅត្រីមាសនេះ ។ ការនាំចូលសាំង កើនឡើងដោយសារតំរូវការទីផ្សារ និងការឡើងថ្លៃសាំង (ប្រហែល ៧០ដុល្លារ/ធុង នៅខែមេសា ដល់មិថុនា) ។ នៅត្រីមាសនេះ ការនាំចូលសាំង កើន ១៥% ដល់ ៣៩.៨០០តោន រីឯម៉ាស៊ូត ធ្លាក់ចុះអស់ ០,៥% មកត្រឹម ១១៥.២០០តោន ។

**ហិរញ្ញវត្ថុសាធារណៈ**

ឱនភាពថវិការបស់រដ្ឋាភិបាល កើនឡើងនៅពីរត្រីមាសបន្តបន្ទាប់គ្នា ដោយនៅត្រីមាសទី២ កើន ១០% ដល់ ២៤៧,៤ពាន់លានរៀល ធៀបនឹងត្រីមាសមុន និងកើន ៣ដង ធៀបនឹងតួលេខនៅត្រី-មាសដូចគ្នា ២០០៥ ។ ទោះបីជាចំណូលសរុបកើនឡើងខ្លាំង នៅត្រីមាសទី២ក្តី ក៏វាបានតែ ៧៥% នៃចំណាយសរុបរបស់រដ្ឋាភិបាលប៉ុណ្ណោះ ។ ចំណូលចរន្ត កើន ២៣% ក្នុងនោះចំណូលពន្ធកើនបាន ១៥% ដល់ ៥៥៨,៦ពាន់លានរៀល ។ អាករលើតំលៃបន្ថែម និងពន្ធគយ នាំមុខគេក្នុងកំណើនចំណូលពន្ធ ដោយតំណាងឱ្យ ២៧% នឹង ៣៥% នៃចំណូលពន្ធសរុប ។ ចំណូលអាករលើតំលៃបន្ថែម កើនបាន ១៣% ដល់ ១៩៧,៤ពាន់លានរៀល ពន្ធគយ កើន ១២% ដល់ ១៥១,៧ពាន់លានរៀល និងអាករពិសេស កើន ២១% ដល់ ១០៣,០ពាន់លានរៀល ។ ការប្រមូលពន្ធផ្ទាល់ ក៏កើនឡើងដែរ ដោយពន្ធលើប្រាក់ចំណេញ កើនបាន ៩៣% ដល់ ៨៥,៩ពាន់លានរៀល រីឯការប្រមូលពន្ធលើប្រាក់បៀវត្សរ៍ បែរជាធ្លាក់ចុះអស់ ៧,៥% មកត្រឹម ១១,៣ពាន់លានរៀល ។ នៅត្រីមាសទី២ ចំណូលមិនមែនពន្ធ កើន ៥៥% ។ ចំណូលពីការកាប់ព្រៃឈើ កើនបាន ៤០% ដល់ ០,៧ពាន់លានរៀល ហើយចំណូលពីប្រៃសណីយ៍ និងទូរគមនាគមន៍ កើនជិត ៣ដង ដល់ ៣០,០ពាន់លានរៀល ។ ចំណូលមូលធនក្នុងស្រុក កើនបាន ៧០% ធៀបនឹងត្រីមាសមុន ដល់ ៤,៦ពាន់លានរៀល ។ កំណើនចំណូលមូលធនក្នុងស្រុកនេះ បានមកពីចំណូលមូលធនផ្សេងៗទៀត (មិនមានចំណូលពីឯកជនភាវូបនីយកម្មទេក្នុងកំឡុងពេលនេះ) ។ ទោះបីជាចំណូលថវិការដ្ឋ កើនឡើងក្នុងកំឡុងពេលនេះក្តី ចំណាយរបស់រដ្ឋាភិបាលក៏កើនឡើងដែរ ដូច្នេះ គេត្រូវការជំនួយបរទេសជាចាំបាច់សំរាប់ធ្វើឱ្យមានតុល្យភាពថវិកា ។ ជំនួយបរទេស កើនបាន ៦៨% ធៀបនឹងត្រីមាសមុន ដល់ ៣២៨,៦ពាន់លានរៀល ។

នៅត្រីមាសទី២ ២០០៦ ចំណាយរបស់រដ្ឋាភិបាល គិតជាសាច់ប្រាក់ កើន ១៩% ធៀបនឹងត្រីមាសមុន ដល់ ៩៧៨,៩ពាន់លានរៀល វីកើន ៣៧% ធៀបនឹងត្រីមាសដូចគ្នា ២០០៥ ។ ចំណាយក្នុងវិស័យអប់រំ និងសុខាភិបាល មានកំណើនដល់ ២០២,៣ពាន់លានរៀល វីកើន ២,៥ដង ធៀបនឹងត្រីមាសមុន ។ ចំណាយខាងសន្តិសុខ និងការពារជាតិ កើន ៤៩% ដល់ ១១៦,៧ពាន់លានរៀល រីឯចំណាយផ្សេងទៀត ធ្លាក់ចុះ ២១% មកត្រឹម ៣០៤,៥ពាន់លានរៀល ។ ចំណាយរបស់រដ្ឋាភិបាលលើវិស័យសុខាភិបាល និងការអប់រំ កើនឡើង ដោយសារមានគ្រោះធម្មជាតិ ដូចជា គ្រោះទឹកជំនន់ធ្ងន់ធ្ងរនៅ ខេត្តមួយចំនួន ។ ចំណាយមូលធន កើន ២៧% ធៀបនឹងត្រីមាសមុន ដល់ ៣៥៥,៤ពាន់លានរៀល ។ ចំណាយចរន្ត ត្រូវបានទូទាត់គ្រប់គ្រាន់ពីចំណូល ចរន្ត ។ ចំពោះចំណាយមូលធន រដ្ឋាភិបាលត្រូវការជំនួយបរទេស ។ នៅពេល អនាគត កម្ពុជានឹងពឹងផ្អែកកាន់តែតិចលើជំនួយបរទេស ពីព្រោះគេរំពឹងថានឹងទទួលបានចំណូលពីប្រេងកាត នៅឆ្នាំ២០១១ ។ ប្រសិទ្ធភាពនៃការប្រមូលចំណូលក្នុងស្រុកនៅទូទាំងប្រទេស ក៏រំពឹងថានឹងកើនឡើងដែរ ។

**អតិផរណា និងអត្រាប្តូរប្រាក់**

សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅភ្នំពេញ នៅត្រីមាសទី២ កើនបាន ៤,៥% ធៀបនឹងពេលដូចគ្នា ២០០៥ ប៉ុន្តែតិចជាងកំណើន ៦,១% នៅត្រីមាសទី១ ។

គ្រប់ទំនិញសំខាន់ៗក្នុងកន្ត្រកសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ សុទ្ធតែឡើងថ្លៃ ។ ថ្លៃម្ហូបអាហារ និងការដឹកជញ្ជូន កើនបាន ៦,៣% និង ១០% រីឯផលិត-ផលថែទាំកាយ និងការថែទាំសុខភាព កើនបាន ៥,៨% និង ០,៧% ។ ទោះបីជាកំណើនថ្លៃទំនិញសំខាន់ៗ ក្នុងកន្ត្រកសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់គិតក្នុងរយៈ ១២ខែដល់ត្រីមាសទី២ ទាបជាងកំណើន នៅត្រីមាសទី១ក្តី ក៏ថ្លៃទំនិញសំខាន់ៗទាំងអស់ នៅតែខ្ពស់ជាងនៅត្រីមាសមុន ។ រឿងនេះជាបញ្ហាសំរាប់ប្រជាជន ជាពិសេសសំរាប់អ្នក ក្រីក្រនៅពេលដែលថ្លៃទំនិញចាំបាច់នានាចេះ តែបន្តកើនឡើង ។

ប្រាក់រៀល ធ្លាក់ថ្លៃនៅត្រីមាសទី២ ប៉ុន្តែឡើងថ្លៃ ធៀបនឹងត្រីមាសទី៤ ២០០៥ ។ ប្រាក់រៀល ធ្លាក់ថ្លៃអស់ ០,៣% ទល់នឹងដុល្លារUS នៅត្រី-មាសទី២ ដោយ ប្តូរបាន ៤១០៦,៦រៀល/ដុល្លារ ធៀបនឹង ៤០៩៤,៨ រៀល/ដុល្លារ នៅត្រី មាសមុន ។ ទល់នឹងប្រាក់បាតថៃ ប្រាក់រៀលធ្លាក់ថ្លៃអស់ ៤,៣% មកត្រឹម ១០៨,០រៀល/បាត ។ ទល់នឹងប្រាក់ដុងវៀតណាម ប្រាក់រៀល មិនសូវមានការប្រែប្រួល ដោយប្តូរបាន ២៥,០រៀល/១០០ដុង ធៀបនឹង ២៥,៤រៀល/១០០ដុង នៅត្រីមាសមុន ។ ស្ថានភាពពាណិជ្ជកម្មរវាងកម្ពុជា និងប្រទេសផ្សេងទៀតមួយចំនួន បានធ្វើឱ្យប្រាក់រៀលធ្លាក់ថ្លៃ ។ ឧទាហរណ៍ ការនាំចូលទំនិញពីថៃ ធំជាងការនាំចេញ ដូច្នេះប្រាក់រៀល ធ្លាក់ថ្លៃទល់នឹង

*ប្រាក់រៀលធ្លាក់ថ្លៃជាបន្តបន្ទាប់ទល់នឹងប្រាក់ដុល្លារអាមេរិក ជំរុញឱ្យប្រជាជនកម្ពុជារក្សាទុកប្រាក់ដុល្លារអាមេរិកជាជាងប្រាក់រៀលរបស់ជាតិខ្លួន ។ ស្ថានភាពគ្មានលំនឹងរបស់ប្រាក់រៀល ធ្វើឱ្យប្រជាជនទុកចិត្តប្រាក់ដុល្លារអាមេរិកជាង ។*

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

ប្រាក់បាតថៃ ។ ប្រាក់រៀលដែលធ្លាក់ថ្លៃជាបន្តបន្ទាប់ទល់នឹងប្រាក់ដុល្លារUS ជំរុញឱ្យប្រជាជនកម្ពុជារក្សាទុកប្រាក់ដុល្លារ ជាជាងប្រាក់រៀលរបស់ជាតិខ្លួន ។ ស្ថានភាពគ្មានលំនឹងរបស់ប្រាក់រៀល ធ្វើឱ្យប្រជាជនទុកចិត្តប្រាក់ដុល្លារUS ជាង ។

## ការវិវត្តន៍រូបិយវត្ថុ

នៅត្រីមាសទី២ រូបិយវត្ថុទូទៅ M2 កើនបាន ៥,៨% ដល់ ៦០៤៤,០ពាន់លានរៀល រឺកើន ៣១% ធៀបនឹងពេលដូចគ្នាឆ្នាំមុន ។ រូបិយវត្ថុទូទៅ តំណាងឱ្យទ្រព្យសកម្មនៃប្រព័ន្ធរូបិយវត្ថុកម្ពុជា ដែលមានទ្រព្យសកម្ម បរទេសសុទ្ធ ឥណទានរដ្ឋាភិបាលសុទ្ធ ឥណនទានក្នុងវិស័យឯកជន និងឥណទានផ្សេងទៀត ។ ទ្រព្យសកម្មបរទេសសុទ្ធ កើនបាន ៤,២% ដល់ ៦៦៨២,០ពាន់លានរៀល រឺកើន ៣១% ធៀបនឹងមួយឆ្នាំមុន ។ ឥណទាន រដ្ឋាភិបាលសុទ្ធ បានបន្តធ្លាក់ចុះតាំងពីឆ្នាំ១៩៩៨ ។ នៅត្រីមាសទី២ ឥណទាន រដ្ឋាភិបាលសុទ្ធ ធ្លាក់ចុះអស់ ១០% មកត្រឹម -៨៣១,០ពាន់លានរៀល ដែលក្នុងនោះប្រាក់បញ្ញើរដ្ឋាភិបាល មាន ១១០៥,០ពាន់លានរៀល រឺកើន ៦,៩% ធៀបនឹងត្រីមាសមុន ។ ឥណទានក្នុងវិស័យឯកជន កើនដល់ ២៩៩៧,០ពាន់លានរៀល រឺកើន ៧,៨% ធៀបនឹងត្រីមាសមុន និង ៣៨% ធៀបនឹងមួយឆ្នាំមុន ។ ការប្រែប្រួលនៃទ្រព្យសកម្មបរទេសសុទ្ធ ឥណទាន រដ្ឋាភិបាលសុទ្ធ និងឥណទានក្នុងវិស័យឯកជន បណ្តាលឱ្យមានកំណើនរូបិយវត្ថុទូទៅ ។ ក្នុងករណីនេះ កំណើនទ្រព្យសកម្មបរទេសសុទ្ធ ត្រូវកាត់កងវិញដោយឥណទានផ្សេងទៀត ដែលរួមមាន ប្រាក់បញ្ញើមានកំហិត និង មូលធនធនាគារនិងធនបំរុងក្នុងធនាគារ ។ ឥណទានផ្សេងទៀត កើនបាន ៣,០% ដល់ ២៨០៣,៣ពាន់លានរៀល ។ កំណើនឥណទានក្នុងវិស័យឯកជន ត្រូវកាត់កងវិញដោយការធ្លាក់ចុះនៃឥណទានរដ្ឋាភិបាលសុទ្ធ (ដោយសារប្រាក់បញ្ញើរដ្ឋាភិបាលកើនឡើង) ។ ដូច្នេះ ធនាគារជាតិនៃកម្ពុជា កំពុងប្រឹងប្រែងគ្រប់គ្រងរូបិយវត្ថុទូទៅ ដើម្បីត្រួតត្រាលើអតិផរណា ពីព្រោះរូបិយវត្ថុទូទៅច្រើនពេកអាចនាំឱ្យមានអតិផរណា ។ នៅត្រីមាសទី២ ទ្រព្យសកម្មនៃប្រព័ន្ធរូបិយវត្ថុកើនឡើង ហើយនាំឱ្យមានកំណើនរូបិយវត្ថុទូទៅ ដែលរួមមានសាច់ប្រាក់ (រៀល) ប្រាក់បញ្ញើចរន្ត ប្រាក់បញ្ញើមានកាលកំណត់/សន្សំ និងប្រាក់បញ្ញើជាដុល្លារ ។ ប្រាក់រៀលក្រៅធនាគារ កើន ២៥% ធៀបនឹង កំឡុងពេលដូចគ្នា ២០០៥ ដល់ ១៤៥៩,០ពាន់លានរៀល ។ ប្រាក់បញ្ញើជារៀល ថយចុះអស់ ០,៩% ធៀបនឹងមួយឆ្នាំមុន មកត្រឹម ១៦៥,៤ពាន់លានរៀល ហើយបញ្ញើជាដុល្លារមាន ១០៧៦,២លានដុល្លារ រឺកើន ៣៤% ធៀបនឹងឆ្នាំមុន ។ ទោះបីជាធនាគារជាតិនៃកម្ពុជាគ្រប់គ្រងរូបិយវត្ថុទូទៅបានក្តី កម្ពុជានៅតែមានអតិផរណា ៤,៥% ក្នុងកំឡុងពេលនេះ ដោយសារតែចំណាយលើការនាំចូលពីបរទេសកើនខ្ពស់ជាងមុន ។

អត្រាការប្រាក់សំរាប់កំចីជាដុល្លារUS នៅថេរ ។ កំចីជាដុល្លារ មានអត្រាការប្រាក់ប្រចាំឆ្នាំ ១៦,៤% នៅត្រីមាសទី២ ។ ប្រាក់បញ្ញើជាដុល្លារក៏មានអត្រាការប្រាក់ប្រចាំឆ្នាំថេរផងដែរក្នុងកំរិត ៣,៩% ។

## ស្ថានភាពក្រីក្រ និងប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់ពលករងាយរងគ្រោះ

នៅរយៈមួយត្រីមាសគិតដល់ខែសីហា ២០០៦ ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់ពលករងាយរងគ្រោះចំនួន ១០ក្រុម បានថយចុះ ៩% ធៀបនឹងកំឡុងពេលដូចគ្នាឆ្នាំមុន ។ យោងតាមទិន្នន័យអង្កេតនៅខែសីហា ២០០៦ ប្រាក់ចំណូលប្រចាំថ្ងៃរបស់ក្រុមពលករងាយរងគ្រោះ បន្តធ្លាក់ចុះ លើកលែងតែកម្មករកាត់ដេរ និងអ្នកស៊ីឈ្នួលធ្វើស្រែ ដែលមានប្រាក់ចំណូលកើនឡើង (មើលតារាង ៨) ។

នៅខែសីហា ២០០៦ ប្រាក់ចំណូលអ្នករត់ម៉ូតូឌុប ថយចុះអស់ ២៨% ពីកំរិត ៩.៤០០រៀល នៅខែដូចគ្នា ២០០៥ មកត្រឹម ៦.៧០០រៀល ។ នេះជាការធ្លាក់ចុះដ៏ខ្លាំងបំផុតក្នុងចំណោមក្រុមទាំងអស់ ។ អ្នករត់ម៉ូតូឌុបភាគច្រើនបានត្អូញត្អែរថា ការថយចុះប្រាក់ចំណូលរបស់ពួកគាត់ បណ្តាលមកពីកំណើនយានទុកទុក និងការឡើងថ្លៃសាំង ។ ពួកគាត់និយាយថា ពីមួយថ្ងៃទៅមួយថ្ងៃ ប្រាក់ចំណូលរបស់ពួកគាត់ប្រៀបដូចជា "ទឹកនៅលើស្លឹកឈូក" គឺមិនទៀងទាត់ទេ ។ ដូច្នេះ ពួកគាត់ត្រូវចំណាយពេលរត់ម៉ូតូឌុបច្រើនជាងមុនដើម្បីផ្គត់ផ្គង់គ្រួសារ ។ ៩០% នៃអ្នកឆ្លើយសំភាសន៏ បាននិយាយថា ប្រាក់ចំណូលរបស់ពួកគាត់ មិនគ្រប់គ្រាន់ដើម្បីចិញ្ចឹមគ្រួសារទេ ពីព្រោះពួកគាត់ត្រូវចំណាយប្រាក់ច្រើនទៅលើម្ហូបអាហារនៅកំឡុងពេលរត់ម៉ូតូនៅភ្នំពេញ ។ បន្ទាប់ពីមានកំណើននៅខែឧសភា ប្រាក់ចំណូលប្រចាំថ្ងៃរបស់អ្នកធាក់ស៊ីក្លូនៅខែសីហា ថយចុះអស់ ២៣% មកត្រឹម ៦.១០០រៀល ធៀបនឹង ៧.៩០០រៀល នៅខែដូចគ្នា ឆ្នាំ២០០៥ រឺថយចុះ ២៩% ធៀបនឹងខែឧសភា ២០០៦ ។ អ្នកធាក់ស៊ីក្លូ ៧៧% រាយការណ៏ថា ប្រាក់ចំណូលរបស់ពួកគេ ធ្លាក់ចុះដោយសារកំណើនចំនួនកម្មករ ។ លើសពីនេះ មាន ៨៧% បាននិយាយថា ពួកគាត់មិនអាចសន្សំប្រាក់ដើម្បីជួយគ្រួសារបានទេ ។ តាំងពីដើមឆ្នាំ២០០៦ ចំនួនយានទុកទុក បានកើនយ៉ាងលឿន ហើយមាននៅតាមទីផ្សារ ភោជនីយដ្ឋាន ផ្ទះសំណាក់ សណ្ឋាគារ និងទីប្រជុំជនផ្សេងទៀត ។ យានទុកទុកនេះ ជាបច្ចេកវិទ្យាថ្មី ដែលផ្តល់ភាពងាយស្រួល និងមានសុវត្ថិភាពជាងម៉ូតូឌុប ។ ដូច្នេះ យាននេះបានដណ្តើមភ្ញៀវពីម៉ូតូឌុប និងជាពិសេសពីស៊ីក្លូ ដែលធ្លាប់តែមានប្រជាប្រិយភាព ។

អង្កេតលើអ្នកលីសែងនៅខែសីហា បានបង្ហាញថា ប្រាក់ចំណូលប្រចាំថ្ងៃរបស់ពួកគេ ធ្លាក់ចុះ ១៣% ធៀបនឹងខែដូចគ្នា ឆ្នាំ២០០៥ ។ អ្នកលីសែង ៨៣% រាយការណ៏ថា ការធ្លាក់ចុះនេះបណ្តាលមកពីកំណើនកម្មករ ។ អ្នកលីសែង ៨២% និយាយថា នៅខែសីហា ពួកគេចំណាយអស់ប្រហែល ១៥០.០០០រៀល ក្នុងនោះ ១១០.០០០រៀល ចំណាយទៅលើម្ហូបអាហារ ។ អ្នកលីសែង ៧២% និយាយថា ពួកគេមិនអាចសន្សំប្រាក់ពីចំណូលបានទេ ។ អ្នកលីសែង ៨៥% បានត្អូញត្អែរពីការលំបាករបស់ខ្លួនក្នុងការធ្វើចំណាកស្រុកមកធ្វើការនៅភ្នំពេញ ដូចជា ពិបាករកការងារធ្វើ (អ្នកខ្លះគ្មានការងារទេ) និងគ្មានកន្លែងស្នាក់នៅ ។ ៥០% នៃអ្នកលីសែងបានឆ្លើយសំភាសន៏ មានអាយុពី ១៨-២៥ឆ្នាំ ហើយភាគច្រើនមកពីជនបទ និងមកពីគ្រួសារមានជីវភាពក្រីក្រ ។

ធៀបនឹងខែសីហា ២០០៥ ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់អ្នកលក់បន្លែតូចតាច ថយចុះ ១២% មកត្រឹម ៥.២០០រៀល ប៉ុណ្ណោះ ។ អ្នកលក់បន្លែតូចតាច ៦៥% មកពីតាមខេត្ត ក្នុងនោះ ៣៣% មកពីខេត្តកណ្តាល ១២% មកពីព្រៃវែង ១០% មកពីតាកែវ និង ១០% ទៀតមកពីបណ្តាខេត្ត ផ្សេងៗ ។ ក្នុងចំណោមអ្នកទាំងនោះ ភាគច្រើនមកពីជនបទដោយ ៣៥% ជាអ្នកគ្មានដី ២៧% មានដីតិចជាងមួយ-

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

ហិកតា និង ៣៨% មានដីមួយ ហិកតា រឺច្រើនជាងនេះ ។ អង្កេតបង្ហាញថា ក្នុងចំណោមអ្នកលក់បន្លែតូចតាច មាន ៤២% ជាអ្នកមានគ្រួសារ ២០% មេម៉ាយ និង ៣៨% នៅលីវ ។ គេទាំងអស់គ្នាលើកឡើងថា ប្រាក់កំរៃដែលរកបាន គឺសំរាប់ទ្រទ្រង់គ្រួសារ ។ អ្នកលក់បន្លែតូចតាច ៤០% មិនបានចូលសាលារៀន រីឯ ៥០% បានបញ្ចប់បឋមសិក្សា ៨% បញ្ចប់អនុវិទ្យាល័យ ហើយមានតែ ២% ប៉ុណ្ណោះ បាន បញ្ចប់វិទ្យាល័យ ។

នៅខែសីហា ចំណូលប្រចាំថ្ងៃពិតរបស់កម្មករសំណង់មានជំនាញ និង គ្មានជំនាញ ធ្លាក់ចុះ ៨% និង ១% ធៀបនឹងខែដូចគ្នាឆ្នាំមុន ។ កំណើន កម្មករ គឺជាមូលហេតុចំបងនៃការធ្លាក់ចុះប្រាក់ចំណូលរបស់ពួកគេ ។ អង្កេតបានបង្ហាញថា កម្មករមានជំនាញដែលរៀបការរួចហើយមានប្រាក់ចំណូល ១៣% ច្រើនជាងកម្មករនៅលីវ ។ ផ្ទុយទៅវិញ កម្មករគ្មានជំនាញ នៅលីវ រកបាន ៦% ច្រើនជាងអ្នករៀបការហើយ ។ កម្មករសំណង់មានជំនាញភាគច្រើននិយាយថា ប្រាក់ចំណូលរបស់ពួកគេប្រែប្រួលពីមួយ ថ្ងៃទៅមួយថ្ងៃ ដូច្នេះពួកគេមិន-អាចសន្សំបានច្រើនទេ ។ ជាធម្មតា កម្មករ សំណង់មានជំនាញចំណាយប្រហែល ១២៥.០០០រៀល/ខែ ហើយកម្មករ គ្មានជំនាញចំណាយ ១២០.០០០រៀល/ខែ ។ ក្នុងចំណោមកម្មករ មានជំនាញទាំងនោះ ៤២% បានរាយការណ៍ថា ប្រាក់ចំណូលរបស់ពួកគេ ចំណាយបានតែលើថ្លៃម្ហូបអាហារប៉ុណ្ណោះ រីឯ ៥០% មានលទ្ធភាពចំណាយ លើម្ហូបអាហារ និងរបស់របរផ្សេងទៀត (ពួកគេមិនបានពន្យល់បន្ថែមទេ) ។ អ្នកនៅសល់ ៨% មិនបានឆ្លើយតបនឹងសំនួរនេះទេ ។ ប្រហែល ៨០% នៃ កម្មករសំណង់មានជំនាញ មកពីតំបន់ជនបទហើយ ១០% ជាជនគ្មានដី ។

ចំណូលប្រចាំថ្ងៃពិតរបស់អ្នករើសអេតចាយ ធ្លាក់ចុះអស់ ២% ធៀបនឹង ខែសីហា ២០០៥ ។ អ្នករើសអេតចាយ ៨០% លើកឡើងថា តំលៃអេតចាយ បានធ្លាក់ចុះនៅបីខែចុងក្រោយនេះ ប៉ុន្តែចំនួនអ្នករើសអេតចាយ បានកើន ឡើង ។ ក្នុងចំណោមអ្នករើសអេតចាយបានសំភាសន៍ ៩៥% ពឹងផ្អែកខ្លាំង លើចំណូលបានពីការប្រមូលអេតចាយ ប៉ុន្តែ ៧៣% និយាយថា ប្រាក់ចំណូលនេះ មិនអាចចិញ្ចឹមគ្រួសាររបស់ពួកគេបានទាំងស្រុងទេ ។ យោងតាមអង្កេតនេះ ៣០% ត្រូវជំពាក់បំណុលក្នុងអត្រាការប្រាក់ខ្ពស់ នៅពេលគ្រួសាររបស់ពួកគេ ខ្វះខាតម្ហូបអាហារ រឺមានជំងឺ ។ ជាទូទៅ ពួកគេខ្ចីប្រាក់ពីឈ្មួញទិញអេតចាយ និងត្រូវលក់អេតចាយឱ្យអ្នកទាំងនោះក្នុងតំលៃទាបដើម្បីសងបំណុល ។

អង្កេតលើកម្មករកាត់ដេរបានបង្ហាញថា រោងចក្រភាគច្រើន ផ្តល់ប្រាក់បៀវត្សរ៍ជាប្រាក់ដុល្លារUS ទោះបីជាមានរោងចក្រខ្លះផ្តល់ជាប្រាក់រៀលក្តី ជាពិសេសចំពោះកម្មករអំណែត ។ យោងតាមអង្កេតនៅខែសីហា ប្រាក់បៀវត្សរ៍ប្រចាំខែរបស់កម្មករគឺ ៧០ដុល្លារUS ដែលជាកំរិតប្រាក់បៀវត្សរ៍ ខ្ពស់បំផុតចាប់តាំងពីមានអង្កេត ។ គិតជាប្រាក់រៀល ប្រាក់ចំណូលប្រចាំថ្ងៃរបស់ពួកគេកើនបាន ៦% ដល់ ៩.៣០០រៀល ធៀបនឹង

## Cambodia Development Review – 2006 Subscription Rates

**Domestic Subscription (Individual)**

❑ English edition ($14) ❑ Khmer edition (5,000r) Payment by ❑ cash ❑ cheque ❑ Telegraphic Transfer

Total payment enclosed ______

**Domestic Subscription (Discount Price for Bulk Orders—Five Copies)**

❑ English edition ($60 for five copies) ❑ Khmer edition (20,000r for five copies)

Payment by ❑ cash ❑ cheque ❑ Telegraphic Transfer. Total payment enclosed ______

**International Subscription (Individual)**

❑ Thailand, Laos, Vietnam ❑ English edition ($25)* ❑ Khmer edition ($15)*

❑ Asia and Europe ❑ English edition ($30)* ❑ Khmer edition ($20)*

❑ Americas and Africa ❑ English edition ($35)* ❑ Khmer edition ($25)*

At present CDRI can accept payment from overseas only by US-dollar dominated cheque or By Telegraphic Transfer.

Total payment enclosed ______

**Payment options:**

1. By Telegraphic Transfer – Please add $10 for bank charges to the above Total Cost.
   Transfer to:
   Account Name: CDRI
   Account Number: *133451*
   Bank Name: *ANZ Royal Bank*
   Bank Address: *Phnom Penh, Cambodia*
   Swift Code: *ANZBKHPP*
   Receiver Correspondent Bank: *JP Morgan Chase Manhattan Bank, New York*
   *Swift Code: CHASUS33*
   *CHIP UID 004966*

2. By Cheque - Please add (overseas) $50 (local) $2 for bank charges to the above Total Cost. Please make Cheque payable to CDRI, attach it to this invoice and send in to Publications at the address shown at the masthead.

Title: ❑ Mr ❑ Ms ❑ Dr ❑ Other: ______ First name: ______ Last name: ______

Position: ______ Organisation / Company: ______

Address (CCC Box if applicable): ______

City / Province: ______ Country: ______

Telephone: ______ Fax: ______

e-mail: ______ ❑ Tick this box to receive regular information about CDRI publications via e-mail

To subscribe simply fill in this form and return it to CDRI with your payment. Please make cheques payable to the Cambodia Development Resource Institute. Do not send cash through the post. Please inform the Publications Section at CDRI if your contact details change.

## តារាង១. គំរោងវិនិយោគឯកជនដែលបានអនុម័ត ឆ្នាំ១៩៩៨-២០០៦

| | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 Q2 | Q3 | Q4 | 2006 Q1 | Q2 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | | | | | | |
| កសិកម្ម | 51.6 | 63.9 | 9.8 | 0.4 | 40.3 | 3.7 | 12.3 | 4.0 | 10.4 | 9.1 | 126.5 | 216.9 |
| ឧស្សាហកម្ម | 650.5 | 162.6 | 109.4 | 105.2 | 67.7 | 137.2 | 189.2 | 62.1 | 349.7 | 82.0 | 40.1 | 76.9 |
| កាត់ដេរ | *126.5* | *67.7* | *81.5* | *26.5* | *27.2* | *68.1* | *133.9* | 23.2 | 56.5 | 27.3 | 30.5 | 9.6 |
| សេវាកម្ម | 154.7 | 222.6 | 150.1 | 118.4 | 145.3 | 168.4 | 92.0 | 30.0 | 44.1 | 28.1 | 60.7 | 2,043.2 |
| សណ្ឋាគារ និងទេសចរណ៍ | *112.0* | *171.8* | *79.8* | *73.8* | *47.1* | *124.1* | *55.9* | 0.0 | 33.6 | 22.6 | 0.0 | 26.2 |
| សរុប | 856.8 | 449.1 | 269.2 | 224.0 | 253.3 | 309.3 | 293.5 | 96.1 | 404.2 | 119.2 | 227.3 | 2,337.0 |
| | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | - | - | -79.8 | 320.6 | -70.5 | 90.7 | 928.1 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 15.0 | -47.6 | -40.0 | -19.5 | 10.5 | 31.1 | -12.4 | -15.2 | 392.9 | 628.1 | -52.2 | 2331.2 |

*Including expansion project approvals. Up to June 2006. Source: Cambodian Investment Board*

## តារាង២. តំលៃគំរោងសំណង់នៅភ្នំពេញដែលបានអនុម័ត ឆ្នាំ១៩៩៨-២០០៦

| | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 Q2 | Q3 | Q4 | 2006 Q1 | Q2 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | លានដុល្លារ | | | | | | | | | | | |
| ភូមិគ្រឹះ, ផ្ទះ | 21.2 | 20.0 | 16.4 | 15.9 | 23.4 | 20.0 | 30.3 | 6.6 | 19.2 | 5.4 | 10.1 | 5.7 |
| ផ្ទះល្វែង | 227.3 | 290.5 | 174.8 | 167.8 | 179.9 | 91.6 | 167.6 | 69.1 | 41.3 | 45.1 | 39.9 | 51.8 |
| ផ្សេងៗ | 27.0 | 16.4 | 14.2 | 12.6 | 16.6 | 87.3 | 65.6 | 28.6 | 16.0 | 21.3 | 17.4 | 24.7 |
| សរុប | 275.4 | 326.8 | 205.4 | 196.2 | 219.8 | 198.9 | 263.4 | 104.3 | 76.5 | 71.8 | 67.4 | 82.2 |
| | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | - | - | -1.6 | -26.7 | -6.1 | -6.2 | 22.0 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 6.9 | 18.7 | -37.2 | -4.5 | 12.0 | -9.5 | 32.5 | 114.8 | -1.8 | 12.0 | -36.5 | -21.2 |

*Source: Department of Cadastre and Geography of Phnom Penh municipality*

## តារាង៣. ការនាំចេញ និងនាំចូល ឆ្នាំ១៩៩៨-២០០៦

| | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 Q2 | Q3 | Q4 | 2006 Q1 | Q2 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | លានដុល្លារ | | | | | | | | | | | |
| ការនាំចេញសរុប | 784.4 | 941.1 | 1056.2 | 1268.2 | 1453.2 | 1708.1 | 2108.1 | 515.0 | 730.0 | 644.8 | 603.2 | 652.5 |
| រួមមាន: សំលៀកបំពាក់ | 378.0 | 554.0 | 962.1 | 1202.2 | 1355.8 | 1628.4 | 2027.0 | 497.6 | 709.8 | 601.0 | 568.5 | 632.4 |
| - ទៅសហរដ្ឋអាមេរិក | 74.1 | 486.0 | 714.1 | 840.9 | 943.4 | 1099.8 | 1270.9 | 335.9 | 489.5 | 408.1 | 402.5 | 438.6 |
| - ទៅសហគមន៍អ៊ឺរ៉ុប | - | - | 228.1 | 323.3 | 356.3 | 414.7 | 590.8 | 106.0 | 162.5 | 145.3 | 110.6 | 142.2 |
| - ប្រទេសផ្សេងទៀត | 82.0 | 68.0 | 19.9 | 38.0 | 56.1 | 113.8 | 165.3 | 55.7 | 57.8 | 47.5 | 55.3 | 51.6 |
| កសិកម្ម | - | - | 94.2 | 66.0 | 97.3 | 79.7 | 81.2 | 17.3 | 20.2 | 43.8 | 34.7 | 20.2 |
| - កៅស៊ូ | - | - | 29.6 | 25.9 | 29.7 | 35.1 | 38.3 | 6.2 | 9.8 | 13.4 | 7.8 | 9.8 |
| - ឈើ | - | - | 32.9 | 22.3 | 16.0 | 10.2 | 11.1 | 2.9 | 2.1 | 2.0 | 2.1 | 2.3 |
| - ត្រី | - | - | 5.4 | 6.0 | 4.3 | 2.8 | 10.6 | 1.1 | 0.8 | 6.6 | 1.9 | 1.0 |
| - ផ្សេងៗ | - | - | 26.2 | 11.8 | 47.4 | 31.6 | 21.3 | 7.1 | 7.5 | 21.9 | 22.9 | 7.0 |
| ការនាំចូលសរុប | 1112.2 | 1237.4 | 1417.7 | 1501.4 | 1707.8* | 1824.9 | 2149.0 | 666.4 | 632.3 | 691.1 | 690.7 | 774.9 |
| រួមមាន: - សាំង | - | - | - | - | 25.9 | 33.2 | 30.2 | 9.3 | 9.9 | 10.7 | 10.9 | 12.4 |
| - ម៉ាស៊ូត | - | - | - | - | 100.8 | 109.6 | 109.4 | 25.8 | 24.6 | 21.1 | 32.5 | 32.2 |
| - សំភារៈសំណង់ | - | - | - | - | 12.9 | 80.8 | 95.3 | 37.1 | 38.7 | 26.2 | 37.0 | 39.1 |
| - ផ្សេងៗ | - | - | - | - | 1568.2 | 1601.3 | 1914.0 | 594.2 | 559.1 | 633.1 | 610.3 | 691.2 |
| ជញ្ជីងពាណិជ្ជកម្ម | -327.8 | -296.3 | -361.5 | -233.2 | -254.6 | -116.8 | -40.9 | -151.4 | 97.7 | -46.3 | -87.5 | -122.4 |
| | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | - | - | - | - | - | - | - | 11.8 | 42.6 | -15.3 | -5.4 | 11.2 |
| ការនាំចេញសរុប | - | - | - | - | - | - | - | 11.2 | 41.7 | -11.7 | -6.4 | 8.2 |
| ការនាំចូលសរុប | - | - | - | - | - | - | - | 28.0 | -5.1 | 9.3 | -0.03 | 12.2 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | 66.4 | 47.0 | 74.0 | 24.9 | 12.8 | 20.1 | 24.5 | 3.8 | 10.3 | 15.5 | 27.8 | 27.1 |
| ការនាំចេញសរុប | 59.0 | 20.0 | 12.2 | 20.1 | 14.6 | 17.5 | 23.4 | 4.1 | 9.2 | 18.3 | 30.3 | 26.7 |
| ការនាំចូលសរុប | 1.6 | 11.3 | 14.6 | 5.9 | 13.7 | 6.9 | 17.8 | 9.9 | 20.5 | 26.1 | 32.6 | 15.6 |

*Import data include tax-exempt imports. Sources: Department of Trade Preferences Systems, MOC and Customs and Excise Department, MEF.*

## តារាង៤. ចំនួនអ្នកដំណើរមកដល់ក្នុងប្រទេសកម្ពុជា ឆ្នាំ១៩៩៨-២០០៦

| | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 Q2 | Q3 | Q4 | 2006 Q1 | Q2 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | អ្នកដំណើរពាន់នាក់ | | | | | | | | | | | |
| តាមផ្លូវអាកាស | 186.3 | 262.9 | 351.7 | 408.4 | 523.0 | 456.0 | 626.1 | 169.8 | 202.8 | 251.5 | 275.4 | 204.4 |
| តាមផ្លូវគោក និងទឹក | 100.2 | 104.8 | 114.7 | 196.5 | 263.5 | 245.0 | 428.9 | 124.0 | 120.4 | 164.5 | 181.9 | 153.6 |
| សរុប | 286.5 | 367.7 | 466.4 | 604.9 | 786.5 | 701.1 | 1055.0 | 293.8 | 323.2 | 416.0 | 457.3 | 358.0 |
| | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | - | - | -22.8 | 10.0 | 28.7 | 9.9 | -21.7 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 30.9 | 28.3 | 26.8 | 29.7 | 30.0 | -10.9 | 50.5 | 51.6 | 41.8 | 9.8 | 20.2 | 21.2 |

*ប្រភព: ក្រសួងទេសចរណ៍ ។*

## តារាង៥. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានជាសាច់ប្រាក់ ឆ្នាំ១៩៩៨-២00៦ (ពាន់លានរៀល)

| | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 | | | 2006 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q2 | Q3 | Q4 | Q1* | Q2 |
| ចំណូលសរុប | 920 | 1326 | 1528 | 1529 | 1744 | 1765 | 2127 | 621.9 | 624.1 | 827.9 | 595.9 | 731.5 |
| ចំណូលចរន្ត | - | - | - | 1521 | 1728 | 1733 | 2107 | 611.5 | 609.5 | 701.6 | 593.2 | 726.9 |
| ចំណូលពន្ធ | 676 | 956 | 1096 | 1096 | 1227 | 1220 | 1577 | 466.0 | 436.2 | 553.8 | 484.7 | 558.6 |
| ពន្ធគយ | 376 | 432 | 376 | 376 | 424 | 395 | 513 | 129.7 | 123.7 | 189.8 | 135.5 | 151.7 |
| ចំណូលមិនមែនពន្ធ | 204 | 348 | 424 | 424 | 501 | 513 | 530 | 145.5 | 173.2 | 147.8 | 108.5 | 168.3 |
| អាជីវកម្មព្រៃឈើ | 20 | 36 | 28 | 29 | 15 | 7 | 2 | 1.5 | 0.3 | 0.1 | 0.5 | 0.7 |
| ប្រៃសណីយ៍ និងទូរគមនាគមន៍ | 88 | 108 | 124 | 122 | 123 | 120 | 94 | 32.0 | 30.9 | 38.0 | 11.4 | 30.0 |
| ចំណូលជាមូលធន | 36 | 12 | 8 | 9 | 16 | 31 | 19 | 10.4 | 14.6 | 126.3 | 2.7 | 4.6 |
| ចំណាយសរុប | 1296 | 1792 | 2332 | 2332 | 2948 | 2757 | 2932 | 713.7 | 912.4 | 998.9 | 820.6 | 978.9 |
| ចំណាយជាមូលធន | 368 | 624 | 976 | 977 | 1388 | 1171 | 1163 | 315.9 | 335.4 | 350.3 | 278.9 | 355.4 |
| ចំណាយចរន្ត | 980 | 1164 | 1356 | 1355 | 1560 | 1586 | 1769 | 397.8 | 577.0 | 648.6 | 541.7 | 623.5 |
| អប់រំ និងសុខាភិបាល | 132 | 280 | 344 | 343 | 454 | 473 | 518 | 92.3 | 202.1 | 228.4 | 80.3 | 202.3 |
| ការពារជាតិ និងសន្តិសុខ | 448 | 464 | 404 | 405 | 438 | 411 | 423 | 73.9 | 116.7 | 71.4 | 78.1 | 116.7 |
| ក្រសួងផ្សេងៗទៀត | 332 | 412 | 636 | 637 | 668 | 702 | 828 | 231.7 | 258.2 | 348.8 | 383.2 | 304.5 |
| ឱនភាពជាទូទៅ | -380 | -476 | -804 | -803 | -1204 | -992 | -805 | -91.9 | -288.3 | -171.0 | -224.7 | -247.4 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 268 | 416 | 768 | 766 | 1249 | 886 | 864 | 255.7 | 335.8 | 269.0 | 196.0 | 328.6 |
| ហិរញ្ញប្បទានក្នុងស្រុក | 112 | 60 | 36 | 37 | -45 | 106 | 148 | -163.9 | -47.5 | -97.9 | 28.6 | -81.3 |

## តារាង៦. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (ប្រែប្រួល) អត្រាប្តូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ឆ្នាំ១៩៩៨-២00៥

| | 1998 | 1999 | 2000 | 2001* | 2002 | 2003 | 2004 | 2005 | | | 2006 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q2 | Q3 | Q4 | Q1 | Q2 |
| | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ខេត្ត | - | 5.8 | 5.4 | -0.1 | 0.9 | 4.4 | 14.4 | 21.5 | 14.5 | 16.6 | 15.8 | 12.0 |
| ភ្នំពេញ - ទំនិញគ្រប់ប្រភេទ | 14.8 | 4.0 | -0.8 | 0.2 | 3.3 | 1.1 | 3.9 | 6.4 | 4.6 | 6.6 | 6.1 | 4.5 |
| - ម្ហូបអាហារ | 14.1 | 7.6 | -3.4 | -2.5 | 1.8 | 1.5 | 6.4 | 9.8 | 6.0 | 10.6 | 10.6 | 6.3 |
| - ដឹកជញ្ជូន | 15.1 | 3.5 | 6.6 | -4.2 | 0.3 | 4.9 | 9.7 | 11.1 | 11.9 | 10.2 | 9.7 | 10.0 |
| | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ* | - | - | 3840.8 | 3916.3 | 3912.1 | 3973.3 | 4016.3 | 4,054.3 | 4,134.3 | 4,154.3 | 4,094.8 | 4106.6 |
| រៀលក្នុង ១ បាតថៃ* | - | - | 95.8 | 88.2 | 91.1 | 95.8 | 99.9 | 101.3 | 100.2 | 101.4 | 103.5 | 108.0 |
| រៀលក្នុង ១00 ដុងវៀតណាម* | - | - | 27.1 | 26.6 | 25.6 | 25.6 | 25.5 | 25.3 | 25.9 | 26.1 | 25.4 | 25.0 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 40.4 | 36.0 | 33.3 | 32.8 | 36.8 | 41.4 | 46.3 | 52.5 | 55.4 | 57.0 | 64.2 | 72.2 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 883 | 1065 | 1105 | 1329 | 1521 | 1508 | 3442 | 2,500 | 2,767 | 2,921 | 2,867 | 3,110 |
| ថ្លៃសាំង (រៀល/លីត្រ) | 1378 | 1613 | 1760 | 2113 | 2084 | 2150 | 2633 | 3,300 | 3,633 | 3,750 | 3,767 | 4,000 |

## តារាង៧. ស្ថានភាពរូបិយវត្ថុ ឆ្នាំ១៩៩៨-២00៦ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 | | | 2006 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q2 | Q3 | Q4 | Q1 | Q2 |
| | ពាន់លានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 1726 | 2019 | 2589 | 3080 | 3737 | 4027 | 4797 | 5,084 | 5,391 | 5,475 | 6,410 | 6,682 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | -496 | -576 | -759 | -876 | -849 | -698 | -467 | -455 | -397 | -450 | -699 | -637 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | 178 | 103 | 3 | -75 | -119 | -128 | -209 | -343 | -404 | -421 | -755 | -831 |
| ឥណទានចំពោះផ្នែកឯកជន | 655 | 763 | 898 | 936 | 1059 | 1337 | 1817 | 2,166 | 2,386 | 2,394 | 2,778 | 2,997 |
| រូបិយវត្ថុទូទៅ M2 | 1230 | 1443 | 1831 | 2204 | 2888 | 3328 | 4329 | 4,629 | 4,994 | 5,025 | 5,711 | 6,045 |
| រូបិយវត្ថុ M1 | 543 | 531 | 540 | 609 | 813 | 937 | 1153 | 1,215 | 1,279 | 1,323 | 1,449 | 1,512 |
| រូបិយវត្ថុផ្សេងៗ | 687 | 911 | 1291 | 1594 | 2075 | 2391 | 3176 | 3,414 | 3,715 | 3,702 | 4,262 | 4,533 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ M2 | 15.7 | 17.3 | 26.9 | 20.4 | 31.0 | 15.2 | 30.0 | 20.4 | 19.8 | 16.1 | 27.0 | 30.6 |
| រូបិយវត្ថុ M1 | 41 | -2.2 | 1.7 | 12.8 | 33.5 | 15.3 | 23.0 | 16.8 | 18.6 | 14.7 | 20.9 | 24.4 |
| រូបិយវត្ថុផ្សេងៗ | 1.3 | 32.6 | 41.7 | 23.5 | 30.2 | 15.2 | 32.8 | 21.7 | 20.2 | 16.6 | 33.6 | 32.8 |

## តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ២000)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បំរែបំរួលធៀបនឹងឆ្នាំមុន (%) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2000 | 2002 | 2003 | 2004 | 2005 | | 2006 | | | 2006 | | |
| | វិច្ឆិកា | | | | សីហា | វិច្ឆិកា | កុម្ភៈ | ឧសភា | សីហា | កុម្ភៈ | ឧសភា | សីហា |
| អ្នកធាក់ស៊ីក្លូ | 7594 | 8975 | 8572 | 7614 | 7857 | 7768 | 7873 | 8546 | 6063 | -7.7 | 11% | -23% |
| អ្នកលីសែង | 6233 | 7044 | 6676 | 6895 | 6000 | 6473 | 6519 | 7375 | 5238 | -6.0 | 5% | -13% |
| អ្នកលក់បន្លែតូចតាច | 5256 | 6566 | 6532 | 6947 | 5938 | 8385 | 6186 | 6492 | 5197 | -3.3 | -24% | -12% |
| អ្នករើសអេតចាយ | 2718 | 3685 | 3944 | 4446 | 4335 | 4801 | 4984 | 4512 | 4266 | -7.4 | -14% | -2% |
| អ្នកបំរើតាមភោជនីយដ្ឋាន* | 2111 | 4365 | 4932 | 4448 | 4648 | 3893 | 4670 | 4243 | 4292 | 4.5 | -1% | -8% |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 4198 | 4304 | 4177 | 4139 | 4009 | 4224 | 4127 | | 4137 | 3.3 | 19% | 3% |
| កម្មកររោងចក្រកាត់ដេរ | 6701 | 8904 | 9577 | 9277 | 8756 | 8659 | 9184 | 7860 | 9264 | -0.3 | 9% | 6% |
| អ្នករត់ម៉ូតូឌុប | 8,610 | 12,184 | 10,092 | 9204 | 9406 | 9645 | 8884 | 8790 | 6744 | -24.5 | -23% | -28% |
| កម្មករសំណង់គ្មានជំនាញ | 5399 | 6453 | 6558 | 6382 | 6069 | 6691 | 5974 | 6407 | 6028 | 3.9 | -21% | -1% |
| កម្មករសំណង់មានជំនាញ | 13,127 | 12,605 | 13,111 | 12,679 | 10,273 | 11,253 | 11,750 | 9833 | 9466 | -18.2 | -20% | -8% |

*សំគាល់: ចំណូលអ្នកបំរើតាមភោជនីយដ្ឋាន អ្នកស៊ីឈ្នួលធ្វើស្រែ កម្មករកាត់ដេរ អ្នករត់ម៉ូតូឌុប និងកម្មករសំណង់មាននិងគ្មានជំនាញ ចាប់ធ្វើអង្កេតពីខែកុម្ភៈ ២000 ។ *ចំណូលអ្នកបំរើតាមហាងមិនរាប់បញ្ចូលអាហារ និងការស្នាក់នៅដែលម្ចាស់ភោជនីយដ្ឋានផ្តល់ឱ្យទេ។ ប្រភព: តារាង៥: ទិន្នន័យបណ្តោះអាសន្នឆ្នាំ ២00៦ *លេខកែតំរូវ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ / តារាង៦: * លេខកែតំរូវ CDRI, IMF, NIS, ក្រសួងផែនការ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ/ តារាង៧: NBC / តារាង៨: CDRI ។*

តពីទំព័រ ២០ **ព័ត៌មានថ្មីៗ ...**

វិជ្ជាស្ថានជាតិស្ថិតិ នៅថ្ងៃទី២៨-៣០ ខែវិច្ឆិកា ឆ្នាំ២០០៦ ។ ព្រឹត្តិការណ៍នេះ រួមមាន សិក្ខាសាលាថ្នាក់ជាតិ នៅព្រឹកថ្ងៃទី២៨ ដើម្បីផ្តល់ព័ត៌មានដល់អ្នកបង្កើតគោលនយោបាយ អង្គការសង្គមស៊ីវិល វិទ្យាស្ថានស្រាវជ្រាវ ផ្សេងៗ និងដៃគូអភិវឌ្ឍន៍របស់កម្ពុជា ស្តីពីការរកឃើញសំខាន់ៗនៃការសិក្សា ក៏ដូចជាអនុសាសន៍ខាងគោលនយោបាយ និងការស្រាវជ្រាវ ។ នៅព្រឹក ថ្ងៃទី២៩ វបសអ បានបើកកិច្ចប្រជុំតុមូលមួយ សម្រាប់អ្នកអនុវត្តន៍ ដើម្បីពិភាក្សាពីវិធីសាស្រ្តស្រាវជ្រាវ និងអនុសាសន៍ខាងគោលនយោបាយ ក្នុងគោលបំណងកាត់បន្ថយភាពក្រីក្រ ។ នៅព្រឹកថ្ងៃទី៣០ វបសអ បានរៀបចំកិច្ចប្រជុំក្រៅផ្លូវការមួយ រវាងអ្នកសរសេររបាយការណ៍ PPA និងអ្នកជួយកែសំរួល ដើម្បីពិភាក្សាពីមធ្យោបាយពង្រឹងគុណភាពរបាយការណ៍បញ្ចប់ ។ ការរកឃើញ និងអនុសាសន៍ខាងគោលនយាបាយ នឹងមានបោះពុម្ពផ្សាយជាភាសាអង់គ្លេស អមដោយសេចក្តីសង្ខេបជាភាសាខ្មែរផងដែរ ។

នៅដើមខែធ្នូ ឆ្នាំ២០០៦ វបសអ បានរៀបចំសិក្ខាសាលាដំបូងមួយដើម្បីបង្ហាញពីគំរោងអភិវឌ្ឍន៍សមត្ថភាពស្រាវជ្រាវការគ្រប់គ្រងធនធានទឹក ដែលថ្មីៗនេះបានផ្តួចផ្តើមឡើងដោយសហការជាមួយសាកលវិទ្យាល័យស៊ីដនី និងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ។ នៅក្នុងដំណាក់កាលដំបូងនៃគំរោង ដែលមានរយៈពេល ៦ខែ វបសអ និងដៃគូរបស់ខ្លួន បានជួបជាមួយអ្នកពាក់ព័ន្ធសំខាន់ៗ ដូចជា ក្រសួងធនធានទឹក ក្រសួងកសិកម្ម ទីភ្នាក់ងារអភិវឌ្ឍន៍របស់បារាំង (AFD) និងទីភ្នាក់ងារអូស្រ្តាលីសំរាប់ការអភិវឌ្ឍន៍អន្តរជាតិ (AusAID) ដើម្បីបង្កើតគណៈកម្មាធិការប្រឹក្សាយោបល់មួយ និងរៀបចំផែនការការងារសំរាប់ឆ្នាំដំបូងនៃគំរោង៥ឆ្នាំ ។ គណៈកម្មាធិការប្រឹក្សាយោបល់ បានបង្កើតឡើងក្នុងគោលបំណងជួយធានាថា ការអភិវឌ្ឍន៍សមត្ថភាព និងការស្រាវជ្រាវនៅក្នុងគំរោង ឆ្លុះបញ្ចាំងពីតំរូវការ និងចំណាប់អារម្មណ៍របស់វិទ្យាស្ថាន ពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានទឹក ជាពិសេស វិស័យធារាសាស្រ្តនៅកម្ពុជា ។ គំរោង នឹងចាប់ផ្តើមសកម្មភាពនៅខែមករា ២០០៧ ដោយផ្តើមចេញពីការសិក្សាឯកសារនៃការស្រាវជ្រាវ-វិស័យ ធារាសាស្រ្តនៅកម្ពុជា និងការវាយតំលៃខាងសង្គមលើវិស័យធារាសាស្រ្ត ដើម្បីកំណត់ពីគំលាតនៃចំណេះដឹង និងពីបញ្ហាសំខាន់ៗជាច្រើនទាក់ទិននឹងការគ្រប់គ្រងធនធានទឹក ។

នៅពាក់កណ្តាលខែធ្នូ ឆ្នាំ២០០៦ វបសអ ធ្វើសិក្ខាសាលាមួយថ្ងៃពេញ ដើម្បីបង្ហាញពីលទ្ធផលនៃការសិក្សារបស់បណ្តាញវិភាគអភិវឌ្ឍន៍ (DAN) ទាក់ទិននឹងទេសចរណ៍អំណោយផលដល់អ្នកក្រីក្រនៅមហាអនុតំបន់មេគង្គ ។ បណ្តាញវិភាគអភិវឌ្ឍន៍ បានទទួលការឧបត្ថម្ភពីមូលនិធិ Rockefeller និងមានការចូលរួមដោយវិទ្យាស្ថានស្រាវជ្រាវមកពីប្រទេសកម្ពុជា ឡាវ ថៃ វៀតណាម និងខេត្តយូណាន (ប្រទេសចិន) ។ នៅកំឡុងពេលសហការស្រាវជ្រាវ ប្រទេសនីមួយៗ បានសិក្សាពីករណី-ជាក់លាក់មួយនៃផលប៉ះពាល់របស់វិស័យទេសចរណ៍ទៅលើអ្នកក្រីក្រនៅទីកន្លែងបាន ជ្រើសរើស ។ ករណីសិក្សានៅប្រទេសកម្ពុជា ធ្វើនៅខេត្តសៀមរាប ប្រទេស ឡាវជ្រើសរើស Luang Prabang ប្រទេសថៃជ្រើសរើសភូមិមួយនៅក្រៅ Chiang Mai ប្រទេសវៀតណាមជ្រើសរើស Sapa រីឯខេត្តយូណាន ជ្រើសរើសកន្លែង ២ នៅ Xishuanbanna ។ ការសិក្សានេះ មានគោលដៅចំបង គឺបង្កើតគោលនយោបាយអំណោយផលដល់អ្នកក្រ ទាំងនៅថ្នាក់ជាតិនិងតំបន់ នៅពេលដែលវិស័យទេសចរណ៍កំពុងរីកលូតលាស់នៅពាសពេញតំបន់ ។ នៅក្នុងសិក្ខាសាលា ប្រទេសនីមួយៗ នឹងបង្ហាញពី ករណីសិក្សារបស់ខ្លួន បន្ទាប់មកនឹងមានការធ្វើរបាយការណ៍សំយោគ និង កិច្ចពិភាក្សា ។

នៅដើមខែមករា ២០០៧ មូលនិធិ Rockefeller នឹងផ្តល់ការឧបត្ថម្ភដល់

---

តពីទំព័រ ៧ **ការបង្កើតទស្សនៈនៃ...**

សីលធម៌មិនយោបាយ ដែលមាននៅក្នុងគ្រប់ប្រព័ន្ធរបស់រដ្ឋាភិបាល ទាំងក្នុងទំរង់ផ្លូវការ ក្រៅផ្លូវការ នយោបាយ និងរដ្ឋបាល ។

- គណនេយ្យភាព វាជាប់ពាក់ព័ន្ធទាំងទំនាក់ទំនងរវាងតួអង្គពីរ យន្តការវិធាន និងធនធាន ដើម្បីឱ្យប្រព័ន្ធអាចដំណើរការបានប្រកបដោយគណនេយ្យភាព ។
- ប្រព័ន្ធមានគណនេយ្យភាពដែលបំរើផលប្រយោជន៍សាធារណៈ គួរតែមានកម្ពុជាធ្វើជាម្ចាស់ និងបង្ហាញពីសីលធម៌របស់កម្ពុជា ។
- ដោយមានកំលាំងគាំទ្រពីការចូលរួមរបស់សាធារណៈជន និងការឆ្លើយតបខាងនយោបាយ ប្រព័ន្ធនេះ គួរតែជួយកសាងទំនុកចិត្តចំពោះស្ថាប័នសាធារណៈ ដោយបង្ហាញពីអព្យាក្រឹតភាព និងការទទួលខុសត្រូវខាងរដ្ឋបាល ជួយការពារទំនិញសាធារណៈ[៣] និង-គាំទ្រដល់អ្នកក្រីក្រ ។
- ប្រព័ន្ធដែលមានគណនេយ្យភាព និងប្រសិទ្ធភាពកាន់តែច្រើន ត្រូវតែរៀបចំយ៉ាងណាឱ្យមានការបែងចែកច្បាស់លាស់នូវតួនាទី ការទទួលខុសត្រូវ ធនធានគ្រប់គ្រាន់អាចព្យាករណ៍បាន ការសំរបសំរួលទាំងខ្សែបណ្តោយនិងខ្សែទទឹង តំលាភាព ការដាក់អនុវត្តន៍ច្បាប់ និងការលើកទឹកចិត្តដល់គ្រប់ៗគ្នាដែលអនុវត្តការងារបានល្អ ។

សរុបមក ការកសាងគណនេយ្យភាពអំណោយផលដល់អ្នកក្រឱ្យមានជោគជ័យ ដើម្បីសំរេចបានការអភិវឌ្ឍន៍របបប្រជាធិបតេយ្យនៅកម្ពុជា គឺអាស្រ័យលើការរកឃើញនូវគំរូនិងរបៀបរបបគណនេយ្យភាព ដែលមានលក្ខណៈជាប់ពាក់ព័ន្ធល្អ និងឈរលើរបៀបរៀបចំការិយាធិបតេយ្យសមហេតុផល-ស្របច្បាប់ និងរបបប្រជាធិបតេយ្យមានប្រជាប្រិយភាព ព្រមទាំងការយល់ដឹង និងការកែតំរូវរបៀបរបបទាំងនេះទៅតាមស្ថានភាពជាក់ស្តែងនៅក្នុងមូលដ្ឋាន ។

**កំណត់សំគាល់**

១. ក្រុមអ្នកស្រាវជ្រាវបានផ្ទៀងផ្ទាត់ក្នុងវចនានុក្រមសម្តេចសង្ឃ ជួន ណាត ប៉ុន្តែ វចនានុក្រមពុំមានចុះពាក្យនេះទេ ។

# ព័ត៌មានថ្មីៗ ពី វបសអ

## ការគ្រប់គ្រង

នៅចុងខែតុលា នាយកប្រតិបត្តិ វបសអ លោក Larry Strange បានជួបជាមួយសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ដើម្បីជំរាបពីការរីកចំរើន និងអាទិភាពស្រាវជ្រាវថ្មីៗរបស់ វបសអ និងដើម្បីគោរពអញ្ជើញសម្តេចថ្លែងសុន្ទរកថាពីកំណត់សំគាល់សំខាន់ៗនៅក្នុងសន្និសីទប្រមើលមើលពីកម្ពុជា (Cambodian Outlook Conference) ដែល វបសអ រៀបចំឡើងដោយសហការណ៍ជាមួយធនាគារ ANZ Royal នៅខែមីនា ឆ្នាំ២០០៧ ។ សម្តេចនាយករដ្ឋមន្ត្រីបានសំដែងការគាំទ្រយ៉ាងខ្លាំង ទាំងនៅពេលជំនួបប្រជុំ និងនៅតាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មាននូវឯករាជភាពនៃការស្រាវជ្រាវរបស់ វបសអ និងគុណតំលៃនៃការស្រាវជ្រាវនេះចំពោះអ្នកបង្កើតគោលនយោបាយកម្ពុជា និងអ្នកពាក់ព័ន្ធផ្សេងទៀតក្នុងកិច្ចអភិវឌ្ឍន៍ប្រទេស ។ សម្តេច ក៏បានយល់ព្រមថ្លែងសុន្ទរកថាក្នុងសន្និសីទប្រមើលមើលពីកម្ពុជា នៅកាលបរិច្ឆេទមួយ តាមការកំណត់ ។ បន្តពីសន្និសីទនេះ វបសអ នឹងបើកកិច្ចប្រជុំក្រុមប្រឹក្សាភិបាលពេញអង្គប្រចាំឆ្នាំរបស់ខ្លួន ដើម្បីពិចារណាពីជំរើសអាទិភាពស្រាវជ្រាវ និងគោលនយោបាយដែលបានមកពីសន្និសីទ ។

នៅថ្ងៃទី១៣-១៤ ខែតុលា នាយកប្រតិបត្តិ វបសអ បានចូលរួមក្នុងវេទិកាវិទ្យាស្ថានស្រាវជ្រាវនៅអាស៊ីខាងកើតលើកទី២ ដែលមានវិទ្យាស្ថានស្រាវជ្រាវគោលនយោបាយសេដ្ឋកិច្ចកូរ៉េជាម្ចាស់ផ្ទះ ។ វេទិកានេះធ្វើឡើងនៅលើកោះ Jeju ប្រទេសកូរ៉េខាងត្បូង ក្រោមប្រធានបទ "សមាហរណកម្មសេដ្ឋកិច្ចអាស៊ីនៅខាងកើត: ការរីកចំរើន និងឧបសគ្គ" ។ លោកនាយក វបសអ បានធ្វើបទបង្ហាញស្តីពី "កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ដើម្បីសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ ការរីកចំរើន និងសហគមន៍: ផ្លូវដើរទៅមុខរបស់អាស៊ីខាងកើត" ។ វេទិកានេះ មានការចូលរួមពីនាយកនៃវិទ្យាស្ថានស្រាវជ្រាវឈានមុខនានានៅអាស៊ាន ចិន កូរ៉េខាងត្បូង និងជប៉ុន ហើយបានយល់ព្រមលើរបៀបវារៈស្រាវជ្រាវគោលនយោបាយសហការគ្នាលើប្រធានបទចំនួន ៣ គឺ ១) បណ្តាញផលិតកម្មអាស៊ីខាងកើត និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ីខាងកើត ២) ទិសដៅថ្មីសំរាប់កិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុនៅអាស៊ីខាងកើតក្រោយកិច្ចប្រជុំនៅឈៀងម៉ៃ និង ៣) គំរូសហប្រតិបត្តិការអភិវឌ្ឍន៍ថ្មីមួយ និងគំនិតផ្តួចផ្តើមនានាសំរាប់អាស៊ីខាងកើត ។ វបសអ បានចូលរួមរួចហើយនៅក្នុងកម្មវិធីស្រាវជ្រាវ គោលនយោបាយសហការគ្នាស្តីអំពីសមាហរណកម្មទីផ្សារនៅមហាអនុតំបន់មេគង្គ ដែលរៀបចំឡើងដោយវិទ្យាស្ថានស្រាវជ្រាវការអភិវឌ្ឍន៍ថៃ ដោយ មានការគាំទ្រពីមជ្ឈមណ្ឌលបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បី អភិវឌ្ឍន៍អន្តរជាតិ ។ កិច្ចប្រឹងប្រែងទាំងពីរនេះរួមគ្នា នឹងពង្រឹងសមត្ថភាព និងការស្រាវជ្រាវជាបណ្តើរៗអំពីសមាហរណកម្មក្នុងតំបន់ និងអនុតំបន់ នៅអាស៊ីខាងកើត និងផលប៉ះពាលរបស់វាមកលើប្រទេសកម្ពុជា ។

នៅខែតុលា វបសអ បានស្វាគមន៍ការវិលត្រលប់មកវិញរបស់លោក ច័ន្ទ សុផល អតីតអ្នកស្រាវជ្រាវជាន់ខ្ពស់មានបទពិសោធន៍យូរឆ្នាំ មកទទួលតំណែងជាប្រធានស្រាវជ្រាវជាន់ខ្ពស់ផ្នែកការសិក្សាពីភាពក្រីក្រ និងបណ្តាញស្រាវជ្រាវផ្សេងៗ ដោយយោងតាមបទពិសោធន៍ដ៏ល្អរបស់គាត់ជាសមាជិកក្រុមសិក្សាពីភាពក្រីក្រនៃធនាគារពិភពលោកនៅកម្ពុជា ។ តំណែងនេះ គឺជាតំណែងគ្រប់គ្រងស្រាវជ្រាវចុងក្រោយត្រូវបំពេញ នៅក្នុងការរៀបចំរចនាសម្ព័ន្ធសាជាថ្មីខាងផ្នែកស្រាវជ្រាវរបស់ វបសអ ដោយផ្អែកលើផែនការយុទ្ធសាស្ត្រ វបសអ ឆ្នាំ២០០៦-២០១០ ។

## ការស្រាវជ្រាវ

វបសអ បានបង្ហាញរបាយការណ៍នៃគំរោងវាយតំលៃភាពក្រីក្រដោយមានការចូលរួមនៅតំបន់បឹងទន្លេសាប ជាមួយនឹងធនាគារអភិវឌ្ឍន៍អាស៊ី និង

តទៅទំព័រទី ១៩


# ទស្សនាវដ្តី អភិវឌ្ឍន៍កម្ពុជា

*ឯកសារបោះពុម្ពផ្សាយរបស់*
*វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា*

ឆ្នាំទី១០ លេខ៤ ខែតុលា-ធ្នូ ឆ្នាំ២០០៦

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* បោះពុម្ពផ្សាយដោយ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា នៅភ្នំពេញចំនួន ៤ដង ក្នុងមួយឆ្នាំជាភាសាខ្មែរ និងភាសាអង់គ្លេសនៅក្នុងពេលដំណាលគ្នា ។

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* ផ្តល់ជាវេទិកាមួយ ដើម្បីពិភាក្សាពីបញ្ហានៃការអភិវឌ្ឍន៍ដែលកំពុងតែជះឥទ្ធិពលដល់ប្រទេសកម្ពុជា ។ *អត្ថបទតាមដានសេដ្ឋកិច្ច* ផ្តល់ជូននូវមូលវិចារឯករាជ្យស្តីពីដំណើរប្រព្រឹត្តទៅនៃសេដ្ឋកិច្ចប្រទេសកម្ពុជា ។

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* ស្វាគមន៍អត្ថបទទាំងឡាយពីប្រិយមិត្តអ្នកអាន ។ លិខិត ត្រូវចុះហត្ថលេខាប្រត្យក្សភាព ទូរស័ព្ទ និងមានអាសយដ្ឋានផង ។ អ្នកនិពន្ធទាំងអស់ត្រូវទាក់ទង វបសអ មុននឹងជូនអត្ថបទរបស់ខ្លួន ទោះជាឯកសារនោះមិនទាន់រៀបរយក៏ដោយ ។ ឯកសារទាំងអស់នឹងត្រូវកែសម្រួលសំរាប់ការបោះពុម្ព ។ វបសអ សូមរក្សាសិទ្ធិបដិសេធការបោះពុម្ព ដោយមិនចាំបាច់បញ្ជាក់ពីហេតុផល ។



## វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

☞ ផ្ទះលេខ៥៦ ផ្លូវ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា
✉ ប្រអប់សំបុត្រលេខ៦២២ ភ្នំពេញ កម្ពុជា
☎ (៨៥៥-២៣) ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣ 🖷 (៨៥៥-២៣) ៨៨០-៧៣៤
e-mail: cdri@camnet.com.kh / pubs@cdri.forum.org.kh
website: http://www.cdri.org.kh



ISBN: 99950 –52-06-7

គ្រឹះស្ថានផ្សាយ: វបសអ
គ្រប់គ្រងកែសំរួល: យូ សិទ្ធិរិទ្ធ
កែសំរួលផលិតកម្ម: អ៊ុំ ចាន់ថា
ជំនួយការកែសំរួល: យេន សុផានី និង គីម ចិត្រា
រោងពុម្ពជប៉ុន ភ្នំពេញ រូបភាពទំព័រមុខ: រូបភាព CDRI



រក្សាសិទ្ធិ ២០០៦ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

រក្សាសិទ្ធិគ្រប់យ៉ាង-គ្មានផ្នែកណាមួយនៃការបោះពុម្ពផ្សាយនេះត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗដូចជា: អេឡិចត្រូនិក យន្តកម្មថតចម្លង... ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពី វបសអ ឡើយ ។


ISSN 1560-7615 / ISBN 978-99950-52-06-5


ទំនួលខុសត្រូវលើគំនិត សត្យានុម័ត និងការបញ្ចេញយោបល់ទាំងឡាយនៅក្នុង *ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* គឺជាបន្ទុកផ្ទាល់របស់អ្នកនិពន្ធ ។
ការបញ្ចេញយោបល់ និងការបកស្រាយទាំងនោះ មិនមែនជាទស្សនៈរបស់ *វបសអ* ទេ ។